ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- រំឭកដល់ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ៧មករា
- គណៈប្រតិភូកងពលតូចថ្មើរជើងលេខ ៨១ ទស្សនកិច្ចសិក្សាបណ្ណាល័យសម្តេចម៉ែ
- តើលោកអាចកំណត់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយវិធីណា?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៥ ខែមករា ឆ្នាំ២០២២

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៥ ខែមករា ឆ្នាំ២០២២

## មាតិកា

### សំបុត្រ

◆ រំឭកដល់ទិវាជ័យជម្នះលើរបបប្រល័យ.....១

### ផ្នែកឯកសារ

◆ សូ គីមអាន ហៅ អាចារ្យ មុី អនុលេខា....២

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ គណៈប្រតិភូកងពលតូចថ្មើរជើងលេខ៨១. ៦
◆ រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី....៨
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុងស្រុក ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ........ ១១
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង..........១៧
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម.. ២៣
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅក្នុងភូមិសាទុំឃុំដាំក្រវៀន........... ២៥
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅក្នុងស្រុក កំពង់សៀម ខេត្តកំពង់ចាម.............. ៣២
◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនិងគម្រោង សុខភាពរបស់........................... ៣៩
◆ ម៉ម រិនៈ ខ្មែរក្រហមធ្វើឲ្យស្ថានភាព..... ៤២

### ផ្នែកវេទិកាសាធារណៈ

◆ តើលោកអាចកំណត់អ្នករស់រានមានជីវិតពី របបខ្មែរក្រហមដោយវិធីណា? ...........៥៤

### ផ្នែកស្រាវជ្រាវរកគ្រួសារ

**«ទួលពិឃាដ»**

◆ ៤. ព្យុះជីវិតក្រោយមេឃបាត់ដួងចន្ទ្រ...... ៥៦



ប្រជាជនកម្ពុជាបានវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្ដួលរំលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រ៉ារដ្ឋ មេត្តា, ងីម ស៊ីហន, សួត វិចិត្រ, មេក វិន, ហ៊ិន ពិសី, ផេង ពង្ស៊្រ៉ាសុី, ភា រស្មី, សូ ហាន់, ថុន ស្រីពេជ្រ, កាន់ សុភាព, សៀង កញ្ញា, មឿន ហាច, ង៉ាន់ វីន, ជីម សុខគា, សុខ ចន្ទ្រា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាក ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# រំឭកដល់ទិវាជ័យជម្នះលើ របបប្រល័យពូជសាសន៍ ៧មករា

**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**




*រូបបដិមាវីរស្ត្រីកម្ពុជា៖ មានក្តីសង្ឃឹម រូបបដិមានេះគឺជាស្នាដៃរបស់សិល្បករឥណ្ឌូនេស៊ី លោក នីយ៉ូមេន ណួតា ផ្តល់កិត្តិយសដល់ស្ត្រីទាំងអស់ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អមជាមួយនឹងសាច់រឿងផ្តល់ដោយលោក ឆាំង យុ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្នុងសម័យកាលដ៏ខ្មៅងងឹត ជីវិតមនុស្សហាក់ដូចជាគ្មានអត្ថន័យ។ ការសម្លាប់រង្គាលបានកើតឡើងដោយគ្មានមូលហេតុអ្វីទាល់តែសោះ។ មានតែអ្នកមានអំណាចប៉ុណ្ណោះដែលអាចមើលឃើញអនាគតរបស់ខ្លួន ព្រមទាំងបានប្រាថ្នាលើសពីអ្វីដែលខ្លួនត្រូវការ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច អំពើឃោរឃៅ និងការបង្ហូរឈាមជាតិសាសន៍ខ្លួនបានកើតឡើង។ ខ្មែរក្រហមបានធ្វើឲ្យស្ត្រីជាច្រើនរស់នៅឯកោ ព្រាត់ប្រាសពីគ្រួសាររបស់ខ្លួន។ ពិភពលោកបានដឹងថាមានអំពើប្រល័យពូជសាសន៍នៅកម្ពុជា ប៉ុន្តែមានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានដឹងអំពីការតស៊ូជម្នះរាល់ឧបសគ្គរបស់ស្ត្រីទាំងនេះ ដើម្បីខ្លួនឯងនិងកូនៗរបស់ខ្លួន។ ស្ត្រីទាំងនេះបានពេបប្រទះទុក្ខលំបាកធ្ងន់ធ្ងរជាច្រើន ប៉ុន្តែស្ត្រីនៅតែមានភាពរឹងមាំមិនងាយទ្រុឌទ្រោមពុះពារហែលឆ្លង។ ដោយប្រើប្រាស់ដៃទាំងគូរបស់ខ្លួន ស្ត្រីទាំងនេះបានកសាងគ្រួសារ និងប្រទេសជាតិរបស់ខ្លួនសាជាថ្មីឡើងវិញ។ រូបបដិមានេះ គឺជាការឧទ្ទិសដល់ស្ត្រីទាំងអស់ដែល រស់រានមានជីវិតពីរបបខ្មែរក្រហម ជាវីរស្ត្រីកម្ពុជា។

# សូ គីមអាន ហៅ អាចារ្យ ម៉ី អនុលេខា តំបន់ ១០៥ ភូមិភាគឦសាន

*ដារ៉ាវឌ្ឍ មេត្តា*



*កងឈ្លបបដិវត្តន៍ខ្មែរក្រហមកំពុងដោតចម្រូងការពារភូមិ។ ខេត្តរតនគិរី ឆ្នាំ១៩៦៨-១៩៦៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សូ គីមអាន ហៅ អាចារ្យ ម៉ី មានអាយុ ៤៤ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកអ្នកលឿង ឃុំព្រែកអ្នកលឿង ស្រុកពាមរក៍ តំបន់២៤។ នៅក្នុងឆ្នាំ១៩៥៤ ខ្ញុំប្រឡងជាប់សាលាបាលីជាន់ខ្ពស់។ កាលខ្ញុំនៅរៀនខ្ញុំស្នាក់នៅ

កុដិលោកអាចារ្យ យុត មានសញ្ញារូបសេះ នៅវត្តខណ្ណាលោម។ ខ្ញុំមានភាពជិតស្និទ្ធជាមួយអាចារ្យ យុត ក្រោយមកប្រហែលជាចុងឆ្នាំ១៩៥៤ ខ្ញុំចូលជាខ្មែរសេរី។

នៅក្នុងឆ្នាំ១៩៥៨ ខ្ញុំត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាដូច្នេះខ្ញុំត្រូវតែខិតខំរៀនដើម្បីត្រៀមប្រឡង។ ខ្ញុំទាក់ទងសិស្សម្នាក់ឈ្មោះ ញេប សាវ៉ាន រស់នៅភូមិព្រែកអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង ដោយអប់រំនយោបាយក្បត់និងប្រគល់ឲ្យអាចារ្យ យុត អប់រំបន្តរួចហើយ ចាត់តាំង សាវ៉ាន ជាសមាជិកខ្មែរសេរី។ ក្រោយមកខ្ញុំប្រឡងធ្លាក់ និងត្រូវរៀនរយៈពេល១ឆ្នាំថែមទៀត។ បន្ទាប់មកខ្ញុំក៏ប្រឡងជាប់ ហើយក៏ឈប់រៀន។

នៅក្នុងឆ្នាំ១៩៥៩ គ្រូបង្រៀនឈ្មោះ ជ័យ អេ គឺជាខ្មែរសេរីបង្រៀននៅសាលាបឋមសិក្សារំលង ខេត្តកំពង់ធំបានបើកសាលាឈ្នួលឈ្មោះ អនុវិទ្យាល័យសង្គមសិក្សា នៅក្រុងកំពង់ធំ។ ជ័យ អេ មកទាក់ទងអាចារ្យ សាន វត្តសារាវ័ន ក្រុងភ្នំពេញ។ អាចារ្យ សាន បានមកទាក់ទងខ្ញុំ។ ខ្ញុំបង្រៀននៅអនុវិទ្យាល័យសង្គមសិក្សាបានរយៈពេល១ឆ្នាំ ប៉ុន្តែដោយសារខ្ញុំឃើញសាលាមិនមានស្ថិរភាពខ្ញុំបានសុំលា ជ័យ អេ ទៅបង្រៀនជាមួយ យឹម ធន នៅសាលាអនុវិទ្យាល័យវិជ្ជាសោភ័ណ។ នៅក្នុងឆ្នាំ១៩៦៦ និង១៩៦៧ អនុវិទ្យាល័យវិជ្ជាសោភ័ណត្រូវបិទទ្វារឈប់បង្រៀនដោយសារមិនមានសិស្សចូលរៀន និងការចំណាយច្រើនជាងចំណូល។ ខ្ញុំត្រូវផ្អាកការបង្រៀនមួយរយៈ ប៉ុន្តែខ្ញុំនៅតែបន្តសកម្មភាពចូលបង្កប់ខ្លួននៅក្នុងចលនាបដិវត្តន៍និងរស់នៅជាមួយអ្នកបដិវត្តន៍តាមរយៈឈ្មោះ នៅ ផន ហៅ សុក។ នៅ ផន ហៅ សុក បានខ្ទេសនាមមិត្ត ហុង ឲ្យស្គាល់ខ្ញុំ ធ្វើឲ្យខ្ញុំមានឱកាសស្និទ្ធស្នាលជាមួយអ្នកបដិវត្តន៍បន្ថែមទៀត។

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦៧ ខ្ញុំត្រូវចេញពីកំពង់ធំមកនៅភ្នំពេញដើម្បីចូលបង្កប់ខ្លួនមិនឲ្យអង្គការបដិវត្តន៍ដឹង។ ខ្ញុំទាក់ទងជាមួយ យឹម ធន គឺជាពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា។ យឹម ធន បានប្រឡងជាប់ពេទ្យនៅក្នុងឆ្នាំ១៩៦២ បន្ទាប់ពីចាកចេញពីខេត្តកំពង់ធំ។ ធន ប្រាប់ខ្ញុំថា គាត់មានមិត្តភក្តិឈ្មោះ ជាវ៉ាល់ ពាក់ស័ក្តិ២ គឺជាគិញនៅក្រសួងនគរបាលជាតិភ្នំពេញ។ យឹម ធន បានឲ្យ ជាវ៉ាល់ រកវិធីសាស្ត្រដើម្បីឲ្យអង្គការបដិវត្តន៍ជឿថា ខ្ញុំគឺជាអ្នកបដិវត្តន៍ប្រាកដមែន។ យឹម ធន បង់ឲ្យ ជាវ៉ាល់ ចេញសំបុត្រចាប់ខ្លួនគិញដែលលាក់ខ្លួននៅក្នុងក្រុង និងខេត្ត។ ជាវ៉ាល់ គិតថាត្រឹមតែចេញសំបុត្រចាប់ខ្លួនមិនជាក់ស្តែងនោះទេគាត់នឹងបញ្ជូនឲ្យគិញ ៣នាក់ទៅចាប់ខ្លួនខ្ញុំដល់ផ្ទះ។ គិញ តាមចាប់ខ្លួនខ្ញុំចំនួន ២លើកក្នុងខែកក្កដា និងខែសីហា ប៉ុន្តែចាប់ខ្ញុំមិនបានក៏ទុកសំបុត្រចាប់ខ្លួនឲ្យម្តាយក្មេកខ្ញុំ។

នៅខែកញ្ញា ឆ្នាំ១៩៦៧ អង្គការបដិវត្តន៍ ទិញម៉ាស៊ីនដេរមួយគ្រឿងឧបត្ថម្ភដល់គ្រួសារខ្ញុំ។ ខ្ញុំស្នើអង្គការឲ្យយកម៉ាស៊ីនដេរនោះយកទៅដាក់ដល់ផ្ទះប្រពន្ធរបស់ខ្ញុំនៅកំពង់ធំ។ ខ្ញុំបានទៅផ្ទះ ហើយម្តាយក្មេកយកសំបុត្រចាប់ខ្លួនមកឲ្យខ្ញុំ។ ខ្ញុំត្រឡប់មកភ្នំពេញវិញ និងយកសំបុត្រនោះឲ្យមិត្តបដិវត្តន៍មើលបន្តគ្នា។ មិត្តងា គឺជាសាស្ត្រាចារ្យអនុវិទ្យាល័យស្អាង ប្រាប់ខ្ញុំកុំឲ្យត្រឡប់ទៅផ្ទះវិញទេ គឺត្រូវភៀសខ្លួនទើបរួចផុតពីការចាប់ខ្លួន។ ខ្ញុំត្រូវរស់នៅភ្នំពេញអស់រយៈពេល៣ខែ។ នៅខែតុលា ឆ្នាំ១៩៦៧ ខ្ញុំបានទៅជួបអាចារ្យ យុត ដោយបញ្ជាក់ប្រាប់គាត់អំពីដំណើររបស់ខ្ញុំហៀបចាកចេញពីទីក្រុងភ្នំពេញទៅជនបទ។ អាចារ្យ យុត ចេញសំបុត្រខ្ទេសនាមឲ្យខ្ញុំមួយសន្លឹកសម្រាប់ទាក់ទង កុយ ធួន។ នៅចុងខែតុលា ឆ្នាំ១៩៦៧ មាននីរសារម្នាក់បាននាំខ្ញុំទៅជួប កុយ ធួន នៅភូមិមួយជិតភូមិបឹងធំ ក្នុងខេត្តកំពង់ចាម។ ខ្ញុំយកសំបុត្រខ្ទេសនាមរបស់អាចារ្យ យុត ទៅឲ្យ កុយ ធួន ហើយកុយ ធួន ទទួលស្គាល់ខ្ញុំ។ ខ្ញុំសម្រាកនៅទីនោះបានរយៈពេល២យប់ ខណៈបង កុយ ធួន ជិះទូកឡើងមកទីរួមខេត្តកំពង់ចាម សម្រាក៣យប់ ដើម្បីរង់ចាំនីរសាររបស់គាត់ដែរ។ កុយ ធួន អប់រំខ្ញុំថា នៅស្រុកលើមានការលំបាកខ្លាំងណាស់មិត្តត្រូវ

មានការតស៊ូជម្នះ ហើយត្រូវខិតខំអប់រំកម្លាំងក្បត់ឲ្យបានច្រើន។ រយៈពេល៥យប់ ទើបនីសារបានមកដល់ហើយបានណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ កង គឺជាខ្មែររបស់គាត់ ហើយ កង ក៏បាននាំខ្ញុំទៅខេត្តមណ្ឌលគិរី។ នៅខែធ្នូ ឆ្នាំ១៩៦៧ ខ្ញុំបានមកដល់ខេត្តមណ្ឌលគិរី។ យើងទៅរស់នៅផ្ទះរបស់ ពូ ផ្លី គឺជាជនជាតិព្នង ក្នុងភូមិពូគ្រេង។ នៅចុងឆ្នាំ១៩៦៨ ខ្ញុំនិងកង បានទៅរៀនវគ្គនយោបាយនៅមន្ទីរក៦០ របស់លេខាតំបន់ ឈ្មោះ ឡាំង។ ខ្ញុំបានជួប កុយ ធួន ហៅ គុន ជួយដឹកនាំការងារតំបន់១០៥ ដែលចល័តជាមួយខេត្តរតនគិរី។

នៅក្នុងឆ្នាំ១៩៦៩ កង និងខ្ញុំបានកែខ្លឹមសារឃោសនាថ្មី ទិសដៅប្រឆាំងជាមួយបដិវត្តន៍។ បដិវត្តន៍វាយមិនឈ្នះចក្រពត្តិអាមេរិក បរិវារភ្នំពេញ និងព្រៃនគរឡើយ។ យើងឃោសនាឲ្យប្រជាជនខ្លាចបដិវត្តន៍មិនហ៊ានចូលព្រៃរកត្រីសាច់ដូចមុន ព្រោះខ្លាចខ្មែរក្រហមចាប់ខ្លួន។ នៅចុងឆ្នាំ១៩៧៨ បង ឡាំង ហៅខ្ញុំទៅរៀននៅមន្ទីររបស់គាត់ ដោយមានឈ្មោះ គុណ គឺជាអ្នកឧទ្ទេសនាមឯកសារ។ អ្នកដែលចូលរៀននៅពេលនោះមានបង ឡាំង បងសូរុន បងខាំភូន និងខ្ញុំ។ បន្ទាប់ពីរៀនរួចឈ្មោះ គុណ ហៅខ្ញុំជួបដោយឡែកនិងអប់រំអំពីនយោបាយ។

នៅឆ្នាំ១៩៧០ អង្គការតំបន់១០៥ សម្រេចដកខ្ញុំចេញពីភូមិពូគ្រេងឲ្យទៅធ្វើជាលេខាស្រុកច្បារ ហើយ កង ត្រូវ គុណ ដកចេញពីតំបន់១០៥។ មុនពេលបែកគ្នា កង ធ្វើសំបុត្រឧទ្ទេសនាមឲ្យខ្ញុំទៅជួបខ្មែរក្បត់នៅស្រែធំឈ្មោះ គ្រូតុំ ដែលបង្កប់ធ្វើសកម្មភាពនៅមូលដ្ឋានស្រែធំ និងប្រគល់សមាជិកក្បត់ទាំង៤នាក់ឲ្យខ្ញុំគ្រប់គ្រង។ នៅពេលនោះខ្ញុំធ្វើជាលេខាស្រុក និងមិត្តចាំ ធ្វើជាអនុលេខា ខណៈដែលខេត្តមណ្ឌលគិរីទាំងមូលត្រូវបានរំដោះ។ ប្រជាជននៅក្នុងស្រុកច្បារ ធ្វើបដិវត្តន៍ មានជំនឿលើបដិវត្តន៍ ពួកគេមិនជឿលើការឃោសនារបស់ខ្មែរសេរីទេ លើកលែងតែពួករដ្ឋការចាស់ និងទាហានប៉ូលីស។

នៅក្នុងឆ្នាំ១៩៧១ អង្គការតំបន់ចាត់តាំងខ្ញុំទៅរៀនសាលាបក្សជាមួយ បងសូរុន បងខាំភូន និងបងឡាំង ចំនួន២៥ថ្ងៃ។ ពេលនោះខ្ញុំបានជួប ធុច ក្រោយពេលរៀនចប់ ហើយ ធុច បានអប់រំខ្ញុំបន្ថែមទៀត។



ជនជាតិភាគតិចនៅខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំត្រូវអង្គការតំបន់១០៥ សម្រេចឲ្យចុះជួយ ផ្តល់យោបល់ ទាក់ទងការងារនៅស្រុកច្បារ អូរាំង និង កែវសីមា រយៈពេល១ខែ។ ខ្ញុំចុះដល់ស្រុកកែវសីមា ជួបជាមួយ កាស៊ី គឺជាលេខស្រុកកែវសីមា បានឲ្យខ្ញុំដឹងសភាពការណ៍នៅស្រុករ៥។ ខ្ញុំបានជូនយោបល់ដល់ កាស៊ី ឲ្យបន្តសកម្មភាពក្បត់ប្រឆាំងបក្សតទៅទៀតតាមសកម្មភាពអាចធ្វើទៅបាន។

នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំជួបជាមួយមេក្រុមក្បត់គ្រប់ក្រុម និងក្តាប់សភាពការណ៍គ្រប់មូលដ្ឋាន ហើយលើក

ទិសដៅការងារក្បត់ថ្មីតាមសភាពការណ៍ជាក់ស្តែង។ ឯសភាពការណ៍រួមនៅក្នុងតំបន់គឺមានការចាត់តាំងសហករណ៍កម្រិតទាបជាបន្តបន្ទាប់ ការកើតឡើងបញ្ហាជំទាស់រវាងកម្មសិទ្ធិឯកជន និងសមូហភាព ដោយអ្នកខ្លះចង់ចូលសហករណ៍ អ្នកខ្លះមិនចង់ចូល ហើយមានអ្នកខ្លះទៀតចូលហើយសុំចេញវិញ។ ខ្ញុំបានទាក់ទងឈ្មោះ ប្រាន គឺជាគណៈស្រុក រ២។

នៅក្នុងឆ្នាំ១៩៧៥ សភាពការណ៍នៅក្នុងតំបន់១០៥ មិនមានអ្វីប្រែប្រួលខ្លាំងទេ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បដិវត្តន៍ឈ្នះទាំងស្រុកលើចក្រពត្តិអាមេរិក និងបរិវារ។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំឡើងមករៀនសាលាបក្សនៅភ្នំពេញ ហើយបានជួបជាមួយ ឃួន។ ឃួនខ្ទេសនាមខ្មែរក្បត់ឈ្មោះ យ៉ា ឲ្យខ្ញុំបានស្គាល់។

នៅក្នុងឆ្នាំ១៩៧៦ តំបន់១០៥ ត្រូវចាត់ចូលក្នុងភូមិភាគឦសាន ដោយមានឈ្មោះ យ៉ា គឺជាលេខាភូមិភាគ។ យ៉ា បានទាក់ទងជាមួយខ្ញុំ តាមការខ្ទេសនាមរបស់ ឃួន។ មុនពេលប្រជុំគណៈតំបន់ យ៉ា បានមកជួបខ្ញុំ អប់រំ និងជំរុញឲ្យកសាងកម្លាំងទាក់ទងជាមួយ ឃួន ឲ្យបានល្អ និងសម្ងាត់បំផុត។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ បងយ៉ា បានឡើងទៅតំបន់១០៥ ប្រជុំគណៈតំបន់ដោយលើកយកបញ្ហាតំបន់មកប្រជុំ រួមមាន ១) បញ្ហាព្រំដែន ២) រៀបចំបោះទីតាំងកងពល និង តំបន់ ៣) ការទាក់ទងកងពល៩២០ និងតំបន់១០៥ ៤) បញ្ហាសហការកងពល និងកងតំបន់ការពារព្រំដែនមណ្ឌលគិរី។ បញ្ហាព្រំដែន យ៉ា បានបញ្ជាក់ថា ប្រសិនបើមានយួនឈ្លានពានព្រំដែនត្រូវដោះស្រាយដោយសន្តិវិធីគឺចរចាឲ្យយួនដកចេញវិញ និងរាយការណ៍ទៅកាន់ភូមិភាគភ្លាមៗ។ បងយ៉ា មកជួបខ្ញុំដោយឡែកហើយអប់រំខ្ញុំ ពីបញ្ហាព្រំដែនកម្ពុជា និងវៀតណាម ដែលឈានចូលដល់បដិបក្ខខ្ពស់ដោះស្រាយមិនរួចឡើយ។ វៀតណាមមានផែនការនៅក្នុងរដូវប្រាំងវាយយកខេត្តមណ្ឌលគិរី តាមប្រភពព័ត៌មានផ្លូវការសម្ងាត់ពីឈ្មោះ គី សឺន ភាគទី៥វៀតណាម។ នៅខែមេសា ឆ្នាំ១៩៧៦ យ៉ា បានឡើងទៅតំបន់១០៥ ប្រជុំគណៈតំបន់និងគណៈស្រុកដោយនាំលេខា និងអនុលេខាតំបន់មាន បងឡាំង ទទួលខាងយោធា, បង សួរុន គឺជាលេខាស្រុក រ៣, បងខាំភូន ខាងសេដ្ឋកិច្ច, ខ្ញុំ សង្គមកិច្ចសុខាភិបាល, មិត្តសូភា យោធា, មិត្ត ចាំ វប្បធម៌ (គឺជាលេខាស្រុក រ២)។ ចំណែកគណៈស្រុកមាន មិត្ត ស្វាយ លេខាស្រុក រ១, មិត្តរ៉ា អនុលេខា, បងឡោក អនុលេខាស្រុក រ២, បងផាក់ អនុលេខាស្រុក រ៣, បងគី លេខាស្រុក រ៤, មិត្តខឿន អនុលេខាស្រុក រ៤, កាស៊ី លេខាស្រុក រ៥ និង ចាន់ដើរ អនុលេខា។

នៅខែមករា ឆ្នាំ១៩៧៧ គណៈតំបន់បានសម្រេចធ្វើសន្និបាតសម្រេចដកការងារពី គណៈ ទាក់ទងបរទេស, ដកភូមិស្រែសង្គមឲ្យទៅស្រុក រ៤។ សកម្មភាពក្នុងពេលនោះគឺមិនអនុវត្តភារកិច្ចដែលបក្សប្រគល់ឲ្យ មិនគោរពតាមការចាត់តាំងរបស់គណៈតំបន់ មិនចុះដឹកនាំក្នុងក្រសួងរបស់ខ្លួន ហើយពេលសន្និបាតមានទំនាស់ជាមួយលេខាតំបន់។ កាស៊ី និង ចាន់ដើរ ត្រូវសន្និបាតតំបន់ដេញចេញពីគណៈស្រុកកែវស៊ីមា ឲ្យរស់នៅក្នុងមន្ទីរសេដ្ឋកិច្ចតំបន់ ក-១៦។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ យើងយោសនាបំផុសទំនាស់នៅក្នុងសហគមន៍ ចលនាប្រជាជនឲ្យទាមទារពីសមូហភាព ដោះស្រាយការរស់នៅប្រចាំថ្ងៃ ដូចជាការស៊ីចុក ស្លៀកពាក់ប្រចាំថ្ងៃ និងថ្នាំស្កូវ។ បន្ទាប់ពីនេះខ្ញុំបានកែប្រែខ្លឹមសារយោសនាខ្លះឲ្យស្របតាមសភាពការណ៍ថ្មី និងខំប្រឹងធ្វើសកម្មភាពក្បត់បន្តរហូតដល់ថ្ងៃទី២៨ ខែមីនា ខ្ញុំត្រូវបក្សចាប់ខ្លួនតែម្តង។

**កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00878។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ សូ គឹមអាន ហៅ អាចារ្យម៉ី ពិតឬយ៉ាងណានោះទេ?**

# គណៈប្រតិភូកងពលតូចថ្មើរជើងលេខ៨១ ទស្សនកិច្ចសិក្សាបណ្ណាល័យសម្តេចម៉ែ

សួត វិចិត្រ



គណៈប្រតិភូក្រសួងការពារជាតិនិងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។
(សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



វរសេនីយ៍ឯក ឯម វាសនា ដែលជាមេបញ្ជាការរង និងជាប្រធានក្រុមការងារប្រវត្តិសាស្ត្ររបស់កងពលតូចថ្មើរជើងលេខ៨១។
(សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បណ្ណាល័យសម្តេចម៉ែ បានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូនៃកងពលតូចថ្មើរជើងលេខ៨១ ដែលមានមូលដ្ឋាននៅក្នុងស្រុកអន្លង់វែង ដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍ដោយផ្ទាល់ស្តីពីការរៀបចំនិងចងក្រងឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងបណ្តាឯកសារសិក្សាស្រាវជ្រាវដទៃទៀត។

ក្នុងនាមជាអ្នកតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧត្តមសេនីយ៍ នាង ឃឹម មេបញ្ជាការកងពលតូចថ្មើរជើងលេខ៨១ វរសេនីយ៍ឯក ឯម វាសនា ដែលជាមេបញ្ជាការរង និងជាប្រធានក្រុមការងារប្រវត្តិ-សាស្ត្ររបស់កងពលតូចបានពិនិត្យមើលពីការដាក់តាំងបង្ហាញសៀវភៅ និងឯកសារ ព្រមទាំងការរក្សាទុកឯកសារនៅក្នុងប្រព័ន្ធអេឡិចត្រូនិច ដែលជួយ

សម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងសាធារណជនជាតិអន្តរជាតិ។

លោកវរសេនីយ៍ឯក បានថ្លែងកោតសរសើរ និងស្នើកិច្ចសហការពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំបណ្ណាល័យរបស់កងពលតូចថ្មើរជើងលេខ៤១ ដើម្បីបម្រើដល់ការសិក្សារៀនសូត្ររបស់សិស្ស និស្សិត សាធារណជនទូទៅ និងកងទ័ព។ បណ្ណាល័យកងពលតូចថ្មើរជើងលេខ៤១នេះ ក៏អាចចូលរួមចំណែកដល់ការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រយោធាដែរ។ «ប្រវត្តិសាស្ត្រយោធាត្រូវបានពិពណ៌នាថា គឺជាការសិក្សាស្រាវជ្រាវអំពីសង្គ្រាម និងការវិភាគអំពីជ័យជម្នះ និងបរាជ័យ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិសាស្ត្រយោធារួមបញ្ចូលនូវធាតុផ្សំជាច្រើនដទៃទៀតលើសពីនេះ។ ប្រវត្តិសាស្ត្រយោធាក្តោបនូវប្រធានបទជាច្រើនដែលរួមមានវឌ្ឍនភាព និងបរាជ័យនៃរបបនីមួយៗរហូតដល់ការវិវត្តរបស់ប្រទេសជាតិនានា ព្រមទាំងសកម្មភាពដែលមនុស្សជាតិ សាងកំហុសដដែលៗ ឬបានរៀនសូត្រពីកំហុសរបស់ខ្លួន។ ប្រវត្តិសាស្ត្រកម្ពុជា ពោរពេញទៅដោយមេរៀនឥតមានពីរសម្រាប់ប្រទេសរបស់ខ្លួន តំបន់ និងពិភពលោក»។

បន្ទាប់ពីដំណើរទស្សនកិច្ចនេះ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបញ្ជាក់ពីកិច្ចសហការរៀបចំបណ្ណាល័យកងពលតូចថ្មើរជើងលេខ៤១ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជូនដល់ប្រតិភូនូវសៀវភៅចំនួន៥ពាន់ក្បាល និងទូរដាក់សៀវភៅមួយចំនួនទៀតផង។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងបង្ហាញផែនទីទៅកាន់គណៈប្រតិភូ។
(សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើបទបង្ហាញទៅកាន់គណៈប្រតិភូ។
(សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលស្វាគមន៍គណៈប្រតិភូកងពលតូចថ្មើរជើងលេខ៤១។
(សុភ័ក្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី

ផេង ពង្សរ៉ាស៊ី



ទេសភាពផ្ទៃទឹកនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី ស្ថិតនៅភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី៖** ជារមណីយដ្ឋានសត្វស្លាបធម្មជាតិដ៏កម្រមួយមានទំហំ ៨៦ហិកតា ដែលមានប្រភេទសត្វស្លាបជិតផុតពូជ និងទទួលរងការគំរាមកំហែងជាច្រើនប្រភេទកំពុងរស់នៅរាប់ម៉ឺនក្បាល ដូចជាស្មោញ ទង់ប្រផេះ ប្រភេទសត្វត្រយ៉ង ត្រដក់ នទៀល ខ្សឹង កុក ខ្វែក ក្អែកទឹក ទង់ ក្រសា និងសត្វស្លាបប្រមាណជិត៥០ប្រភេទផ្សេងៗទៀត។ រមណីយដ្ឋាននេះ ស្ថិតនៅភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង មានចម្ងាយប្រមាណ៨០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ និងប្រមាណ ១៥ គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។

ស្ថិតនៅចំកណ្តាលផ្ទៃទឹកដ៏ធំល្វឹងល្វើយ រមណីយដ្ឋាននេះអាចទទួលភ្ញៀវទេសចរណ៍បានគ្រប់រដូវ។ នៅរដូវប្រាំង ភ្ញៀវទេសចរណ៍នានាអាចធ្វើដំណើរដោយខ្លួនឯងតាមរថយន្ត ទោចក្រយានយន្ត និងថ្មើរជើងទៅកាន់ទីតាំងនេះ។ ចំណែកនៅរដូវវស្សាវិញ ភ្ញៀវទេសចរណ៍អាចធ្វើដំណើរតាមទូក និងកាណូត



មានសត្វស្លាបរាប់ម៉ឺនក្បាលប្រមាណ៥០ប្រភេទ រស់នៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

តែប្រមាណពីរគីឡូម៉ែត្រពីភូមិអ្នកស្រុក ទៅកាន់ទីទួលដើម្បីទស្សនាហ្វូងសត្វស្លាប និងព្រៃឈើដែលដុះប្រជ្រៀតគ្នានៅលើទីទួលព័ន្ធតាឡី។ តាមការឲ្យដឹងពីប្រជាជនរស់នៅជុំវិញបរិវេណទីទួលនេះថា ហ្វូងសត្វស្លាបទាំងអស់ លើកលែងតែសត្វក្រាបពង បានចាកចេញពីសំបុក និងទីទួលព័ន្ធតាឡីនៅវេលាព្រឹក ដើម្បីចេញទៅរកស៊ីនៅកន្លែងឆ្ងាយៗពីទួល ហើយបានវិលត្រឡប់មកវិញនៅវេលាល្ងាចចាប់ពីម៉ោង៥រហូតដល់ពេលជិតយប់ងងឹត។ ភ្ញៀវទេសចរណ៍នានាច្រើននាំគ្នាទៅទស្សនាហ្វូងសត្វស្លាបទាំងនេះ ចាប់ពីវេលាម៉ោងបី ឬម៉ោងបួនតទៅ ដើម្បីបានមើលឃើញដំណើរវិលត្រឡប់របស់ហ្វូងសត្វស្លាប។

នៅជុំវិញទីទួលព័ន្ធតាឡី យើងសង្កេតឃើញមានរោងធ្វើពីឈើគ្មានដំបូល ឬមានដំបូលធ្លុះធ្លាយចំនួនបួនប្រាំ និងរោងធ្វើអំពីថ្មចំនួនមួយ ត្រូវបានសាងសង់ឡើងនៅជុំវិញបរិវេណព្រៃព័ន្ធតាឡី ដើម្បីធ្វើជាកន្លែងទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ទាំងឡាយដែលមកទស្សនានៅទីនេះ។ ក្រុមការងារយើងបានទៅកាន់រោងធ្វើពីឈើចាស់ទ្រុឌទ្រោមមួយស្ថិតនៅភាគខាងកើតទីទួល និងបានឡើងលើរោងនោះដើម្បីទស្សនាហ្វូងសត្វស្លាបឲ្យបានជិតបន្តិច។ នៅលើរោងដំបូលធ្លុះធ្លាយនេះ យើងពុំសូវចាប់អារម្មណ៍ខ្លាំងឡើយពីសុវត្ថិភាពផ្ទាល់ខ្លួន ប៉ុន្តែយើងបែរជាចាប់អារម្មណ៍ខ្លាំងបំផុតពីទេសភាពផ្ទៃទឹកមើលពីលើ និងទិដ្ឋភាពហ្វូងសត្វស្លាបដែលហើរឆ្វែលចុះឆ្វែលឡើងនៅជុំវិញខ្លួន។ ម្នាក់ៗបានទាញទូរសព្ទដៃមកផ្តិតយករូបភាពជដែកគ្នា ថតគ្នាទៅវិញទៅមក និងទស្សនាទេសភាពកណ្តាលផ្ទៃទឹក និងអ្វីៗដែលអាចមើលឃើញនៅជុំវិញខ្លួនជាពិសេសទិដ្ឋភាពព្រះអាទិត្យហៀបនឹងអស្តង្គត បញ្ចេញពណ៌ក្រហមព្រឿងៗ លម្អដោយហ្វូងសត្វស្លាបហើរឆ្វែលចុះឡើងៗពីដើមឈើមួយទៅដើមឈើមួយ។

ទីតាំងរមណីយដ្ឋានទួលព័ន្ធតាឡី ទទួលបានការ

ចាប់អារម្មណ៍ខ្លាំងពីអ្នកទស្សនានៅឆ្នាំ២០១៩ និង២០២០ បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តមួយត្រូវបានរៀបចំធ្វើឡើងនៅចុងឆ្នាំ២០១៩ ដើម្បីពិភាក្សាពីការដាក់បញ្ចូលតំបន់នេះ ឬដែលអ្នកស្រុកនិយមហៅថា ទីតាំង «ដីសើមបឹងស្នេហ៍» ទៅជាតំបន់ការពារធនធានធម្មជាតិ។ ដីសើមបឹងស្នេហ៍ជាទីតាំងដីព្រៃលិចទឹកមួយកន្លែងដែលធ្លាប់ទទួលបានជំនួយក្នុងការបង្កាត់ពូជ និងអភិរក្សសត្វស្លាប ព្រមទាំងធនធានធម្មជាតិ កាលពីប៉ុន្មានឆ្នាំមុនៗ ប្រាក់ ផល្លី ជាអ្នកអភិរក្សសត្វស្លាបនៅរមណីយដ្ឋានទួលព័ន្ធតាឡី ឬដីសើមបឹងស្នេហ៍បានឲ្យដឹងថា ហ្វូងសត្វស្លាបទាំងអស់បានមកស្នាក់នៅបណ្តោះអាសន្ននៅលើទីទួលនេះ តែក្នុងរដូវវស្សា ឬរដូវទឹកឡើងប៉ុណ្ណោះនៅមុនឆ្នាំ២០១៨។ លុះចាប់តាំងពីឆ្នាំ២០១៩មក ការតាំងទីលំនៅនៃសត្វទាំងនេះ គឺលែងមានការផ្លាស់ទីទៀតហើយ។ «នៅឆ្នាំ២០១៧-២០១៨ សត្វទាំងអស់នេះគឺជាសត្វរដូវកាល។ ដល់ពេលខែទឹកឡើងបានគេ (សត្វ) មក ហើយដល់ខែទឹកសម្រក គេទៅវិញបាត់។ តែចាប់ផ្តើមពីឆ្នាំ២០១៨-២០១៩ ហើយជាពិសេសនៅដើមឆ្នាំ២០២០ គឺគេចាប់ផ្តើមបោះទីតាំងនៅជាអចិន្ត្រៃយ៍តែម្តង។»


ទេសភាពថ្ងៃហៀបនឹងលិចនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


ភ្ញៀវទេសចរណ៍ជិះទូកកម្សាន្តនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពាក់កណ្តាលឆ្នាំ២០២១កន្លងទៅនេះ សត្វស្លាបរាប់ពាន់ក្បាលបានងាប់ជាបន្តបន្ទាប់។ ម្ចាស់ទូកចម្លង (មិនស្គាល់ឈ្មោះ) ម្នាក់បានប្រាប់ថា មូលហេតុដែលនាំឲ្យសត្វស្លាបទាំងនោះងាប់ គឺដោយសារក្តៅខ្លាំង និងចំហាយអាចម៍សត្វទាំងនោះជះខ្លាំងពេកដែលធ្វើឲ្យសត្វទាំងនោះពិបាកដកដង្ហើម។ តាមការឲ្យដឹងពីម្ចាស់ទូកចម្លងដដែលថា នៅចុងខែមករា ឆ្នាំ២០២២នេះ កំណើតសត្វស្លាបទាំងនេះបានកើនឡើងច្រើនដូចមុន ហើយនឹងអាចច្រើនជាងមុនក្នុងពេលដ៏ខ្លី ព្រោះថាសត្វទាំងនោះកំពុងក្រាបពង ស្របពេលដែលទឹកដែលព័ទ្ធជុំវិញទីទួលនេះនៅមិនទាន់ស្រកអស់នៅឡើយ។

នៅតាមវាលស្រែប្របសងខាងផ្លូវជាតិនានានៃខេត្តព្រៃវែងដែលយើងបានធ្វើដំណើរ យើងតែងក្រឡេកមើលឃើញហ្វូងសត្វស្លាបជាច្រើនប្រភេទហើរ និងស្វែងរកស៊ីចំណីទាំងនៅតាមវាលស្រែដែលទើបនឹងភ្ជួររាស់ ទាំងវាលស្រែដែលទើបនឹងស្ទូងរួច និងតាមវាលស្រែដែលហៀបនឹងទទួលបានផលរបស់អ្នកស្រុក។ នៅពេលដែលយើងធ្វើដំណើរវិលត្រឡប់មកពីប្រកបការងារវិញនៅម៉ោងប្រមាណជាង ៥រសៀល យើងសង្កេតឃើញសត្វស្លាបទាំងហ្វូងៗ ហើរសំដៅទៅកាន់ទីជម្រកនៅទីទួលព័ន្ធតាឡី ឬតំបន់ដីសើមបឹងស្នេហ៍។

# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

***សួគ វិចិត្រ, មេក ទិន និង ហ៊ាន ពិសី***

ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសាររយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីស្តាប់រឿងរ៉ាវជីវិតរបស់គាត់ដែលបានឆ្លងរបបខ្មែរក្រហម។ ខាងក្រោម គឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៖

## ប៊ុន ច័ន្ទ

ប៊ុន ច័ន្ទ ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិព្នង មានទីកន្លែងកំណើតនៅភូមិ កោះម៉ាយើល ឃុំជីមៀត (បច្ចុប្បន្ន ឃុំណងខីឡឹក) ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ច័ន្ទបច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ច័ន្ទបានចែករំលែករឿងរ៉ាវរបស់គាត់ថា ខ្ញុំមានបងប្អូនចំនួនពីរនាក់។ ខ្ញុំគឺជាកូនទីពីរនៅក្នុងគ្រួសារ ដែលមានឪពុកគឺជាជនជាតិរដែ និងម្តាយគឺជាជនជាតិព្នង។ កាលពីកុមារ ខ្ញុំមិនបានរៀនសូត្រនៅសាលាទេ ប៉ុន្តែខ្ញុំមានបងបង្រៀននៅផ្ទះ រហូតខ្ញុំអាចអានអក្សរ និងសរសេរអក្សរបាន។ ខ្ញុំនៅចាំថា មានការទម្លាក់គ្រាប់បែកជារៀងរាល់ថ្ងៃនៅស្រុកកោះញែក ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិផ្ទះសម្បែង, ងាប់គោ, ក្របី, មាន់, ទា ជាពិសេសប្រជាជនត្រូវបាត់បង់ជីវិតស្ទើតែរាល់ថ្ងៃ។ លុះឆ្នាំ១៩៧២ ខ្ញុំបានចាកចេញពីគ្រួសារនៅអាយុ១២ឆ្នាំ។ នៅពេលនោះខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើការនៅក្នុងមន្ទីរកុមារ។ កិច្ចការងារដែលខ្ញុំត្រូវធ្វើនៅពេលនោះ រួមមាន ស្រោចស្តែ, ត្រកួន, ដឹកទឹក និងជញ្ជូនខស។ កាលនោះដោយសារខ្ញុំមានចំណេះដឹងគ្រាន់បើជាងក្មេងដទៃ ខ្ញុំក៏ត្រូវបានចាត់ឲ្យធ្វើជាគ្រូបង្រៀនអក្សរដល់ក្មេងដទៃទៀតនៅក្នុងមន្ទីរ បន្ទាប់ពីទំនេរពីការងារ។ លុះនៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ មន្ទីរកុមារក៏ត្រូវបានរំសាយ។ ខ្មែរក្រហមកចាប់ផ្តើមបែងចែកកុមារទៅតាមមុខជំនាញ ខ្លះទៅខាងពេទ្យ ខ្លះខាងបើកបរ ខ្លះទៀតខាងរោងចក្រ និងមុខជំនាញផ្សេងៗជាច្រើនទៀត។ ដោយឡែកខ្ញុំមានចំណេះដឹងគ្រាន់បើជាងកុមារដទៃ ក៏ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យមកធ្វើការខាងកាន់បញ្ជីនិងស្រង់ស្ថិតិនៅក្នុងកងកុមារ។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនមកកាន់ដាក់ដាំ ខេត្តមណ្ឌលគិរី ជាប់ព្រំដែនវៀតណាម។ នៅទីនោះខ្ញុំធ្វើជានីរសារ



ប៊ុន ច័ន្ទ ទទួលកញ្ចប់អនុស្សាវរីយ៍ពី ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (សួគ វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់ ប៊ុនរៀម ដែលជាប្រធានកងវរសេនាតូចៗ ខ្ញុំរស់នៅដាក់ដាំបានរយៈពេលមួយឆ្នាំ ទើបខ្មែរក្រហមបញ្ជូនមកស្រុកពេជ្រាដាវិញដោយបំពេញការងារជានីរសារដដែលៗ រហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានរត់ភៀសខ្លួនចូលទៅរស់នៅក្នុងព្រៃខេត្តមណ្ឌលគិរីៗ ពេលនោះ ខ្ញុំចិញ្ចឹមជីវិតដោយជីកមើមក្ដួច និងមើមដំឡូងហូប ព្រោះខ្ញុំគ្មានស្បៀងឡើយៗ នៅឆ្នាំ១៩៨០ ខ្ញុំបានរៀបការៗ លុះឆ្នាំ១៩៨២ ទើបប៊ុនរៀម ប្រធានកងវរសេនាតូចដឹកនាំកម្លាំងទាំងអស់របស់ខ្លួនធ្វើដំណើរមកកាន់ព្រំដែនថៃៗ ដូច្នេះខ្ញុំនៅកងវរសេនាតូចតស៊ូជាមួយប៊ុនរៀមរហូតខ្ញុំផ្លាស់មកនៅក្នុងភូមិ១០៥នេះ ដែលជាឈ្មោះដាក់តាមលេខអគ្គភាពជាប់រហូតមកសព្វថ្ងៃនេះៗ



សែ ខាំអាន ទទួលកញ្ចប់អនុស្សាវរីយ៍ពី សួត វិចិត្រ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្ទង់វែងៗ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## សែ ខាំអាន

សែ ខាំអាន ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិលាវ មានទីកន្លែងកំណើតនៅភូមិកោះម៉ាយើល ឃុំណងធឺ ឡឹក ស្រុកកោះញែកខេត្តមណ្ឌលគិរីៗ បច្ចុប្បន្នខាំអានរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យៗ ខាំអានបានរៀបរាប់ថា កាលពីកុមារខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ សង្គមចាស់ ដូច្នេះខ្ញុំអាចសរសេរ និងអានអក្សរបានតិចតួចប៉ុណ្ណោះៗ បន្ទាប់មកនៅឆ្នាំ១៩៦៧ ខ្ញុំបានចូលតស៊ូនៅក្នុងព្រៃ ប៉ុន្តែកាលនោះ ខ្ញុំនិងប្រជាជនចេញតស៊ូតាមគ្នាដោយមិនដឹងថា នរណាអ្នកដឹកនាំឡើយៗ យើងនៅតស៊ូនិងធ្វើខ្ទមតូចៗសម្រាប់ស្នាក់ជាបណ្ដោះអាសន្នៗ បន្ទាប់មកខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាគ្រូបង្រៀនអក្សរដល់ក្មេងៗ ដែលរត់ភៀសខ្លួនចូលទៅនៅក្នុងព្រៃដែរដើម្បីឲ្យក្មេងៗទាំងនោះចេះអក្សរខ្មែរៗ មកដល់ឆ្នាំ ១៩៧០ ក៏មានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ទើបខ្ញុំនិងអ្នកភូមិផ្សេងទៀតត្រឡប់មករស់នៅភូមិវិញៗ ប៉ុន្តែយើងរស់នៅ និងរកស៊ីដោយលួចលាក់ៗ យើងលាក់ខ្លួនតែនៅក្នុងលេណដ្ឋានតែប៉ុណ្ណោះ ព្រោះពេលថ្ងៃមានយន្តហោះទម្លាក់គ្រាប់បែកៗ លុះដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមវាយរំដោះបានភ្នំពេញ ទើបប្រជាជនលែងភ័យព្រួយពីការទម្លាក់គ្រាប់បែកទៀតៗ ប៉ុន្តែយើងត្រូវបានខ្មែរក្រហមដាក់ឲ្យរស់នៅក្នុងសហករណ៍ និងធ្វើការរួមគ្នាៗ យើងត្រូវបានដាក់ឲ្យហូបរួមគ្នានៅក្នុងរោងបាយសហករណ៍ ដែលមានរបបបីពេលក្នុងមួយថ្ងៃៗ ចំណែកការងារ ខ្មែរក្រហមចាត់តាំងប្រជាជនឲ្យលើកទំនប់, វែកដី និងជីកប្រឡាយៗ នៅសម័យនោះ យើងគ្មានសិទ្ធិសូម្បីតែនិយាយស្ដី ហើយប្រសិនបើហ៊ានប្រព្រឹត្តខុសវិន័យច្បាស់ជាត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលជាមិនខានៗ ចំណែកប្រធានសហករណ៍មានតែអ្នកមកពីស្រុកក្រៅ ឬប្រជាជនខ្មែរតែប៉ុណ្ណោះ ដែលជាអ្នកគ្រប់គ្រងៗ រីឯជនជាតិភាគតិចនោះមិនសូវមានឡើយៗ ជំនាន់នោះ នរណាប្រព្រឹត្តខុស ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលដោយពុំចាំបាច់មានតុលាការកាត់ទោសឡើយៗ បច្ចុប្បន្នប្រទេសមានសន្តិភាព ដូច្នេះខ្ញុំសប្បាយចិត្តណាស់ ហើយខ្ញុំក៏មិនចង់បានអ្វីទៀតដែរៗ

## នោ រ៉ាមើស

នោ រ៉ាមើស ភេទប្រុស អាយុ៧០ឆ្នាំ កើតនៅក្នុងឃុំអូររាំង ស្រុកអូររាំង ខេត្តមណ្ឌលគិរីៗ សព្វថ្ងៃ រ៉ាមើស រស់នៅក្នុងភូមិថ្មល់កែង ឃុំផ្អាវ ស្រុកត្រពាំង



នោ រ៉ាមើស ភេទប្រុស អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែង ឃុំផ្សារ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រាសាទ ខេត្តឧត្តរមានជ័យ។ រ៉ាមើល និយាយរៀបរាប់អំពីបទពិសោធន៍តស៊ូរបស់ខ្លួនក្នុងសម័យខ្មែរក្រហមថា កាលពីកុមារភាពខ្ញុំរៀនសូត្របានថ្នាក់ទី៩ពីសង្គមចាស់។ គ្រួសាររបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ឪពុករបស់ខ្ញុំគឺជាជនជាតិព្នង ចំណែកម្តាយគឺជាជនជាតិខ្មែរ។ នៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀនដោយសារមានការទម្លាក់គ្រាប់បែក។ ប្រជាជនដែលរស់នៅក្នុងភូមិបាននាំគ្នាជីកលេណដ្ឋានក្បែរៗផ្ទះ ដើម្បីលាក់ខ្លួនពីការទម្លាក់គ្រាប់បែក។ កាលណោះ គ្រួសារមីងបង្កើតរបស់ខ្ញុំមួយគ្រួសារបានស្លាប់ដោយសារគ្រាប់បែកធ្លាក់ចំផ្ទះរបស់គាត់។ បន្ទាប់មក នៅក្នុងស្រុកអូររាំងក៏មានការកេណ្ឌប្រជាជនឲ្យចូលព្រៃធ្វើជាយោធាខ្មែរក្រហម។ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ។ នៅក្នុងឆ្នាំ១៩៧៣ ឪពុកម្តាយខ្ញុំបានស្លាប់ចោលខ្ញុំនិងប្អូនៗ។ ខ្ញុំទៅរស់នៅជាមួយមីងរបស់ខ្ញុំរហូតដល់ឆ្នាំ១៩៧៦ ទើបខ្ញុំចូលធ្វើការខាងបើករថយន្តនៅអង្គភាពដឹកជញ្ជូនជើងគោក។ កាលណោះ ខ្ញុំនៅអង្គភាពពាណិជ្ជកម្ម ក្រោមការមើលខុសត្រូវរបស់ តាសៀង នៅទីក្រុងភ្នំពេញ។ នៅពេលដែលខ្ញុំបានធ្វើដំណើរទៅដល់ទីក្រុងភ្នំពេញ ខ្ញុំសង្កេតឃើញថា មិនមានប្រជាជនរស់នៅទេ គឺមានតែអ្នកធ្វើការនៅរោងចក្រ និងកងទ័ពនៅយាមល្បាតតាមផ្លូវ។ កាល

នោះ ទីកន្លែងធ្វើការ និងស្នាក់នៅរបស់ខ្ញុំគឺនៅជិតស្ពានជ្រោយចង្វារ។ នៅពេលដែលតំបន់នីមួយៗស្នើសុំក្រណាត់ប្រុសម្លៀកបំពាក់ ខ្ញុំត្រូវដឹកក្រណាត់យកទៅឲ្យតំបន់ទាំងនោះឲ្យគ្រប់ចំនួន។ ពេលខ្ញុំធ្វើដំណើរនៅតាមដងផ្លូវ ខ្ញុំឃើញប្រជាជនកំពុងច្រូតកាត់ និងលើកទំនប់។ ខ្ញុំសម្លឹងមើលទៅឃើញទឹកមុខប្រជាជនសោកសៅ និងស្គមស្គាំង ហត់ៗ។ ចំណែកឯការធ្វើដំណើររបស់ក្រុមដឹកជញ្ជូនរបស់ខ្ញុំមិនសូវជួបការលំបាកទេ។ ប៉ុន្តែមានថ្ងៃមួយ ពេលក្រុមរបស់ខ្ញុំដឹកជញ្ជូនក្រណាត់ទៅ អូរជ្រៅ ក្នុងភូមិភាគពាយ័ព្យក៏មានភាពអសន្តិសុខខ្លះព្រោះនៅទីនោះមានកងកម្លាំងខ្មែរស ឡាវ និងថៃស នៅទីនោះ ប៉ុន្តែមានថៃក្រហមជាអ្នកយាមការពារផ្លូវឲ្យក្រុមដឹកជញ្ជូនរបស់ខ្ញុំមិនឲ្យមានការវាយប្រហារឡើយ។ នៅពេលដែលទំនេរពីការងារ ខ្ញុំអាចទៅលេងបាល់ទាត់ និងបាល់ទះបានព្រោះខ្មែរក្រហមមិនប្រើឲ្យយើងធ្វើការងារបន្តទេ។ ចំពោះការហូបចុកក្រុមដឹកជញ្ជូនរបស់ខ្ញុំទទួលបានអាហារហូបចុកគ្រប់គ្រាន់ ប៉ុន្តែប្រជាជនដែលរស់នៅនិងធ្វើការក្នុងសហករណ៍ហូបមិនគ្រប់គ្រាន់ឡើយ។ ខ្ញុំធ្វើការក្នុងអង្គភាពដឹកជញ្ជូនរហូតដល់កងទ័ពវៀតណាមវាយចូលមកដល់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៩។ បន្ទាប់មកខ្ញុំរួមទាំងកងទ័ពនិងប្រជាជនបានប្រមូលសម្ភារដាក់ ឡានធ្វើដំណើរមកកាន់ខេត្តកំពង់ចាម។ ពេលមកដល់ខេត្តកំពង់ចាម ខ្ញុំទុករថយន្តចោលរួចនាំគ្នាចុះដើរឆ្ពោះទៅកាន់ភ្នំដងរែក។ យើងធ្វើដំណើរអស់រយៈពេល១ឆ្នាំទើបទៅដល់តំបន់ម៉ុំបីព្រំដែនខ្មែរ, ថៃ និង ឡាវ។ បន្ទាប់មក ខ្ញុំបានចូលធ្វើជាកងទ័ពចេញទៅវាយនៅសមរភូមិខាងស្រុកក្រឡាញ់, ខេត្តកំពង់ធំ និងផ្លូវជាតិលេខ៦លេខ៧។ កាលនោះខ្ញុំនៅកងពលលេខ១០៥ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាសារុន និង តាអនស៊ឹម។ នៅក្នុងឆ្នាំ១៩៨៨ ខ្ញុំបានផ្លាស់មករស់នៅអន្លង់វែង ដោយស្នាក់នៅក្បែរស្ពានអូរជីក។ ប៉ុន្តែដោយសារតែនៅអូរជីកទឹកលិចខ្ញុំរួមទាំងប្រជាជនផ្លាស់មករស់នៅក្នុងភូមិ១០៥

ដែលបច្ចុប្បន្ន ភូមិថ្នល់កែងនេះរហូតមកៗ

---

## ឌី ប៊ុនសុំ

ឌី ប៊ុនសុំ ភេទប្រុស អាយុ៧០ឆ្នាំ កើតនៅក្នុងភូមិដីមៀត ឃុំដីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរីៗ សព្វថ្ងៃ ប៊ុនសុំ រស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យៗ ប៊ុនសុំ បាននិយាយរៀបរាប់អំពីបទពិសោធន៍តស៊ូរបស់ខ្លួនក្នុងសម័យខ្មែរក្រហមថា កាលពីកុមារភាពខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ពីសង្គមចាស់ ក៏ឈប់រៀនដោយសារមានសង្គ្រាមនៅក្នុងប្រទេសៗ ខ្ញុំមានបងប្អូនបង្កើតចំនួន ៧ នាក់ ហើយខ្ញុំគឺជាកូនពៅនៅក្នុងគ្រួសារៗឪពុកម្ដាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការដើម្បីទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃៗ នៅក្នុងឆ្នាំ១៩៦៨ ប្រជាជនរស់នៅក្នុងស្រុកកោះញ៉ែកបាននាំគ្នារត់ទៅរស់នៅក្នុងព្រៃជាប់ព្រំដែនវៀតណាមៗ នៅឆ្នាំ១៩៧០ ប្រជាជនបាននាំគ្នាចេញពីព្រៃមករស់នៅក្នុងភូមិរបស់ខ្លួនរៀងៗខ្លួនវិញៗ នៅពេលដែលខ្ញុំត្រឡប់មកដល់ភូមិវិញ ខ្ញុំឃើញផ្ទះប្រជាជនមួយចំនួនធំ ត្រូវបានដុតបំផ្លាញចោលៗ នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ ការរស់នៅក្នុងស្រុកកោះញែកបានផ្លាស់ប្ដូរទាំងស្រុងៗ ប្រជាជនទាំងអស់ត្រូវបានខ្មែរក្រហម



ឌី ប៊ុនសុំ ភេទប្រុស អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យៗ (ហ៊ាន ពិសី /មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រមូលចូលជាសហករណ៍ហូបបាយរួម និងធ្វើការងាររួមៗ ការរស់នៅក្នុងសហករណ៍ ខ្ញុំរួមទាំងប្រជាជនមានការលំបាកណាស់ៗ ជួនកាលខ្ញុំធ្វើការទាំងយប់ ចំណែកឯអាហារក៏ហូបមិនបានគ្រប់គ្រាន់ៗ ខ្ញុំរស់នៅនិងធ្វើការក្នុងសហករណ៍រហូតដល់ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញៗ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅនៅខាងពាណិជ្ជកម្ម ដោយបើករថយន្តដឹកក្រណាត់ និងសម្លៀកបំពាក់ទៅចែកតាមតំបន់នីមួយៗៗ នៅពេលនោះការហូបចុករបស់ខ្ញុំមិនមានការខ្វះខាតឡើយៗ បន្ទាប់ពីខ្ញុំដឹកជញ្ជូនក្រណាត់រួចរាល់ និងមានពេលទំនេរ ខ្ញុំបើករថយន្ត ប៊ុដិះកង់ដើរលេងនៅមុខវាំង ទៅទួលគោកពោធិ៍ចិនតុង និងចោមចៅៗ ខ្ញុំរស់នៅក្នុងមន្ទីរពាណិជ្ជកម្ម និងដឹកក្រណាត់រហូតដល់កងទ័ពវៀតណាមវាយចូលមកដល់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៩ៗ ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់បានរត់ភៀសខ្លួនទៅកាន់ភ្នំដងរែកតាមបណ្ដោយព្រំដែនថៃៗ ខ្ញុំធ្វើដំណើរអស់រយៈពេលកន្លះខែ ទើបទៅដល់ច្រក១០០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេនៗ បន្ទាប់ពីមកដល់ច្រក១០០១ ខ្ញុំធ្វើការនៅអង្គភាពបិតចម្រូងរហូតដល់ឆ្នាំ១៩៨៥ ទើបកងទ័ពវៀតណាមវាយចូលមកដល់ៗ ខ្ញុំនិងប្រជាជនដែលរស់នៅទីនោះបាននាំគ្នារត់មកកាន់តំបន់១០០៣វិញ ដែលគ្រប់គ្រងដោយ តាម៉ុកៗ នៅក្នុងឆ្នាំ១៩៩០ តាម៉ុក បានឲ្យប្រជាជនដែលរស់នៅលើភ្នំដងរែកចុះមករស់នៅក្នុងស្រុកអន្លង់វែងៗ

---

## ឈន សាអ៊ុន

ឈន សាអ៊ុន ភេទប្រុស អាយុ៧០ឆ្នាំ កើតនៅឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមៗ សព្វថ្ងៃ សាអ៊ុន រស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យៗ សាអ៊ុនបាននិយាយថា នៅឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ពេលនោះខ្ញុំឃើញមានឧទ្ធម្ភាគចក្រអាមេរិកជាច្រើនគ្រឿង



ឈន សាអ៊ិន ភេទប្រុស អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាំទម្លាក់គ្រាប់នៅរកាខ្នុរ។ នៅឆ្នាំ១៩៧២ ខ្ញុំបានចូលតស៊ូជាមួយខ្មែរក្រហម។ ដំបូងខ្ញុំធ្វើការជាស្មៀនឃុំ ប៉ុន្តែដោយសារមិនមានការងារធ្វើខ្ញុំក៏សុំផ្លាស់ទៅនៅខាងយោធាវិញ។ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅសមរភូមិមុខនៅទួលគោក។ អស់រយៈពេលមួយយប់មួយថ្ងៃ យើងប្រយុទ្ធគ្នារហូតគ្មានពេលសម្រាកឡើយ។ ពេលនោះ កងកម្លាំងរបស់ខ្មែរក្រហមមានភាពស្វាហាប់ និងបានដឹកលេណដ្ឋានដើម្បីលាក់ខ្លួន។ កាលនោះ កងទ័ពលន់ នល់បានដឹកជញ្ជូនស្បៀង និងសម្ភារតាមទន្លេអ្នកលឿង ដូច្នេះខ្មែរក្រហមបានលួចដាក់កាំភ្លើងធំនៅតាមបណ្ដោយទន្លេអ្នកលឿង និងបានឲ្យកម្លាំងទ័ពរបស់ខ្លួននៅសមរភូមិទីក្រុងភ្នំពេញវាយសម្រុកជាមុនធ្វើឲ្យកងទ័ព លន់ នល់ នៅអ្នកលឿងចលាចលព្រោះខ្លាចខ្មែរក្រហមវាយយកភ្នំពេញបាន។ លន់ នល់ ក៏ដកកងទ័ពមួយចំនួនរបស់ខ្លួនពីទន្លេអ្នកលឿងទៅភ្នំពេញវិញ។ ដូច្នេះខ្មែរក្រហមឆ្លៀតឱកាសវាយយកអ្នកលឿង។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមវាយយកបានភ្នំពេញ ខ្មែរក្រហមបានបញ្ជូនខ្ញុំមកកាន់ខេត្តមណ្ឌលគិរី។ ខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិទាំងអស់ដាក់រួម ដោយមិនឲ្យមានកម្មសិទ្ធិឯកជនឡើយ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានសង្ស័យគ្នាឯង និងបានកាប់សម្លាប់គ្នា។ នៅពេលដែលថ្នាក់លើចុះមកត្រួតពិនិត្យ មេសហករណ៍ដាំបាយ និងធ្វើម្ហូបឲ្យប្រជាជនហូបឆ្អែត ប៉ុន្តែពេលថ្នាក់លើទៅផុតគឺប្រជាជនត្រូវធ្វើការងារធ្ងន់ និងអត់អាហារដដែល។

## រ៉ានី

រ៉ានី ភេទស្រី អាយុ៧០ឆ្នាំ កើតនៅក្នុងភូមិកោះរំយើល ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ សព្វថ្ងៃរ៉ានីរស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ រ៉ានីបាននិយាយរៀបរាប់អំពីបទពិសោធន៍តស៊ូរបស់ខ្លួនក្នុងសម័យខ្មែរក្រហមថា ខ្ញុំគឺជាកូនកាត់ជនជាតិភាគតិច ចារាយ ព្នង និងលាវ។ ម្ដាយរបស់ខ្ញុំជនជាតិចារាយរីឯឪពុករបស់ខ្ញុំកាត់ព្នង និងលាវ។ កាលពីកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ ពីសង្គមចាស់ក៏ឈប់រៀនដោយសារតែគ្រួសាររបស់ខ្ញុំមានជីវភាពខ្វះខាត។ ប្រជាជនដែលរស់នៅខេត្តមណ្ឌលគិរី ភាគច្រើនគឺជាជនជាតិភាគតិច រួមមាន ព្នង ចារាយ លាវ និងទំពួន។ ជារៀងរាល់ឆ្នាំប្រជាជនតែងតែប្រារព្ធធ្វើពិធីសុំទឹកភ្លៀង និងធ្វើពិធីបន់ស្រន់សុំជាសះស្បើយពីជំងឺដែលកំពុងតែកើតមាន។ ជនជាតិភាគតិចរបស់ខ្ញុំមិនអាចរៀបការជាមួយសាច់ញាតិ បងប្អូនជីដូនមួយ ឬ ជាប់សាច់ឈាមគ្នាបានទេពីព្រោះយើងតំណមខ្លាចអ្នកតាកាច់ ឬខ្លាចរន្ទះបាញ់ជាដើម។ នៅក្នុងឆ្នាំ១៩៦៨ គ្រួសារខ្ញុំរួមទាំងប្រជាជនដែលរស់នៅក្នុងស្រុកកោះញែកនាំគ្នា ចូលទៅរស់នៅក្នុងព្រៃដោយសារអាមេរិកទម្លាក់គ្រាប់បែក។ រហូតដល់ឆ្នាំ១៩៧០ ប្រជាជនដែលរស់នៅក្នុងព្រៃបានចេញមករស់នៅក្នុងភូមិស្រុករៀងៗខ្លួនវិញ។ ប៉ុន្តែខ្ញុំរស់នៅក្នុងភូមិមិនបានប៉ុន្មានខែផងក៏រត់ចូលព្រៃម្ដងទៀត ដោយសារ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែង។ គ្រួសាររបស់ខ្ញុំ រួមទាំងប្រជាជនជាច្រើននាក់ទៀតដែលរស់នៅក្នុងព្រៃគឺស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយចិញ្ចឹមជីវិតដោយការជីកក្ដួច និងជីកដំឡូងព្រៃហូបនៅពេលអស់ស្បៀងអាហារ។ នៅចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ខ្ញុំបានចូលធ្វើជាគ្រូពេទ្យ។ កាលនោះខ្ញុំអាចចូលរៀនពេទ្យ




វ៉ាន់ នី ភេទស្រី អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិ ថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បានដោយសារខ្ញុំអាចអាន និងសរសេរអក្សរបាន។ ខ្ញុំរៀនខាងជំនាញព្យាបាលជំងឺគ្រុនចាញ់។ នៅក្នុងមន្ទីរពេទ្យខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រង និងបង្រៀនពីវេជ្ជបណ្ឌិត ជួន ជឿន។ បន្ទាប់ ពីខ្ញុំរៀនពេទ្យបានរយៈពេល៣ទៅ៤ខែ ខ្មែរក្រហមបញ្ជូនខ្ញុំមកព្យាបាលកងទ័ព និងប្រជាជននៅក្នុងព្រៃដែលស្ថិតក្នុងខេត្តមណ្ឌលគិរី។ ខ្ញុំគឺជាមេក្រុមគ្រប់គ្រងក្រុមគ្រូពេទ្យនារីនៅក្នុងកងពលលេខ១៥។ ចំពោះការហូបចុក ទោះបីជាខ្ញុំជាគ្រូពេទ្យក៏ហូបខ្វះខាតដូចប្រជាជនទូទៅដែរ គឺខ្ញុំត្រូវទៅជីកក្ដួចនិងដំឡូងយកមកហូបដើម្បីចិញ្ចឹមជីវិត។ មកដល់ឆ្នាំ១៩៨១ ខ្ញុំមានប្ដីដែលធ្វើជាកងទ័ព។ ខ្ញុំរស់នៅក្នុងព្រៃដែលស្ថិតក្នុងខេត្តមណ្ឌលគិរីរហូតដល់ឆ្នាំ១៩៨៦ ទើបខ្ញុំនិងប្រជាជនទាំងអស់សម្រេចចិត្តធ្វើដំណើរឆ្ពោះមកភ្នំដងរែកដើម្បីចូលទៅរស់នៅជំរំក្នុងទឹកដីថៃ។ កាលនោះខ្ញុំមានការលំបាកក្នុងការធ្វើដំណើរ ព្រោះអាកាសធាតុក្ដៅ អត់អាហារ ម្យ៉ាងវិញទៀតខ្ញុំមានកូនខ្ចី។ ខ្ញុំធ្វើដំណើរអស់រយៈពេល២ខែកន្លះ ទើបបានមកដល់ព្រំដែនថៃ។ បន្ទាប់ពីខ្ញុំបានរស់នៅក្នុងជំរំក្នុងទឹកដីថៃ ទើបខ្ញុំលែងមានការខ្វះខាត។ នៅក្នុងឆ្នាំ១៩៩០ គ្រួសាររបស់ខ្ញុំរួមទាំងប្រជាជនដទៃទៀតដែលបានទៅរស់នៅជំរំក្នុងទឹកដីថៃ បានចុះមករស់នៅក្នុងស្រុកអន្លង់វែងវិញ។ នៅពេលនេះ តាម៉ុក បានរៀបចំចែកដីធ្លីឲ្យប្រជាជនធ្វើផ្ទះសម្បែង និងធ្វើស្រែចម្ការសម្រាប់ហូបចុករៀងៗខ្លួន។ ប្រជាជនបានប្រកបមុខរបរធ្វើស្រែចម្ការ និងរស់នៅសុខសប្បាយរហូតដល់អ៊ុន គាក់ ចូលមកដល់អន្លង់វែង នៅឆ្នាំ១៩៩៣។ ពេលនោះ ខ្ញុំរួមទាំងប្រជាជនបានរត់ឡើងលើភ្នំម្ដងទៀត។ ខ្ញុំ និងប្រជាជនជាច្រើននាក់បានរស់នៅលើភ្នំដងរែករហូតដល់មានការចុះចូលធ្វើសមាហរណកម្មនៅអន្លង់វែងទើបនាំគ្នាចុះមករស់នៅតាមភូមិរៀងៗខ្លួនវិញ។



ផ្លូវលំក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង

ផេង ពង្សរ៉ាស៊ី, គា រស្មី, សូ ហាន់ និង ថុន ស្រីពេជ្រ

បុគ្គលិក និងអ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង កាលពីចុងសប្តាហ៍ទី៣និងដើមសប្តាហ៍ទី៤ ខែមករា ឆ្នាំ២០២២ បានចុះទៅកាន់ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដើម្បីជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៣នាក់ មកពីភូមិផ្សេងគ្នានៃឃុំព្រៃពោន។ លោកមេឃុំឈ្មោះ កែវ វន្ធា បានជួយសម្របសម្រួលកិច្ចការនេះតាំងពីដើមដល់ចប់។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសាច់រឿង ឬបទពិសោធន៍របស់អ្នករស់រានមានជីវិតទាំង១៣នាក់។



ម៉ឹង ឈិន អាយុ៧៥ឆ្នាំ រស់នៅភូមិត្រពាំងក្រសាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ម៉ឹង ឈិន

ម៉ឹង ឈិន អាយុ៧៥ឆ្នាំ រស់នៅភូមិត្រពាំងក្រសាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក។ ឈិន កើតនៅឆ្នាំ១៩៤៩ ក្នុងគ្រួសារក្រីក្រមួយនៅភូមិព្រៃពោន ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ស្ថិតក្នុងអាណានិគមបារាំង ឈិន រស់នៅជាមួយឪពុកម្តាយ និងបងប្អូន៥នាក់យ៉ាងលំបាក។ ពេល ឈិន មានអាយុ១១ឆ្នាំ គាត់បានចូលរៀននៅក្នុងសាលាបឋមសិក្សា ព្រៃពោន និងមិនបានបន្តការសិក្សាបន្តទៀតទេ បន្ទាប់បានបញ្ចប់ការសិក្សានៅក្នុងសាលានេះ។ ឈិន បាននិយាយដូច្នេះថា «ប្អូនៗរបស់ខ្ញុំបានបន្តការសិក្សានៅទីក្រុងភ្នំពេញទៀត។ ដោយសារតែខ្ញុំជាកូនច្បងក្នុងគ្រួសារ ខ្ញុំមិនបានបន្តការសិក្សានឹងគេទេ ព្រោះត្រូវនៅមើលថែឪពុកម្តាយចាស់ៗនៅស្រុកកំណើត និងជួយប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវភាព»។ បន្ទាប់ពីថ្ងៃ១៨ មីនា ១៩៧០ យុវជននៅក្នុងភូមិជាច្រើននាក់បានស្ម័គ្រចិត្តចូលរួមក្នុងចលនាបដិវត្តន៍របស់ខ្មែររំដោះ តាមការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ។ ឈិន ត្រូវបានអូសទាញដោយក្រុមយុវជនទាំងនោះ ប៉ុន្តែគាត់មិនបានសម្រេចចិត្តចូលរួមទេ ដោយសារតែឪពុកម្តាយចាស់ៗ និងត្រូវនៅមើលថែប្អូនៗផង។

ក្នុងអំឡុងឆ្នាំ១៩៧១ កងកម្លាំងធីវគី និងវៀតកុងមានវត្តមាននៅក្នុងទឹកដីភូមិព្រៃពោន ឃុំព្រៃពោន ហើយ កងកម្លាំងទាហាន លន់ នល់ ក៏បានបោះទីតាំងបន្ទាយរបស់ខ្លួននៅក្បែរបរិវេណវត្តព្រៃពោនដែរ។ វត្តមានរបស់កងកម្លាំងទាំងនេះ បានធ្វើឲ្យភូមិព្រៃពោនមានហេតុការណ៍ចម្លែកៗកើតឡើងជាហូរហែរ ដូចជាការប្រយុទ្ធគ្នា ការចាកចេញពីភូមិកំណើត និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកភូមិ។ ជារឿយៗ ការប្រយុទ្ធគ្នាបានកើតមានឡើងរវាងកងកម្លាំងទាំង

នោះ។ ឥទ្ធិពលនៃការប្រយុទ្ធគ្នានេះ បានធ្វើឲ្យប្រជាជននៅក្នុងភូមិខ្ចាចខ្ចាយគ្រប់ៗគ្នា រហូតនាំគ្នាចាកចេញពីផ្ទះសម្បែងរបស់ខ្លួនដើម្បីស្វែងរកទីកន្លែងជ្រកកោនសុវត្ថិភាពនៅឆ្ងាយៗពីភូមិកំណើត។ ស្ថិតក្នុងអំឡុងពេលដែលប្រជាជនទាំងអស់មិនស្នាក់នៅក្នុងផ្ទះ កងកម្លាំងធីវគី បានចូលរុករើផ្ទះសម្បែង និងសម្លាប់សត្វពាហនៈ និងសត្វចិញ្ចឹមផ្សេងទៀតរបស់អ្នកភូមិដើម្បីធ្វើម្ហូប។ នៅពេលដែលសភាពការណ៍ប្រយុទ្ធគ្នាស្ងប់ស្ងាត់ទៅ ប្រជាជននាំគ្នាវិលត្រឡប់មកកាន់ផ្ទះសម្បែងវិញ និងប្រកបរបរធ្វើស្រែបន្តិចបន្តួចដូចមុន ទោះជាស្ថានការមិនប្រក្រតីក៏ដោយ។ ព្រឹត្តិការណ៍នេះ បានជំរុញឲ្យទឹកចិត្តយុវជនគិតគូរពីការចូលរួមចំណែកក្នុងការស្តារប្រទេសជាតិ តាមរយៈការចូលរួមក្នុងកម្លាំងបដិវត្តន៍ដើម្បីនាំយកសម្តេចព្រះ នរោត្តម សីហនុ មកកាន់ប្រទេសកម្ពុជា ដើម្បីគ្រប់គ្រងប្រទេសជាថ្មីឡើងវិញ។ យុវជនភាគច្រើនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរបដិវត្តន៍។ យុវជនខ្លះទៀតមិនបានបង្ហាញឲ្យឃើញពីការចូលរួមដោយផ្ទាល់ទេ ប៉ុន្តែបានសម្តែងពីទឹកចិត្តស្នេហាជាតិតាមរយៈការចូលរួមសកម្មភាពនានាក្នុងភូមិកំណើត។ ឈិន មិនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរបដិវត្តន៍ពិតមែន ប៉ុន្តែគាត់បានឆ្លៀតពេលវេលាក្នុងការចូលរួមប្រជុំផ្សេងៗដែលបានកើតឡើងក្នុងភូមិស្រុក ដូចជាប្រជុំសម្ងាត់ ប្រជុំនយោបាយ និងប្រជុំអប់រំមនោគមវិជ្ជា។ ឈិន និយាយដូច្នេះថា «នៅឆ្នាំ១៩៧១ ខ្ញុំធ្លាប់បានចូលរួមប្រជុំសម្ងាត់មួយជាមួយយុវជនប្រហែល ២៥ នាក់ទៀត ដែលធ្វើឡើងនៅពេលយប់ឯកណ្តាលវាលស្រែដើម្បីអប់រំមិនឲ្យយុវជនទាំងអស់ស្រែក «ជយោ! សម្តេចឪ» ទេ នៅពេលទទួលបានជ័យជម្នះទាំងស្រុង។ ឈ្មោះ ប៉ោន និង ឡាន ជាប្រធានយុវជនឃុំព្រៃពោន ជាអ្នកហៅខ្ញុំឲ្យមកប្រជុំ។ ប្រជុំរបៀបនេះ មានតែម្តងទេ ប៉ុន្តែមានប្រជុំជាច្រើនទៀតបានកើតឡើង ដែលនិយាយតែពីរឿងជ័យជម្នះរបស់ខ្មែរក្រហម។ ខ្ញុំបានចូលរួមស្ទើរតែគ្រប់អង្គប្រជុំ»។

ចាប់ពីឆ្នាំ១៩៧២មក ស្របពេលដែលកងកម្លាំងវៀតណាមភាគច្រើន (ទាំងកងកម្លាំងធីវគី និងវៀតមិញ) ចាកចេញពីភូមិឃុំព្រៃពោន ការទម្លាក់គ្រាប់បែកក៏នៅតែបន្តកើតមានដដែលៗ រីឯចលនាបដិវត្តន៍ក៏រឹតតែរីកចម្រើនឡើងៗដែរ រហូតទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃ១៧ មេសា ១៩៧៥។ ពីឆ្នាំ១៩៧៥ដល់ថ្ងៃដែល ឈិន ត្រូវរៀបការនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧ គាត់ត្រូវកម្មាភិបាលខ្មែរក្រហមប្រើឲ្យធ្វើការនៅក្នុងកងចល័តស្រុកកំពង់ត្របែក ដែលតម្រូវឲ្យធ្វើការនៅទីកន្លែងឆ្ងាយៗពីភូមិកំណើត។ ឈិន បាននិយាយពីការរៀបការរបស់គាត់ប្រាប់ថា «នៅថ្ងៃទី៧ ខែ៧ ឆ្នាំ១៩៧៧ ខ្ញុំរៀបការជាមួយប្រពន្ធខ្ញុំ។ ក្នុងថ្ងៃនោះ គូស្រករ១៣គូផ្សេងទៀតត្រូវអង្គការផ្សំផ្គុំដូចខ្ញុំដែរ នៅក្នុងសហករណ៍ព្រៃពោន។ មុនថ្ងៃរៀបការមួយថ្ងៃ នៅម៉ោងប្រហែល ៧ យប់គេ (អង្គការ) ឲ្យយុវជនម្នាក់ទៅហៅខ្ញុំមកឲ្យមើលគ្រួសារ (ប្រពន្ធ) របស់ខ្ញុំដែលកំពុងអង្គុយនៅក្នុងសហករណ៍។ ខ្ញុំធ្លាប់ស្គាល់គាត់កាលពីយើងនៅក្នុងកងចល័តដូចគ្នា។ គាត់ស្លូតណាស់។ គេប្រាប់ថា មិត្តឯងត្រូវរៀបការនៅថ្ងៃស្អែកជាមួយនារីម្នាក់ហ្នឹង យល់ព្រមអត់? ខ្ញុំភ្ញាក់ខ្លួនព្រើតរួចខ្ញុំឆ្លើយថា យល់ព្រម។ ដល់អ៊ីចឹង គេសរសេរនៅលើក្រដាសតាមការយល់ព្រមរបស់ខ្ញុំ។ ខ្ញុំមិនដឹងថាគេសរសេរអ្វីខ្លះទេ។ អ្នកសរសេរគឺជាគ្រូបង្រៀននាពេលនោះ។ ស្អែកឡើង ខ្ញុំមករៀបការនៅក្នុងសហករណ៍ព្រៃពោន។ ប្រធានសហករណ៍ព្រៃពោន ជាអ្នកណែនាំក្នុងពិធីរៀបការ។ កន្លះខែបន្ទាប់ពីរៀបការរួច ខ្ញុំត្រូវបញ្ជូនទៅកាន់កន្លែងមួយចំនួនក្បែរៗស្រុកពាមជរ ដើម្បីធ្វើការងារដាំដំណាំ និងក្តួរាស់។ យូរៗខ្ញុំបានមកលេងផ្ទះម្តង។ រហូតដល់ឆ្នាំ១៩៧៩ ទើបខ្ញុំមានកូនប្រុសម្នាក់»។ នៅឆ្នាំ១៩៧៨ ឈិន បានស្នើសុំអង្គការទៅកាន់ខេត្តពោធិ៍សាត់ជាមួយគ្រួសារបងស្រីរបស់ខ្លួន ប៉ុន្តែត្រូវអង្គការបដិសេធ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ឈិន បានបាត់បង់បងថ្លៃប្រុសម្នាក់ និងក្មួយពីរនាក់។ ឈិនបានចូលធ្វើជាគ្រូបង្រៀន និងបានចូលនិវត្តន៍នៅឆ្នាំ២០១៥។ សព្វថ្ងៃ ឈិន ប្រកបរបរជាគ្រូពេទ្យប្រចាំភូមិ។

## ម៉ឹង សាមួន



ម៉ឹង សាមួន អាយុ៦៧ឆ្នាំ រស់នៅភូមិត្រពាំងក្រសាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ឹង សាមួន អាយុ៦៧ឆ្នាំ រស់នៅភូមិត្រពាំងក្រសាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុករបស់សាមួន មានឈ្មោះ ម៉ឹង គង់ ហើយម្តាយឈ្មោះ កោគ ប៊ិច និងមានបងប្អូន៨នាក់ (ស្រី៣)។ ឪពុកម្តាយររបស់សាមួន ស្លាប់តាំងពី សាមួននៅក្មេងដោយសារជំងឺចាស់ជរា។ សាមួនដែលជាកូនពៅនៅក្នុងគ្រួសារបានផ្លាស់ប្តូរទីលំនៅទៅនៅវត្តដើម្បីបន្តការសិក្សារៀនសូត្រនៅបឋមសិក្សាព្រៃពោនរហូតដល់បញ្ចប់ថ្នាក់ទី៧។ ឆ្នាំ១៩៦៨ សាមួនបានបន្តការសិក្សារបស់ខ្លួននៅអនុវិទ្យាល័យព្រៃពោន ដោយចូលរៀនថ្នាក់ទី៦។ ឆ្នាំ១៩៧០ នៅក្នុងស្រុកចាប់ផ្តើមមានសង្គ្រាម សាមួនបានផ្លាស់ប្តូរការសិក្សាពីព្រៃពោនទៅវិទ្យាល័យកំពង់ត្របែក ប៉ុន្តែបានតែប៉ុន្មានខែក៏រត់ទៅរស់នៅ ទីក្រុងភ្នំពេញវិញ។ ព្រះចៅអធិការវត្តព្រះនាម ប៉ែន នួន ជាអ្នកនាំសាមួនឲ្យទៅរស់នៅក្នុងវត្តបទុម ដោយគង់ក្នុងកុដិលេខ ២៨ ក្រោមការគ្រប់គ្រងរបស់ ព្រះសង្ឃឈ្មោះ ម៉ៅ ខាន់។ ការរស់នៅក្នុងវត្តមានការលំបាកណាស់ សាមួនឆ្លៀតធាក់ស៊ីក្លូ ដើម្បីផ្គត់ផ្គង់ការសិក្សា និងម្ហូបអាហារប្រចាំថ្ងៃព្រោះព្រះសង្ឃដើរបិណ្ឌបាតមិនសូវបានដូចគ្នា។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកឈ្នះទៅលើទាហាន លន់ នល់ ទាំងស្រុង ហើយយោធាខ្មែរក្រហមជាច្រើននាក់បានរត់ចូលក្នុងទីក្រុងភ្នំពេញរួមទាំងប្រកាសខ្លួនថាមិនមែនចូលមកចរចា។ សាមួនបានជួបបងប្រុសរបស់ខ្លួនម្នាក់ដែលមានឈ្មោះថា ម៉ឹង ព្រៃ ក្នុងឯកសណ្ឋានជាយោធាខ្មែរក្រហម។ បងរបស់សាមួន បានប្រាប់ឲ្យសាមួនត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ និងឲ្យសាមួនទៅរៀនអំពីការរស់នៅរបស់ប្រជាជនក្នុងភូមិវិញ។ សាមួន បានធ្វើដំណើរអស់រយៈពេល១៩ថ្ងៃទើបមកដល់ ភូមិត្រពាំងក្រសាំង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ដោយធ្វើដំណើរតាមផ្លូវជាតិលេខ១១។ ពេលទៅដល់ផ្ទះ បងប្អូនក្នុងភូមិបានណែនាំ សាមួន អំពីរបៀបរស់នៅ និងប្រាប់ឲ្យគាត់ធ្វើជាមនុស្សល្ងង់។ ក្នុងឆ្នាំ១៩៧៥ ដំបូងឡើយប្រជាជនធ្វើស្រែរួមគ្នា ប៉ុន្តែការហូបអាហារតាមផ្ទះរៀងខ្លួន ហើយប្រធានសហករណ៍ជាអ្នកចែកស្រូវឲ្យប្រជាជនក្នុង១នាក់៣គីឡូស្រូវយកមកហូបក្នុងមួយថ្ងៃ។ ប្រជាជននៅក្នុងភូមិរួមទាំងសាមួន បានយកស្រូវទៅលីងហើយបុករួចរែងយកតែអង្ករមចេញ សល់ប៉ុន្មានយកមកហូប។ នៅពេលមានភ្ញៀវនៅតាមផ្លូវធ្វើដំណើរ និងកន្លែងបន្ទោរបង់ឃើញមានដានជើងរបស់មនុស្ស ប៉ុន្តែលាមកគឺដូចជាលាមកសត្វជ្រូកទៅវិញ។ បន្ទាប់ពីបែកហើយបានប្រមាណ១ឆ្នាំ នៅក្នុងភូមិព្រៃក្រសាំងចាប់ផ្តើមបង្កើតជារោងបាយរួម ហូបរួម និងប្រមូលសត្វចិញ្ចឹម សម្ភារប្រើប្រាស់ទាំងអស់ ដាក់ក្នុងសហករណ៍រួម។ ការហូបអាហារកាន់តែលំបាក គឺបានតែបបរពីរពេលក្នុងមួយថ្ងៃ ហើយការធ្វើការងារកាន់តែធ្ងន់។ បន្ទាប់ពីបញ្ចប់ការធ្វើស្រែ ប្រជាជននៅក្នុងភូមិដែលមានកម្លាំងធ្វើការ អង្គការបញ្ជូនឲ្យទៅជីកប្រឡាយ និងលើកប្រព័ន្ធភ្លឺស្រែផ្សេងៗ។ ពេលទៅធ្វើការយើងអាចដើររកបន្លែ ដូចជា កំប្លោក ត្រកួន ព្រលិត និងសត្វល្អិតផ្សេងៗយកមកហូបបន្ថែមបាន។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ សាមួនបានរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្លួនម្នាក់ ដែលមាន

ឈ្មោះថា ម៉ឺង សារ៉ុន និងបានរស់នៅជាមួយគ្នារហូតដល់បែកសម័យខ្មែរក្រហមក្នុងឆ្នាំ១៩៧៩។ ក្រោយមកបានប្រមាណ ៥ឆ្នាំ សាមួន បានទៅប្រឡងជាប់ធ្វើជាគ្រូបង្រៀននៅវិទ្យាល័យកំពង់ត្របែក ហើយគាត់តែងតែយករឿងរ៉ាវដែលគាត់បានឆ្លងកាត់សម័យខ្មែរក្រហមប្រាប់ទៅសិស្សរបស់គាត់។ សាមួនបានបន្ថែមទៀតថា គាត់មានការអន់ចិត្ត និងខឹងយ៉ាងខ្លាំង នៅពេលដែលក្មេងៗជំនាន់ក្រោយនិយាយថា ប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាប្រវត្តិសាស្ត្រដែលគេប្រឌិតឡើង ហើយឆ្អឹងសាកសពដែលនៅសល់ទាំងអស់គឺជាជ័រ។

---

## ស៊ុម ហ៊ួន



ស៊ុម ហ៊ួន អាយុ៦៦ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង
(ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ុម ហ៊ួន អាយុ៦៦ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅភូមិបេង ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ហ៊ួន ជាមនុស្សម្នាក់ដែលស្រឡាញ់ខាងវិស័យសិល្បៈណាស់ គាត់បានទៅដាក់ពាក្យប្រឡងចម្រៀងទៀតផងនៅវត្តកសួបៈក្រោយខ្មែរក្រហមដួលរលំ តែត្រូវប្រឡងធ្លាក់។ នៅឆ្នាំ១៩៧២ ហ៊ួន បានទៅរៀនច្រៀងចម្រៀងជាច្រើនបទ ដែលសុទ្ធតែជាចម្រៀងបដិវត្តន៍របស់ខ្មែរក្រហម។ គ្រូបង្រៀនចម្រៀងដែលរស់នៅក្នុងភូមិរបស់ ហ៊ួន បានបង្រៀនចម្រៀងជាច្រើនបទដល់ ហ៊ួន និងអ្នកឯទៀតសម្រាប់ច្រៀងឱ្យខ្មែរក្រហមស្តាប់ ហើយបទដែល ហ៊ួន នៅតែចាំមិនភ្លេចនោះ គឺបទ ឈាមក្រហមឆ្អៅ និង ដៃកាន់អាវុធ។ ផ្ទាកមកមើលជីវប្រវត្តិពីដើមរបស់ ហ៊ួន វិញ នៅឆ្នាំ១៩៦៨ ស៊ុម ហ៊ួនបានចូលរៀនដំបូងនៅសាលាវត្តបេងក្នុងអាយុ៨ឆ្នាំ ហើយបានផ្អាកការសិក្សាមួយរយៈ ត្រឹមថ្នាក់ទី១០។ មូលហេតុដែលគាត់មិនអាចបន្តការសិក្សាបាននោះ គឺដោយសារតែស្រុកទេសមានភាពច្របូកច្របល់ មានសង្គ្រាមកើតឡើង មានការវាយប្រយុទ្ធគ្នានៅពាសពេញទឹកដីបន្ទាប់ពី លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ មក។ សង្គ្រាមបានធ្វើឱ្យក្រុមគ្រួសាររបស់ ហ៊ួន និងអ្នកឯទៀតមានការលំបាកជាខ្លាំង ជាពិសេសត្រូវរត់ចាកឆ្ងាយពីផ្ទះសម្បែងឥតឈប់ឈរ ហើយអ្នកខ្លះក៏ត្រូវអស់ជីវិតទៀតដោយសារសង្គ្រាម។ ក្រោយសេនាប្រមុខ លន់ នល់ កាន់កាប់ទីក្រុងភ្នំពេញបានទាំងស្រុង សម្តេច នរោត្តម សីហនុ បានអំពាវនាវពី ប៉េកាំង មកឱ្យប្រជាជនរត់ចូលព្រៃម៉ាគីម៉ា ដើម្បីតស៊ូ និងបង្កើតជារណៈសិរ្សរំដោះជាតិកម្ពុជា។ ប្រជាជនជាច្រើនរួមទាំង ហ៊ួន ដែរ ដែលបានចូលតាម ការអំពាវនាវរបស់សម្តេច ដើម្បីទាមទារអំណាចមកថ្វាយជូនព្រះអង្គវិញ។ ហើយការចូលរួមរបស់ ហ៊ួន នេះដែរត្រូវបានគេលើកឱ្យធ្វើជាកងឈ្លបនៅក្នុងឃុំព្រៃពោន។ នៅឆ្នាំ១៩៧៨ (មិនចាំថ្ងៃខែ) ហ៊ួន ត្រូវបានខ្មែរក្រហមជ្រើសតាំងឱ្យចូលជាកងពល៨០៥ ចំណុះឱ្យមជ្ឈិម ដែលមានតា សែម ជាប្រធាននៅស្រុក អូរាំងឪ។ ការជ្រើសតាំងនេះតម្រូវឱ្យ ហ៊ួន ហាត់រៀនច្បាប់ទាហាននៅ ទីរួមខេត្តព្រៃវែង ដោយការហាត់រៀននោះមានដូចជាការបង្ហាត់ឱ្យបេះដាក់មីន ដោះមីន បាញ់ស៊ីប លូន ក្រាប ជាដើម ក្នុងរយៈពេល៦ខែ។ នៅចុងឆ្នាំ១៩៧៨ ក្នុងសភាពការណ៍វៀតណាម វាយចូលទឹកដីកម្ពុជាពេញទំហឹង ហ៊ួនបានចេញទៅច្បាំងនៅ ទួលអាក្លូតប្រមុះជ្រូក ស្រុកព្រះស្តេច តាមព្រំដែន ដើម្បីការពារ

មិនឲ្យយួនវាយចូលមកបាន តែក៏ត្រូវបានវៀតណាមបាញ់កាំភ្លើងត្រូវចំភ្លៅខាងស្តាំចំនួន ២គ្រាប់ ដែលបន្សល់ទុកនូវស្លាកគ្រាប់កាំភ្លើងរហូតមកដល់សព្វថ្ងៃ។ ទាហានខ្មែរក្រហម បានបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យបឹងព្រលិត ហើយសម្រាកនៅទីនោះចំនួនមួយខែកន្លះទើបវិលចូលសមរភូមិវិញដើម្បីប្រយុទ្ធបន្តទៀត។ ហ៊ួន បាននិយាយថា ខណៈពេលដែលគាត់កំពុងតែត្រូវគ្រាប់កាំភ្លើង គាត់មានការភិតភ័យ និងញ័រយ៉ាងខ្លាំងនៅពេលដែលគាត់ឮស្នូរគ្រាប់កាំភ្លើងផ្ទុះឡើងម្តងៗ។ សង្គ្រាមខ្មែរក្រហមជាមួយវៀតណាមត្រូវបានបញ្ចប់ ខ្មែរក្រហមបានចាញ់ទៅលើសង្គ្រាម ហ៊ួនបានបោះកាំភ្លើងចោល ហើយបានវិលមកកាន់ស្រុកកំណើតវិញ ក្រោយថ្ងៃជ័យជម្នះ ៧មករា ឆ្នាំ១៩៧៩ ហើយបានប្រកបរបរធ្វើស្រែរហូតមកដល់បច្ចុប្បន្ន។

## ឃុត សោភា



ឃុត សោភា ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិ ជីពាយ ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង
(ដេង ពង្សរ៉ាស៊ី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃុត សោភា ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិជីពាយ ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ម្តាយរបស់ សោភា ឈ្មោះ ឡាំ ផល ហើយឪពុកឈ្មោះ ឃុត ចិន។ សោភា មានបងប្អូនបួននាក់ (ស្រីពីរនាក់)។ បងប្អូនរបស់ សោភា ចំនួនពីរនាក់បានស្លាប់ក្នុងរបបខ្មែរក្រហម។ នៅពេលដែលខ្មែរក្រហមចូលគ្រប់គ្រងនៅក្នុងភូមិជីពាយដំបូង ក្មេងៗ ត្រូវបានអនុញ្ញាតឲ្យរៀនសូត្រដល់ថ្នាក់ទី៥។ ក្មេងៗនៅក្នុងភូមិទាំងអស់ រួមទាំង សោភា ផង បានចូលរៀននៅក្នុងសាលាពេលព្រឹក ហើយចំណែកពេលរសៀលគឺអង្គការប្រើឲ្យទៅប្រមូលអាចម៍គោ អាចម៍ក្របីនៅតាមផ្ទះអ្នកភូមិ។ បន្ថែមលើសពីនេះទៅទៀត ក្រុមរបស់ សោភា ត្រូវបានប្រធានសហករណ៍ប្រើឲ្យទៅស្ទូងស្រូវ ដឹកដីស្រះប្លុកត្រពាំង និងច្រូតស្រូវតាមរដូវកាល។ នៅក្នុងឆ្នាំ១៩៧៨ សោភា បានរៀនត្រឹមតែថ្នាក់ទី៣ ព្រោះអង្គការបានបញ្ជូនគ្រួសាររបស់គាត់ឲ្យទៅកាន់ខេត្តពោធិ៍សាត់។ គ្រួសាររបស់ សោភា ចាប់ផ្តើមចេញដំណើរពីភូមិដោយជិះរទេះគោរហូតទៅដល់អ្នកលឿង។ នៅយប់ដដែលគ្រួសាររបស់ សោភា និងប្រជាជនជាច្រើនគ្រួសារទៀតបានបន្តដំណើរដោយជិះកប៉ាល់ពីអ្នកលឿងរហូតទៅឈប់នៅច្បារអំពៅ។ ពេលទៅដល់ច្បារអំពៅ មានកម្មាភិបាលខ្មែរក្រហមចែកអាហារ សម្លៀកបំពាក់ និងក្រមារឲ្យមកប្រជាជនម្នាក់មួយ។ ក្រោយពីសម្រាកបានតែបន្តិច អង្គការបានឲ្យគ្រួសាររបស់ សោភា ឡើងលើរថភ្លើង ដើម្បីធ្វើដំណើរបន្តទៅមុខទៀត។ គ្រួសាររបស់ សោភា បានជិះរថភ្លើងទៅឈប់នៅវត្តពោធិ៍ (ខេត្តពោធិ៍សាត់) ដើម្បីសម្រាកហូបអាហារ និងបែងចែកកម្លាំងដើម្បីធ្វើការនៅថ្ងៃស្អែក។ បងរបស់ សោភា ត្រូវបានអង្គការប្រើឲ្យទៅចាំដេញជ្រូកព្រៃកុំឲ្យចូលមកស៊ីស្រូវ។ ចំណែក សោភា និងប្អូនម្នាក់ទៀតដែលនៅតូច គឺត្រូវឲ្យចាំដេញចាបនៅសហករណ៍អន្លង់វិល។ ឪពុករបស់ សោភា វិញ ត្រូវកម្មាភិបាលខ្មែរក្រហមប្រើឲ្យដឹកអំបិល ចំណែកម្តាយវិញ ត្រូវអង្គការប្រើឲ្យត្បាញក្រមា។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះប្រជាជននៅក្នុងសហករណ៍កូនផារ ដែលជាកន្លែង សោភា ធ្វើការ។ អំឡុងពេលដែលចលាចល គ្រួសាររបស់ សោភា បានរត់មកវត្តពោធិ៍វិញ ដើម្បីឲ្យកងទ័ពវៀតណាមជួយ។ នៅតាមផ្លូវមានទាហានចិត្តល្អម្នាក់ ប្រាប់ទៅក្រុមគ្រួសាររបស់ សោភា កុំឲ្យចូលទៅក្នុងវត្ត ព្រោះមានទាហាន

ខ្មែរក្រហមចាំធ្វើបាបប្រជាជន។ គ្រួសាររបស់សោភា បានបន្តដំណើររហូតដល់ទីរួមខេត្តពោធិ៍សាត់ជាកន្លែងដែល សោភា ស្នាក់នៅអស់រយៈពេល១ខែកន្លងមកទៀត។ បន្ទាប់ពីឃើញសភាពការតាមផ្លូវស្រួលបួលហើយ និងមានកងទ័ពវៀតណាមចាំនាំផ្លូវផង ក្រុមគ្រួសាររបស់ សោភា អាចធ្វើដំណើរមកដល់អ្នកលឿង និងបានទៅដល់ស្រុកកំណើតនៅភូមិជីពាយ។ នៅឆ្នាំ១៩៩០សោភាបានរៀបការជាមួយកម្លោះក្នុងភូមិម្នាក់ដែលមានឈ្មោះជា ធឿន និងមានកូន៣នាក់ស្រីទាំងអស់។ រឿងរ៉ាវដែល សោភា បានឆ្លងកាត់ ហើយនៅតែចាំមិនភ្លេចគឺ នាងបានវង្វេងប្អូនប្រុសម្នាក់ធ្វើឲ្យនាង យំរហូតដើររកប្អូនឃើញវិញ។

## សាន ផាន



សាន ផាន អាយុ៧០ឆ្នាំ រស់នៅភូមិជីពាយ ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ផេង ពង្សរ៉ាស៊ី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

សាន ផាន អាយុ៧០ឆ្នាំ រស់នៅភូមិជីពាយ ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុករបស់ផានឈ្មោះ នៅ ភឹម ហើយម្ដាយឈ្មោះ សាយ ភឹម។ ផានមានបងប្អូន១១នាក់(ប្រុស៥នាក់)។ នៅអាយុ១៥ឆ្នាំ ផាន បានបញ្ចប់ថ្នាក់ទី៩ នៅសាលាបឋមសិក្សាបេងបុរី និងបានរៀនបន្តរហូតដល់បញ្ចប់ការសិក្សានៅថ្នាក់ទី៧ ក្នុងសាលាបឋមសិក្សាថ្នាក់ខណ្ឌ។ នៅឆ្នាំ១៩៧០ ផានបានឈប់រៀន ព្រោះតែមានសង្គ្រាមប្រយុទ្ធគ្នា និងការទម្លាក់គ្រាប់នៅក្នុងភូមិជីពាយ។ នៅអាយុ២០ឆ្នាំ សាន បានរៀបការជាមួយ ចាប សៀប។ នៅឆ្នាំ១៩៧៥ អង្គការបានប្រើឲ្យផានចូលរួមនៅក្នុងក្រុមផលិតនង្គ័លរនាស់ ក្រឡុសបង្គី ចប កាំបិត ពូថៅ ចាន ស្លាបព្រា និងឆ្នាំង។ ក្រោយមកទៀតអង្គការបានបញ្ជូនផានឲ្យទៅធ្វើការនៅក្នុងក្រុមដឹកជញ្ជូនប្រចាំភូមិជីពាយ។ រឿងមួយដែល ផាន នៅចាំមិនភ្លេច គឺភាពភ័យខ្លាចរបស់គាត់ចំពោះកំហុសដែលគាត់បានជួបប្រទះ ហើយត្រូវកម្មាភិបាលខ្មែរក្រហមស្ដីបន្ទោស។ គាត់បាននិយាយប្រាប់ថា នៅពេលដែលអង្គការប្រើគាត់ឲ្យទៅដឹកសត្វទា ២០០ក្បាល ពីឃុំជាងដែកមកឃុំព្រៃពោន គាត់បានធ្វើឲ្យសត្វទា ២ក្បាល ងាប់នៅតាមផ្លូវ។

កំហុសនេះ ត្រូវប្រធានសហករណ៍ជាងដែកឈ្មោះ វ៉ា រ៉ាន់ ស្ដីបន្ទោសចំពោះការធ្វេសប្រហែសនេះ។ ផានបានរំឭកថា គាត់ភ័យខ្លាចខ្លាំងបំផុត គឺភ័យខ្លាចក្រុមកងឈ្លបមកចាប់គាត់យកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៨ ផាន បានសុំអង្គការទៅលេងឪពុកនៅកអណ្ដើក ជាកន្លែងដែល ផាន បានឃើញអ្នកទោសជាច្រើននាក់ត្រូវបានអង្គការប្រើឲ្យធ្វើការងារធ្ងន់ៗ និងមិនមានអ្វីហូបទាំងអស់។ នៅដើមខែមករា ឆ្នាំ១៩៧៩ គ្រួសាររបស់ផាន ត្រូវបានជម្លៀសទៅខេត្តភាគខាងលិចរួមជាមួយប្រជាជនជាច្រើនទៀតនៅក្នុងភូមិ។ គ្រួសាររបស់ ផាន បានធ្វើដំណើររយៈ៣ថ្ងៃទៅដល់ស្រុកព្រះស្ដេច ក៏បានត្រឡប់មកវិញព្រោះមានកងទ័ពវៀតណាមចូលមកជួយ។ ពេលមកដល់ភូមិ ផាន បានចាប់ផ្ដើមប្រមូលរបស់របរធ្វើស្រែចម្ការ និងស្បៀងអាហារបន្តិចបន្តួចពីរោងបាយ ដើម្បីចិញ្ចឹមជីវិតបន្តមកដល់សព្វថ្ងៃ។ ប្រពន្ធរបស់ ផាន បានស្លាប់ចោលគាត់នៅអាយុ៦៣ឆ្នាំ ហើយសព្វថ្ងៃ ផាន មានកូន៤នាក់ (ប្រុស១) និងកំពុងរស់នៅជាមួយកូនស្រីពៅរបស់គាត់។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
## ធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

**ទូច វណ្ណេត**



លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមកំពុងបង្ហាញពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃអង្គារ៍ ទី២៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង០៨:១៥នាទីព្រឹក អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់ ធ្វើទស្សនកិច្ចមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដើម្បីស្វែងយល់អំពីកិច្ចការងារស្រាវជ្រាវ ចងក្រង និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ដំណើរទស្សនកិច្ចនេះរួមបញ្ចូល៖



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងមើលឯកសារដាក់តាំងនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

១) ការទស្សនាពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

២) ការចាក់បញ្ចាំងវីដេអូឯកសារស្តីពីសកម្មភាពការងាររបស់អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម

៣) ការបង្ហាញឯកសារទាក់ទងរបបខ្មែរក្រហម រួមមានចម្លើយសារភាព និងបទសម្ភាសន៍

៤) ការចែកជូនប្រតិទិនឆ្នាំ២០២២ ដើម្បីរំឭកដល់កម្រងព្រះរាជអនុស្សាវរីយ៍នៃព្រះបាទសម្តេចព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» ដែលបោះពុម្ពដោយបណ្ណាល័យសម្តេចម៉ែ ។

បន្ទាប់ពីកម្មវិធីនៃដំណើរទស្សនកិច្ចនេះបានបញ្ចប់នៅវេលាម៉ោង០៩:៣០នាទី អ្នករស់មានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលទស្សនាមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម បានចែករំលែកទស្សនយល់ឃើញ ក៏ដូចជា សម្តែងការពេញចិត្តចំពោះការទទួលរៀបចំយ៉ាងយកចិត្តទុកដាក់របស់ក្រុមការងារ ដូចខាងក្រោម៖

**គុង សុភា** អាយុ៦០ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បង្ហាញការពេញចិត្តចំពោះសកម្មភាពអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមថា «ខ្ញុំមានការចងចាំមិនអាចបំភ្លេចបានផ្ទាល់ខ្លួនចេញពីការបាត់បង់ឪពុក និងការរស់នៅឃ្លាតឆ្ងាយពីគ្រួសារ។ ខ្ញុំយល់ថា ការចងក្រងរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិត និងការសិក្សាអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមគឺមានសារសំខាន់សម្រាប់ក្មេងជំនាន់ក្រោយ» ។

**គង់ ហ៊ាន់** អាយុ៧០ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាកសិករនៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បានរំឭកអំពីការរស់នៅក្នុងភាពភ័យតក់ស្លុត «នៅពេលដែលខ្ញុំឃើញម៉ាស៊ីនដេរខោអាវនៅក្នុងផ្ទាំងរូបថតនេះ ខ្ញុំនឹកឃើញអំពីពេលវេលាដែលខ្ញុំធ្វើការនៅក្នុងកងកាត់ដេរភូមិ។ ខ្ញុំទទួលរងភាពភ័យតក់ស្លុតគ្រប់ពេលវេលាខ្ញុំធ្វើការ។ រូបភាពអំពីម៉ាស៊ីននេះ ជំរុញឲ្យខ្ញុំមានការចងចាំពីរឿងរ៉ាវជាច្រើនដែលខ្ញុំបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម» ។

**លោក អៀង សារឿន** អាយុ៦៧ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បង្ហាញទស្សនយល់ឃើញ «ខ្ញុំសូមអរគុណដល់ក្រុមការងារដែលបានបង្ហាញអំពីការងារ និងសកម្មភាពអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលខ្ញុំយល់ថា មានសារសំខាន់ដល់ក្មេងៗជំនាន់ក្រោយ, ខ្លះមិនយល់ឬមិនជឿ ទុកលំបាកដែលចាស់ៗជំនាន់មុន រួមទាំងរូបខ្ញុំផ្ទាល់ បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមនោះឡើយ។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងមើលឯកសារដាក់តាំងនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនាពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងឧបករណ៍តម្បាញនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# វេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ផ្លុង ដានី, រី លក្ខិណា, គៀត ស្រីឡែន និង ឈុំ រ៉ា

## ពេលរសៀលថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២២

ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះទៅសាលាឃុំទម្លង និងបានជួបជាមួយជំទប់ទី១ ឃុំទន្លូង ឈ្មោះ ប៊ឹង ប៊ុនថន និងលោក ដាន់ ចន្នី ដែលជាជំនួយការរដ្ឋបាលឃុំទន្លូង។ គោលបំណងដែលក្រុមការងារចុះទៅសាលាឃុំទន្លូង ដើម្បីផ្តល់ដំណឹងដល់សាលាឃុំអំពីមជ្ឈមណ្ឌលឯកសារកោះថ្ម មានគម្រោងស្តីពីការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅក្នុងគម្រោងនេះ យើងមានផ្តល់សេវាពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅនៅតាមមន្ទីរសម្រាកព្យាបាលដែលជាដៃគូរបស់យើងនៅក្នុងឃុំទន្លូង នៅទីរួមស្រុកមេមត់ និងនៅស្រុកត្បូងឃ្មុំ ដោយមិនគិតថ្លៃ។ លោកជំទប់ទី១ និងលោកជំនួយការរដ្ឋបាលឃុំបានឯកភាព និងជួយផ្សព្វផ្សាយដល់ប្រពលរដ្ឋនៅក្នុងឃុំទម្លងទាំងមូលជ្រាបជាព័ត៌មាន និងមកទទួលការពិនិត្យសុខភាពនៅតាមមន្ទីរសម្រាកព្យាបាលដែលជាដៃគូរបស់មជ្ឈមណ្ឌលឯកសារកោះថ្ម។ លោកជំទប់ទី១ ក៏មានសំណូមពរចង់ឲ្យខាងមជ្ឈមណ្ឌលឯកសារកោះថ្មមកជួបប្រជុំជាមួយមេភូមិទាំង១៣ ក្នុងថ្ងៃណាមួយ ដើម្បីផ្សព្វផ្សាយ ក៏ដូចជាពន្យល់ពួកគាត់ឲ្យកាន់តែច្បាស់ ហើយងាយស្រួលដល់មេភូមិទៅផ្សព្វផ្សាយបន្តទៀតដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ពួកគាត់។

## នៅចន្លោះពីថ្ងៃទី២៤ - ២៧ ខែមករា ឆ្នាំ២០២២

ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រួមមាន ផ្លុង ដានី រី លក្ខិណា គៀត ស្រីឡែន និងឈុំរ៉ា បានចុះសម្ភាសន៍លើគម្រោងវេទិកាប្រវត្តិសាស្ត្រគ្រួសារចំនួន១០គ្រួសារនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំបន្តពីឆ្នាំ២០២១។ ភូមិសាទុំ គឺជាភូមិមួយស្ថិតនៅជាប់ព្រំដែន (កម្ពុជា-វៀតណាម) និងជាអតីតសមរភូមិក្តៅ រវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុង នៅអំឡុងចុងទសវត្សរ៍ឆ្នាំ ១៩៦០ និងដើមឆ្នាំ១៩៧០។ អ្នកភូមិសាទុំបានឲ្យដឹងថា នៅចុងឆ្នាំ១៩៦០ កងទ័ពវៀតកុងបានសាងសង់បន្ទាយ និងមន្ទីរពេទ្យធំមួយកន្លែងស្ថិតនៅចម្ងាយប្រមាណ ៤គីឡូម៉ែត្រ ប៉ែកខាងជើងភូមិសាទុំ។ បន្ទាយ និងមន្ទីរពេទ្យនោះស្ថិតនៅក្នុងព្រៃក្បាលដាំជ្រៃ ព្រៃកញ្ឆន់ក្បែរត្រពាំងទឹកមួយ។ នៅពេលនោះមានកងទ័ពវៀតកុងត្រូវរបួសនៅតាមសមរភូមិជាច្រើនត្រូវបានដឹកមកព្យាបាលនៅក្នុងមន្ទីរពេទ្យនេះ។ នៅអំឡុងពេលនោះក៏មានអ្នកភូមិសាទុំមួយចំនួនបានទៅសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរបស់វៀតកុងនោះដែរ។ អ្នកភូមិសាទុំដែលមានអាយុលើសពី៦០ឆ្នាំភាគច្រើនបានស្គាល់បន្ទាយ និងមន្ទីរពេទ្យរបស់កងទ័ពវៀតកុងយ៉ាងច្បាស់ ពីព្រោះពួកគាត់ធ្លាប់បានទៅលេង ប្តូយកបន្លែបង្ការទៅលក់ឲ្យកងទ័ពវៀតកុងនៅក្នុងបរិវេណមន្ទីរពេទ្យនោះ។

អ្នកភូមិសាទុំក៏បានឲ្យទៀតថា នៅក្នុងឆ្នាំ១៩៦៩ ឬឆ្នាំ១៩៧០ យន្តហោះបេ៥២របស់ទាហានសហរដ្ឋអាមេរិកបានមកទម្លាក់គ្រាប់បែកស្រោចលើបន្ទាយ និងមន្ទីរពេទ្យដែលធ្វើឲ្យកងទ័ពវៀតកុងជាច្រើនបានស្លាប់ និងរបួស។ ចំណែកកងទ័ពដែលនៅសេសសល់បានរត់គេចខ្លួនចេញពីបន្ទាយ និងមន្ទីរពេទ្យអស់តែម្តង។ នៅអំឡុងឆ្នាំ១៩៨៥ ឬឆ្នាំ១៩៨៦ កងទ័ពវៀតណាមក៏បានចុះមកទីតាំងបន្ទាយ និងមន្ទីរពេទ្យក្នុងភូមិសាទុំ គាស់យកសាកសពកងទ័ពវៀតកុងដែលបានកប់នៅក្បែរបន្ទាយ និងមន្ទីរពេទ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ សេចក្តីសង្ខេបរឿងរ៉ាវគ្រួសារនីមួយៗមានដូចខាងក្រោម៖

## ១. ឯម ប៉ាន់

ឯម ប៉ាន់ ភេទប្រុស អាយុ៨៣ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ ឯម ឡិប និងម្តាយឈ្មោះ ឡុក ឈុន។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ស្រីចំនួន២នាក់ និងប្រុសចំនួន៤នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ខ្វាន់ សៀង។ កូនរបស់ខ្ញុំទាំងអស់ចំនួន៩ នាក់ ស្រីចំនួន៣នាក់ និងប្រុសចំនួន៦នាក់។

កាលពីនៅតូចៗខ្ញុំរៀននៅសាលាវត្តក្រវៀនបានត្រឹមថ្នាក់អាទិដ្ឋាន និងថ្នាក់បរិវច្ឆនដ្ឋាន ខ្ញុំក៏បួសបានចំនួន៥វស្សា នៅវត្តក្រវៀន ហើយបួសជាភិក្ខុបានចំនួនមួយវស្សា។ ពេលដែលខ្ញុំសឹកមកវិញ ខ្ញុំក៏យកប្រពន្ធតែម្តង។ ខ្ញុំមានកូន៤នាក់ ក៏ចូលបម្រើជាកងទ័ពរបស់លន់ នល់ ដែលមានទីតាំងភ្នំពេញ-កំពង់ចាម។ ខ្ញុំបានទៅទទួលការហ្វឹកហ្វឺននៅឡាំសើុង ប្រទេសវៀតណាម។ ខ្ញុំទៅហាត់រៀនបានចំនួន៣ខែ ដែលបង្រៀនដោយយួនហាណូយ ចំណែកទាហានអាមេរិកជាអ្នកឈរមើល។ ការបង្រៀនមានដូចជារៀនផ្នែកចម្បាំង បាញ់កាំភ្លើង លូនក្រាប ប្រើកាំភ្លើងធំ។ ពេលដែលហាត់រៀនចប់ខ្ញុំក៏ត្រឡប់មកកំពង់ចាមវិញ។ ខ្ញុំមានតួនាទីកាន់កាំភ្លើងធំ១០៥មីលីម៉ែត្រ ដែលមានទីតាំងនៅស្តាតចាស់ ខេត្តកំពង់ចាម តែអាចប្រតិបត្តិការជុំវិញខេត្តកំពង់ចាម។ មួយរេស៊ីម៉ង់មាន៤ បាតាយ៉ុង ក្នុងមួយបាតាយ៉ុង មាន៤កុំប៉ាញី។ មួយកុំប៉ាញីមាន១៥០នាក់។ បើមានកម្លាំងពេញមួយរេស៊ីម៉ង់ ស្មើនឹង២៨០០នាក់។ មេបញ្ជាការរបស់ខ្ញុំឈ្មោះ ដួង ចាន់ហ៊ាន។ នៅកន្លែងកាំភ្លើងធំមានគ្នា៥នាក់ ដើម្បីផ្លាស់ប្តូរជួយបាញ់គ្នា។ កាំភ្លើងធំ១៥០មីលីម៉ែត្រ អាចបាញ់ចម្ងាយ៤០គីឡូម៉ែត្រ។ ពេលដែលមានសញ្ញាគេអូឲ្យបាញ់ទៅទិសខាងណាៗ ខ្ញុំក៏តម្រង់កាំភ្លើងទៅកាន់ទិសដែលផ្តល់សញ្ញា។ នៅឆ្នាំ១៩៧៣ មានការវាយប្រហារគ្នាខ្លាំង ពីសំណាក់យោធាខ្មែរក្រហម ទាល់តែមានម៉ារីនឡើងពីភ្នំពេញទៅជួយអន្តរាគមន៍ ទើបអាចយកឈ្នះកម្លាំងយោធាខ្មែរក្រហម។ កម្លាំងខ្មែរក្រហមក៏មានបាញ់មកក្បែរៗទីតាំងប៉ុស្តិ៍របស់ខ្ញុំដែរ។ ទាហាន លន់ នល់ ហៅ «ប៉ុស្តិ៍យាម» ថាជាទីតាំងសង់ទីយ៉ង់ ចំណែកខ្មែរក្រហមហៅថា មន្ទីរគយគន់។ ខ្ញុំនៅកាន់កាំភ្លើងធំរហូតដល់ឆ្នាំ១៩៧៥ បែកទីក្រុងកំពង់ចាម។ ពេល



ឯម ប៉ាំ ' ភេទប្រុស អាយុ៨៣ឆ្នាំ រស់នៅភូមិ សាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្ម។ ( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ដែលខ្ញុំទៅប្រចាំការនៅកំពង់ចាម ខ្ញុំយកប្រពន្ធនិងកូនទៅនៅជាមួយដែរ។

ពេលដែលបែកភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានដោះសម្លៀកបំពាក់ជាយោធាចេញ ហើយស្លៀកសម្លៀកបំពាក់ខ្មៅ។ ពេលដែលខ្ញុំធ្វើដំណើរពីកំពង់ចាមមកទឹកឆា បានជួបជាមួយយោធាខ្មែរក្រហម ពួកគេហៅខ្ញុំតែសមមិត្តទេ ព្រោះពាក់ខោអាវខ្មៅដូចគ្នា ហើយគេសួរថាមិត្តធ្វើអី? ខ្ញុំចេះតែឆ្លើយថាធ្វើជាកម្មករ។ ខ្ញុំមិនបានទៅត្រឡប់ទៅស្រុកកំណើតវិញទេ។ ខ្ញុំធ្វើដំណើររហូតដល់ភូមិតាឡីសង្កាត់គ។ ពេលទៅដល់ខ្មែរក្រហមឲ្យខ្ញុំធ្វើស្រែចំណែកខែប្រាំងឲ្យខ្ញុំឡើងត្នោត និងអារឈើ។ ដំបូងឡើយខ្មែរក្រហមដាក់ខ្ញុំជាប្រជាជនថ្មី ប៉ុន្តែដោយឃើញស្នាដៃខ្ញុំឡើងត្នោតបានទឹកត្នោតច្រើន និងរំងាស់ស្ករត្នោតបានច្រើនដែរ ហើយខ្ញុំអារឈើបានស្អាត ទើបក្រោយមកខ្មែរក្រហមឲ្យខ្ញុំស្មើភាពជាមួយប្រជាជនចាស់។ ក្រៅពីឡើងត្នោត ខ្ញុំធ្វើជាកងចល័តវែកដីមួយម៉ែត្រគូបនៅឯទំនប់បឹងគោក ហើយពេលខ្លះគេឲ្យខ្ញុំដឹកខសយកទៅឲ្យអ្នកវែកដី។ ពេលមួយដែលដឹកខសទៅ ត្រូវរន្ទះបាញ់ស្លាប់អ្នកដឹកខសនោះ។ នៅសង្កាត់គ ខ្ញុំធ្លាប់ឃើញមានមន្ទីរសន្តិសុខដែលឈ្មោះ មិត្តសុខ ធ្វើជាប្រធាន។ ឆ្នាំ១៩៧៩ រៀបនឹងបែកទីក្រុងភ្នំពេញ មិត្តសុខបានយកឆ្អឹងខ្មោចដែលសម្លាប់ហើយ យកមកចាក់ប្រេងដុតចោល។ នៅពេលដែលរបបខ្មែរក្រហមដួលរលំ ខ្ញុំធ្វើជាអាចារ្យ និងប្រមូលលោកបាន ៣អង្គ មកនៅវត្តដីដុះ។ នៅឆ្នាំ១៩៨៣ ទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញ ហើយធ្វើចម្ការរហូតដល់សព្វថ្ងៃ។

## ២. ទិត្យ យាន់

ទិត្យ យាន់ ភេទស្រី អាយុ៧៨ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃនេះខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ភ្លុយ (ស្លាប់) និងមានម្តាយឈ្មោះ ខ្វ (ស្លាប់)។ ខ្ញុំមានបងប្អូន៧ នាក់ (ប្រុស១នាក់ ស្រី៦នាក់) ខ្ញុំជាកូនទី៤។ ប្តីរបស់ខ្ញុំឈ្មោះ ហន មានកូន៧ នាក់ (ប្រុស២នាក់ ស្រី៥នាក់)។ កាលពីខ្ញុំនៅក្មេង ខ្ញុំមិនបានរៀនសូត្រនោះទេ ព្រោះកាលនោះមិនមានសាលាដូចសម័យនេះ។ បើខ្ញុំចង់រៀនត្រូវទៅរៀននៅវត្ត ហើយមានមនុស្សតិចតួចណាស់បានរៀន ភាគច្រើនមានតែសិស្សប្រុស។ ខ្ញុំនៅផ្ទះមើលប្អូន និងជួយធ្វើស្រែចម្ការឪពុក ម្តាយរបស់ខ្ញុំបន្តិចបន្តួច។ ក្រោយមកមិនបានប៉ុន្មាន ខ្ញុំអាយុ២០ឆ្នាំ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ ហើយយើងមានកូនម្នាក់។ នៅឆ្នាំ១៩៧០ ខ្ញុំឮអ្នកភូមិនិយាយពីរឿងបាតុកម្មទម្លាក់សម្តេច សីហនុ នៅមេមត់ ប៉ុន្តែអ្នកភូមិរបស់ខ្ញុំមិនបានទៅចូលរួមជាមួយគេទេ។ បន្តពីនេះមិនបានប៉ុន្មាន នៅជិតៗភូមិរបស់ខ្ញុំមានគ្រាប់របស់ទាហានអាមេរិកទម្លាក់លើទីតាំងទាហានវៀតកុង។ វៀតកុងតែងតែលាក់ខ្លួននៅតាមព្រៃនៃភូមិរបស់ខ្ញុំ អ្នកភូមិនៅពេលឮសំឡេង គ្រាប់ផ្លោងម្តងៗ តែងនាំគ្នារត់ចូលក្នុងរណ្តៅមិនថាថ្ងៃមិនថាយប់នោះទេ។ សង្គ្រាមអាមេរិកបានបញ្ចប់ទៅមិនបានប៉ុន្មានផង ស្រាប់តែរបប ប៉ុល ពត



ទិត្យ យាន់ ភេទស្រី អាយុ៧៨ឆ្នាំ រស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កំពុងរៀបរាប់រឿងរ៉ាវរបស់គាត់ទៅកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និងកូនចៅរបស់គាត់ ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មួយទៀតមកដល់។ ឆ្នាំ១៩៧៥ ក្នុងភូមិរបស់ខ្ញុំត្រូវបានខ្មែរក្រហមបង្គាប់ឲ្យធ្វើស្រែប្រវាស់ដៃ។ បន្ទាប់ពីប្រមូលផលបាន អ្នកភូមិត្រូវដាក់ជារួម ប៉ុន្តែមិនបានកម្រៃជារបស់ខ្លួនទេ។ ពេលនោះអ្នកភូមិក៏បានហូបរួមជាមួយគ្នា។ ធ្វើការប្រវាស់ដៃបាន១ឆ្នាំ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងគ្រួសាររបស់ខ្ញុំទៅស្រុកសំបូរ ខេត្តក្រចេះ។ ខ្ញុំរស់នៅក្នុងភូមិកោះរៀល។ នៅទីនោះខ្ញុំបានហូបគ្រប់គ្រាន់មួយថ្ងៃ ៣ពេល។ កាលនោះខ្ញុំត្រូវបានខ្មែរក្រហមមិនឲ្យខ្ញុំធ្វើការទេព្រោះខ្ញុំកំពុងកូនខ្ចីកូនទី៣ ចំណែកប្តីរបស់ខ្ញុំខ្មែរក្រហមបានឲ្យគាត់ទៅដាំដំណាំ ដូចជាពោត ចេក។ ខ្ញុំរស់នៅភូមិកោះរៀលបាន១ខែ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅស្រុកស្ទឹងត្រង់។ ខ្ញុំសម្រាកនៅទីនោះបាន៣យប់ ក៏ជិះកាណូត



ស្បោង អ៊ុច ភេទស្រី អាយុ៧៦ឆ្នាំ រស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកកំពង់ចាមវិញ។ ខ្ញុំដើររហូត ៥ថ្ងៃ ទើបមកដល់ស្រុកមេមត់។ ខ្ញុំដើរពីមេមត់រហូតមកដល់ស្រុកកំណើតភូមិសាទុំវិញ។ ក្រោយពេល ខ្ញុំមកដល់ស្រុកណើតវិញ ផ្ទះរបស់ខ្ញុំ ព្រៃដុះជុំវិញ និងឆេះអស់គ្មានសល់ឡើយ។ ខ្ញុំនិងប្តីរបស់ខ្ញុំបាននាំគ្នា កាប់ឆ្ការព្រៃ និងទៅរកទិញស្រូវពូជពីវៀតណាម យកមកធ្វើពូជ និងដាំដំណាំ ធ្វើចម្ការរហូតមកដល់សព្វថ្ងៃ។

## ៣. ស្បោង អ៊ុច

ស្បោង អ៊ុច ភេទស្រី អាយុ៧៦ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ស្បោង និងម្តាយឈ្មោះ យ៉ាប។ ខ្ញុំមានបងប្អូនទាំងអស់ចំនួន ៨នាក់ ស្រីចំនួន៧នាក់ និងប្រុសចំនួន១នាក់។ សព្វថ្ងៃនៅសល់តែស្រី ៣នាក់ប៉ុណ្ណោះ។ គ្រួសារទី១ឈ្មោះ ប៊ុន ស្លាប់នៅជំនាន់ខ្មែរក្រហម។ គ្រួសារទី២ ឈ្មោះ ឈីន ស្លាប់ដោយសារជំងឺ។ ខ្ញុំមានកូន៦នាក់ ស្រីចំនួន ៣នាក់ និងប្រុសចំនួន៣នាក់ ប៉ុន្តែស្លាប់អស់ស្រី២នាក់ ដោយសារជំងឺកញ្ច្រិលនៅសម័យខ្មែរក្រហម។ សព្វថ្ងៃខ្ញុំនៅសល់កូន៤នាក់ ស្រីចំនួន១នាក់ និងប្រុស៣នាក់។

កាលពីនៅតូចៗ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះតែគ្មានសាលារៀននៅក្បែរផ្ទះ បើចង់រៀនត្រូវទៅរៀននៅវត្ត ហើយនៅឆ្ងាយពីផ្ទះទៀត។ ខ្ញុំធ្លាប់ឃើញនៅចម្ការកៅស៊ូរបស់បារាំងនៅមេមត់ សុទ្ធតែកម្មករជាជនជាតិវៀតណាម ពេលដែលខ្ញុំបររទេះគោជាមួយឪពុកទៅផ្សារមេមត់ រកដូរអំបិល ប្រហុកយកមកភូមិវិញ។ ខ្ញុំរៀបការតាំងពីជំនាន់សម្តេចសីហនុ ហើយខ្ញុំបានកូន៤នាក់នៅពេលដែលមានការទម្លាក់គ្រាប់បែកពីសំណាក់កងទ័ពអាមេរិក ដើម្បីតាមរកទាហានវៀតកុង។ អ្នកភូមិផ្សេងទៀត ក៏ដូចជាគ្រួសារខ្ញុំដែរ បានរត់គេចពីការទម្លាក់គ្រាប់បែករហូតទៅដល់ស្រែកណ្តាល ស្រែសោម ខាងជើងមេមត់។ ខ្ញុំរស់នៅភូមិស្រែសោមបានមួយឆ្នាំ ទើបត្រឡប់មកភូមិសាទុំវិញ។ ពេលដែលត្រឡប់មកភូមិ ខ្ញុំដាំស្រូវបាន ២ឆ្នាំ ទើបមានចលនាខ្មែរក្រហមចូលមកក្នុងភូមិ បំផុសប្រជាជនឲ្យធ្វើស្រែប្រវាស់ដៃ។ ពេលដែលប្រមូលផលមកដាក់រួមហើយប្រធានក្រុមចែកចំណែកតាមគ្រួសារ។ រហូតដល់ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមចូលគ្រប់គ្រងពេញលេញ ហើយប្រមូលរបស់របរដាក់រួម ព្រមទាំងហូបបាយរួម ធ្វើស្រែប្រមូលផលដាក់

រួមៗ របបអាហារដែលខ្មែរក្រហមចែកឲ្យគឺស្ងោរចេកលាយជាមួយបាយ ពេលខ្លះហូបបបរ ចំណែកប្រុសៗខ្មែរក្រហមឲ្យហូបបាយឆ្អែតហើយទៅកាប់រណ្តៅនៅព្រែកតាអុង។

នៅពេលដែលខ្មែរក្រហមចោទអ្នកភូមិថាក្បាលយួន ខ្លួនខ្មែរហើយ ខ្មែរក្រហមបានជម្លៀសប្រជាជនក្នុងភូមិទាំងអស់ឲ្យទៅខេត្តក្រចេះ។ ពេលដែលដល់ខេត្តក្រចេះ កូនរបស់ខ្ញុំបានកើតជំងឺកញ្ជ្រិលស្លាប់អស់២នាក់ ព្រោះតែគ្មានថ្នាំព្យាបាល និងរបបអាហារហូបមិនគ្រប់គ្រាន់។ ប្តីរបស់ខ្ញុំក៏មានជំងឺគ្រុនចាញ់ហើយស្លាប់នៅខេត្តក្រចេះដែរ។ ចំណែកខ្ញុំខ្មែរក្រហមឲ្យទៅកាប់ឆ្ការព្រៃដើម្បីដាំស្រូវ ចំណែករបបអាហារក៏ហូបមិនគ្រប់គ្រាន់។ ក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅដល់ថ្មគ្រែ និងជិះកាណូតបន្តមកស្រុកស្ទឹងត្រង់។ ខ្ញុំមករស់នៅបុសខ្នុរបានមួយខែ កងទ័ពវៀតណាមក៏ចូលមកដល់ និងប្រកាសឲ្យប្រជាជនត្រឡប់ទៅស្រុកកំណើតវិញ។ ខ្ញុំនិងកូនបានត្រឡប់មកស្រុកកំណើតវិញ ហើយកាប់ឆ្ការដីដើម្បីដាំស្រូវ ដែលបានស្រូវពូជពីវៀតណាម នៅពេលខ្ញុំទៅស៊ីឈ្នួលវៀតណាម ដោយទទួលបានស្រូវមួយគីឡូក្នុងមួយថ្ងៃ។ ខ្ញុំចេះបញ្ជូនអារក្ស បើគេរកមើលទៅថាខុសអារក្សព្រៃភ្នំ គឺគេមកអញ្ជើញខ្ញុំឲ្យបញ្ជូនអារក្សនៅវាលស្រែ នៅព្រៃ ត្រូវមានភ្លេង និងត្រូវមានបាយដំណើប មានមាន់ស្ងោរ សាច់ជ្រូក ស្រាសទឹកផ្អែមៗ ហើយពេលខ្លះក៏មានគេមករកបញ្ជូនទៅផ្ទះដែរ ព្រោះតែគេមានបងប្អូនឈឺព្យាបាលនៅពេទ្យមិនជា ទើបគេមករកថាខុសអី ដើម្បីងាយស្រួលរៀបចំឲ្យត្រូវតាមអ្នកដែលគេចង់បាន។ ចំណែកដង្វាយនៅផ្ទះមានតាមសទ្ធា ៥ពាន់ ឬមួយម៉ឺនរៀល។ រាល់ខែមីនា រៀងរាល់ ៣ឆ្នាំម្តង ត្រូវលេងភ្លេងឡើងអារក្សនៅផ្ទះរបស់ខ្ញុំ។

## ៤. ឯម សុគន្ធ

ឯម សុគន្ធ ភេទស្រី អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ ម្តាយរបស់ខ្ញុំឈ្មោះ ឡូ ឈុន និងឪពុកឈ្មោះ ឯម លីប។ ខ្ញុំមានបងប្អូនចំនួន៧នាក់ ស្លាប់បីនាក់ នៅរស់បួននាក់ ។ បងប្អូនរបស់ខ្ញុំបីនាក់ស្លាប់នៅក្នុងអំឡុងពេលសង្គ្រាម។ កងទ័ពអាមេរិកចូលមកដល់ក្នុងភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំរកពួកវៀតកុងដែលមកលាក់ខ្លួននៅក្នុងទឹកដីប្រទេសកម្ពុជា។ ពួកវៀតកុងបានបោះទីតាំងនៅក្នុងភូមិសាទុំ និងមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺនៅក្នុងព្រៃ។ វៀតកុងបានលាក់ខ្លួននៅតាមអូរក្បាលជ្រៃ កញ្ជន់ បុស្សសំព័រ។ ប្រជាជនភាគច្រើនយកអង្ករលក់ទៅឲ្យពួកវៀតកុង។ គ្រួសាររបស់ខ្ញុំពេលព្យុះគ្រាប់កាំភ្លើង និងគ្រាប់បែកម្តងៗបានរត់ចូលទៅពួននៅក្នុងរណ្តៅដែលគ្រួសាររបស់ខ្ញុំ បានជីកលាក់ខ្លួន ។ ពេលឈប់ព្យុះគ្រាប់ទើបខ្ញុំត្រឡប់ចូល



ឯម សុគន្ធ ភេទស្រី អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្ទះវិញ។ ដល់ឆ្នាំ ១៩៧៥ ខ្ញុំត្រូវធ្វើការងារប្រវាស់ដៃនៅក្នុងភូមិសាទុំ។ ខ្ញុំការហូបចុកទៅតាមផ្ទះរៀងខ្លួន។ ក្រោយមកទៀត ទើបអង្គការបង្កើតជាសហករណ៍ឲ្យប្រជាជនហូបរួម ដេករួម ធ្វើការងាររួមជាមួយគ្នា។ ខ្ញុំមានអាយុ១៧ឆ្នាំ ត្រូវបានអង្គការជ្រើសតាំងឲ្យទៅធ្វើការងារនៅតាមកងចល័ត។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនបាននៅក្នុងភូមិសាទុំទៀតទេ គឺអង្គការចាត់តាំងឲ្យទៅនៅភូមិក្រវៀន។ នៅទីនោះ អង្គការឲ្យខ្ញុំធ្វើស្រែ ស្ទូងស្រូវ ដកសំណាប បានពីរបីខែក៏ជម្លៀសខ្ញុំឲ្យទៅនៅភូមិខ្វូរ ចេញពីភូមិខ្វូរខ្ញុំទៅនៅភូមិជ្រៃឡើង។ បន្ទាប់មកខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅនៅមេមត់ និងអណ្តូងថ្ម។ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំនៅតាមក្រុម គឺក្នុងក្រុម(ក)។ ការហូបចុករបស់ខ្ញុំ គឺមានពេលថ្ងៃត្រង់ និងពេលល្ងាច។ អាហារភាគច្រើន គឺបបរលាយចេក លាយពោតដោយមនុស្សម្នាក់ទទួលបានមួយវែង ឬកន្លះចាន។ ក្រោយមកទៀត ខ្មែរក្រហមជម្លៀសខ្ញុំចេញទៅខេត្តក្រចេះ។ ពេលទៅដល់ ស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ខ្មែរក្រហមប្រើឲ្យខ្ញុំធ្វើស្រែ ស្ទូងស្រូវ ធ្វើទំនប់ ដែលជាការងារធ្ងន់ហើយគ្មានពេលឈប់សម្រាក។ តមកទៀត ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅនៅភូមិតាពុំ និងតាប៉ាង។ ខ្ញុំធ្វើការងារទាំងយប់ ប្រសិនបើអត់បានធ្វើការងារទេ ប្រធានសហករណ៍មិនឲ្យហូបបាយឡើយ។ នៅទីនោះ អង្គការឲ្យខ្ញុំធ្វើស្រែ ធ្វើទំនប់ លើកប្រព័ន្ធភ្លឺស្រែ។ ខ្ញុំនៅបានពីរបីខែ ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅនៅភូមិចឹង។ នៅទីនោះមានមនុស្សស្លាប់ជាច្រើន ភាគច្រើនសុទ្ធតែអត់បាយ។ ចាប់តាំងពីខ្មែរក្រហមជម្លៀសខ្ញុំចេញពីស្រុកភូមិមក ខ្ញុំមិនដែលបានជួបឪពុកម្តាយទេ ព្រោះអំឡុងពេលជម្លៀស ខ្មែរក្រហមមិនឲ្យខ្ញុំបានទៅជួបជុំគ្រួសារឪពុកម្តាយទេ។ ខ្មែរក្រហមមិនឲ្យខ្ញុំទៅសួរសុខទុក្ខ ឬទៅលេងគ្រួសារទេ។ អំឡុងពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីភូមិ ទៅនៅខេត្តក្រចេះ គឺមានប្រជាជននៅឃុំជាំក្រវៀន ឃុំជាំតាម៉ៅ ឃុំទន្លូង អង្គការមិនអនុញ្ញាតឲ្យមនុស្សកំលោះក្រមុំនិយាយជាមួយគ្នាមួយទល់មួយនោះទេ ដោយខ្លាចខុសសីលធម៌។ មុនពេលទៅធ្វើការប្រធានកងបានហៅប្រជុំគ្នាជាមុន ប្រាប់អំពីការងារដែលត្រូវធ្វើ។ ក្រោយមកទៀត ខ្មែរក្រហមជម្លៀសខ្ញុំទៅនៅភូមិជយោ ភូមិស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាម។ ពេលខ្ញុំទៅដល់ខេត្តកំពង់ចាមស្រូវចាប់ផ្តើមទុំ ដូច្នេះអង្គការចាត់តាំងឲ្យប្រជាជនទៅច្រូតស្រូវ។ នៅទីនោះខ្ញុំបានហូបបាយឆ្អែត ដោយមួយថ្ងៃបានបីពេល គឺពេលព្រឹក ពេលរសៀល និងពេលល្ងាច។ ខ្ញុំនៅទីនោះបាន២ទៅ៣ខែស្រាប់តែឃើញទាហានវៀតណាមចូលមកដល់ ហើយឲ្យខ្ញុំត្រឡប់ទៅស្រុករបស់យើងវិញ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើង។ មុនពេលចេញមក វៀតណាម បានបើកអង្ករឲ្យ ដោយអ្នកខ្លះច្រើន អ្នកខ្លះតិចទៅតាមកម្លាំងដែលអាចយកទៅរួច។ ខ្ញុំដើរបានប្រមាណជាកន្លះខែ ទើបដល់ភូមិវិញ។ ខ្ញុំឃើញសុទ្ធតែព្រៃដុះជុំវិញភូមិ និងផ្ទះសម្បែងត្រូវបានភ្លើងឆេះអស់។ ពេលមកដល់ ខ្ញុំមិនទាន់មានអង្ករហូបគ្រប់គ្រាន់ទេ គ្រួសារខ្ញុំនាំគ្នាជីកដំឡូងយកមកហូប។ ប្រជាជនខ្លះយកមាសទៅដូរយកពូជស្រូវមកដាំ។ រយៈពេលពីរឆ្នាំក្រោយមក ទើបខ្ញុំមានស្រូវហូបគ្រប់គ្រាន់។

## ៥. ពល សារ៉ន

ពល សារ៉ន ភេទស្រី អាយុ៨៣ឆ្នាំ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ទាន់ ពល (ស្លាប់) និងមានម្តាយឈ្មោះ ទេញ (ស្លាប់)។ ខ្ញុំមានបងប្អូន៥ នាក់ (ស្រី៤នាក់ និងប្រុស១នាក់)។ ប្តីរបស់ខ្ញុំឈ្មោះ អៀនជា។ ខ្ញុំមានកូន ១១នាក់ (ស្រី ៥ នាក់ ប្រុស ៦ នាក់)។ កាលពីនៅក្មេង ខ្ញុំមិនបាន



ពល សារ៉ន ភេទស្រី អាយុ៨៣ឆ្នាំ រស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មៗ
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

រៀនសូត្រទេ ព្រោះសាលារៀនមានតែក្នុងវត្ត ភាគច្រើនមានតែប្រុសៗ បានទៅរៀនៗ ខ្ញុំនៅផ្ទះជួយធ្វើស្រែ ចម្ការ ម្តាយឪពុករបស់ខ្ញុំៗ នៅពេលបានផលយើងយកទៅលក់នៅមេមត់បានមួយគី ឡូបីរៀលៗ ក្រោយមកទៀតខ្ញុំបានទៅធ្វើជាកម្មករចៀរជ័រកៅស៊ូឲ្យបារាំង ជាមួយឪពុករបស់ខ្ញុំៗ បារាំងបានឲ្យខ្ញុំ និងឪពុករបស់ខ្ញុំយាមរោងមួយ ដែលជាកន្លែងសម្រាប់សម្រាកៗ កម្មករចម្ការកៅស៊ូបារាំង ភាគច្រើនជាជនជាតិវៀតណាមៗ ខ្ញុំបានប្រាក់ខែពីបារាំងប្រាំពីររៀលៗ ខ្ញុំធ្វើកម្មករចៀរជ័រនៅ ខ្លាយ បាន១ឆ្នាំ ទើបខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំ និងមានកូន៣នាក់ៗ

ឆ្នាំ១៩៧០ កងទ័ពអាមេរិកចូលមកដល់ក្នុងភូមិរបស់ខ្ញុំ និងមានគ្រាប់ផ្លោងទៀតផងៗ ខ្ញុំនិងគ្រួសារបាននាំគ្នារត់ទៅភូមិរលឹមៗ នៅដើមឆ្នាំនោះ១៩៧០ នៅមេមត់មានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ហើយប្តីរបស់ខ្ញុំមានបំណងទៅចូលរួមបាតុកម្មតវ៉ាជាមួយគេដែរ ប៉ុន្តែនៅពេលទៅដល់ពាក់កណ្តាលផ្លូវ មានអ្នកប្រាប់ថា កុំទៅអីមានមនុស្សស្លាប់ច្រើនណាស់ៗ ប្តីរបស់ខ្ញុំក៏បានត្រឡប់មកភូមិរលឹមវិញៗ នៅពេលនោះមានការទម្លាក់គ្រាប់បែកខ្លាំង ទាំងយប់ ទាំងថ្ងៃ ដូច្នេះខ្ញុំនិងប្តីបររទេះទៅនៅស្រែដីរីផុងៗ ក្រោយមកខ្ញុំបានត្រឡប់មកស្រុកកំណើតភូមិសាទុំវិញៗ បន្ទាប់ពីមកដល់ផ្ទះវិញ ខ្ញុំធ្វើចម្ការ ស្រែធម្មតាៗ ខ្មែរក្រហមចូលមកដល់ក្នុងភូមិ ហើយបានឲ្យអ្នកភូមិធ្វើស្រែប្រវាស់ដៃៗ បន្ទាប់ពីប្រវាស់ដៃ មិនបានប៉ុន្មាន អ្នកភូមិត្រូវបានខ្មែរក្រហមឲ្យហូបរួមៗនៅម៉ោង១១ ខ្មែរក្រហមគោះជួង ហៅប្រជាជនឲ្យទៅហូបបាយនៅមន្ទីរកិនស្រូវៗ ខ្មែរក្រហមឲ្យអាហារយើង៣ពេល ព្រឹក, ថ្ងៃត្រង់ និងល្ងាចៗ កាលនោះខ្ញុំមិនបាននៅជុំគ្រួសារទេ ព្រោះប្តីរបស់ខ្ញុំត្រូវបានចាត់តាំងទៅធ្វើការកន្លែងផ្សេង គឺលើកប្រព័ន្ធភ្លឺស្រែ និងបិទទំនប់ៗ ចំណែកកូនរបស់ខ្ញុំ ខ្មែរក្រហមឲ្យទៅរើសអាចម៌គោៗ កូនស្រីម្នាក់ទៀត ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យទៅធ្វើពេទ្យនារីៗ កាលនោះខ្មែរក្រហមបានបង្រៀនចាស់ៗនៅក្នុងភូមិ ខ្ញុំក៏បានចូលរៀនដែរៗ ខ្មែរក្រហមបង្រៀនខ្ញុំឲ្យសរសេរអក្សរ, ក, ខ និងបង្រៀនឲ្យចេះប្រកបអក្សរៗ ខ្មែរក្រហមបានបើកខ្មៅដៃ និងសៀវភៅឲ្យចាស់ៗៗ ខ្មែរក្រហមបង្រៀន ខ្ញុំកន្លះម៉ោង បន្ទាប់ពីហូបបាយរួច និងបានបង្រៀនឲ្យចេះសរសេរថា " បងៗយោធាជិះនាវាការពារកោះ"ៗ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅឃុំក្រវៀនៗ នៅពេលទៅដល់ទីនោះ ខ្មែរក្រហមឲ្យខ្ញុំដាំទំពាំ និងចេកៗ ខ្ញុំនៅមិនបានប៉ុន្មានខ្មែរក្រហមជម្លៀសទៅក្រចេះៗ នៅទីនោះ បងប្រុសខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែ និងលើកប្រព័ន្ធភ្លឺ ប្រសិនបើលើកមិនហើយតាមផែនការ ខ្មែរក្រហមព្រមានៗ នៅទីនោះមិនបានប៉ុន្មានផង ខ្មែរក្រហមជម្លៀសខ្ញុំតាមកាណូតទៅអូរស្ពឺ រួចជិះឡានដែលបើកដោយវៀតណាមៗ ក្រោយពីស្នាក់នៅ ទន្លេបិទ

៣យប់ ខ្ញុំបានជិះឡានជាមួយវៀតណាមទៅមេមត់។ មកដល់មេមត់ ខ្ញុំបានដើររយៈពេល៣ថ្ងៃ មកភូមិសាទុំវិញ។ នៅពេលមកដល់ផ្ទះ ខ្ញុំបានដាំបន្លែ ពោត ស្រូវ និងបានធ្វើស្រែរហូតមកដល់សព្វថ្ងៃនេះ។

## ៦ - យិន សាន

យិន សាន ភេទប្រុស អាយុ៨៧ឆ្នាំ បច្ចុប្បន្ននៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ ឪពុក ឈ្មោះ យិន ហើយម្តាយឈ្មោះ ញៀន គាត់ទាំងពីរបានស្លាប់អស់ ។ ខ្ញុំមានបងប្អូនចំនួនពីរនាក់ ខ្ញុំជាកូនទីមួយ ចំណែកប្អូនស្រីជាកូនទីពីរ មានឈ្មោះ យិន សារិន។ ខ្ញុំមានកូនពីរនាក់ ស្រីម្នាក់និងប្រុសម្នាក់ សព្វថ្ងៃរស់នៅជាមួយកូនស្រីពៅ ។ កាលពីកុមារភាព ខ្ញុំអត់បានសិក្សារៀនសូត្រទេ ព្រោះកាលនោះអត់មានគ្រូបង្រៀនម៉្យ ុំរស់នៅក្នុងទឹកដីវៀតណាម ភូមិទឹកជៀត ស្រុក ឡុកនិញ ខេត្តបិន ឡុង។



យិន សាន ភេទប្រុស អាយុ៨៧ឆ្នាំ បច្ចុប្បន្ននៅ ភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងភរិយា។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅទីនោះមានសង្គ្រាមខ្លាំងរវាងអាមេរិក និងយៀកកុង។ អាមេរិកចូលមកទម្លាក់គ្រាប់បែកកន្លែងដែលខ្ញុំរស់នៅ ដែលធ្វើឲ្យប្រជាជននៅទីនោះមានរបួស និងស្លាប់។ ពេលដែលឮសូរគ្រាប់ទាំគ្នាលាក់ខ្លួននៅក្នុងរណ្តៅដែលបានជីកទុកសម្រាប់លាក់ខ្លួន ទាល់តែឈប់ឮសូរគ្រាប់ទើបចេញពីរណ្តៅរួចត្រឡប់ទៅផ្ទះវិញ។ កាលពីមុនមានវត្តខ្មែរ ប្រជាជនប្រកបរបរធ្វើស្រែចម្ការធម្មតា ខ្ញុំថាពីដើមជាទឹកដីរបស់ខ្មែរ ព្រោះកាលមុនមានប្រជាជនខ្មែររស់នៅចំនួន៦ភូមិ នៅក្នុងមួយភូមិមាន៣០ទៅ៤០គ្រួសារ។ មានពួកយៀកកុងខាងជើងនិងធីវគីខាងត្បូងបានធ្វើសង្គ្រាម ហើយបានវាយជាមួយខ្មែរដែរ។ អំឡុងពេលសង្គ្រាមមានសល់គ្រាប់មីនពេញផ្ទៃដី ខ្ញុំត្រូវបានពិការជើងម្ខាងដោយសារជាន់មីន ខ្ញុំថាដើរទៅទាក់ខ្សែមីនរបស់ពួកយៀកកុង។ ពេលខ្ញុំដើរមានគ្នាចំនួនបីនាក់ តែពីរនាក់ទៀតអត់មានត្រូវរបួសអ្វីទេ ខ្ញុំឆ្ងល់ថាម៉េចបានត្រូវគ្រាប់តែខ្ញុំម្នាក់ឯងវិញ។ ខ្ញុំមិនបានទៅពេទ្យសម្រាប់ព្យាបាលទេ មានតែប្រើប្រាស់ថ្នាំខ្មែរប៉ុណ្ណោះ អត់មានពេទ្យកាត់ជើងខ្ញុំទេ តែប្រើថ្នាំខ្មែរយូរៗទៅជើងខ្ញុំស្អុយរលួយដាច់ខ្លួនឯង។ ដោយសារតែទាហានអាមេរិកអុកឡុកខ្លាំងពេក ទើបខ្ញុំចេញពីវៀតណាម មករស់នៅភូមិសាទុំវិញ។ ប្រជាជនភាគច្រើន រកស៊ីស្រែចំការ អ្នកខ្លះមកលក់អង្ករទៅឲ្យយៀកកុង ព្រោះមានកងទ័ពនៅតាមព្រៃ តាមព្រំប្រទល់។ ក្រោយពេលបាតុកម្មបានពីរឆ្នាំស្រាប់តែគាត់មករស់នៅ ភូមិសាទុំ ជាមួយម្តាយមីងវិញ។

នៅក្នុងសម័យខ្មែរក្រហមគេចាប់ឲ្យខ្ញុំរៀបការ មុនពេលរៀបការគេប្រាប់តែមួយថ្ងៃប៉ុណ្ណោះ ប្រាប់ថាត្រៀមខ្លួនទៅព្រឹកស្អែករៀបការ។ ខ្ញុំជាកំលោះចាស់មានអាយុ៣៥ឆ្នាំ ព្រោះខ្ញុំពិការជើងសម័យអាមេរិក ទើបគ្មានអ្នកយកខ្ញុំ។ ពេលព្រឹកឡើងខ្ញុំបានទៅកន្លែងគេចាប់គូ ហើយខ្មែរក្រហមឲ្យអង្គុយទល់មុខគ្នា ខ្ញុំមានអារម្មណ៍រំភើប ភ័យដោយសារមិនធ្លាប់មានគូ។

ខ្ញុំនិយាយក្នុងចិត្តថាអាចចិញ្ចឹមគេរស់ដែរឬទេ? ក្នុងចំណោមនោះមានចំនួន៣៨គូ ខ្ញុំជាគូទី៥។ ពេលរៀបការ ខ្មែរក្រហមបានជប់លៀងកាប់គោមួយក្បាល និងជ្រូកបីក្បាលនាំគ្នាសប្បាយនៅទីនោះ ខ្ញុំមិនបាននៅជប់លៀងទេ គេឲ្យទៅផ្ទះរួចហូបបាយក្នុងផ្ទះ។ ប្រពន្ធរបស់ខ្ញុំពេលនោះមានអាយុ២៨ឆ្នាំ គាត់ធ្លាប់រៀបការម្តងរួចមកហើយ។ ក្រោយមកខ្មែរក្រហមឲ្យខ្ញុំបានឈប់សម្រាកពីការងារបីថ្ងៃ និងមានឈ្លបមកចាំលួចមើល ដើម្បីតាមដានថាខ្ញុំនិងគ្រួសារចុះសម្រុងគ្នាឬអត់។ ខ្ញុំជាអ្នកនិយាយរកប្រពន្ធមុន។ ក្រោយមកទៀត ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំចេញពីភូមិសាទុំ ឲ្យនៅទន្លេ ភូមិសោយប៉ើស រការខ្នុរ។ ប្រពន្ធរបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យធ្វើស្រែស្ទូង ស្រូវ។ ចំណែកខ្ញុំជាជនពិការជើងម្ខាង ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើបង្គី កន្ត្រកជាមួយមនុស្សចាស់ៗ។ នៅទីនោះមានប្រជាជនខ្មែរ និងប្រជាជនចាម ពីផ្ទះខ្ញុំទៅកន្លែងធ្វើការចម្ងាយ៥ម៉ែត្រ ខ្ញុំដើរបានដោយសារកាន់ឈើច្រត់។ ចំពោះអាហារមានពីរពេល គឺពេលព្រឹកនិងពេលល្ងាច មានតែបបរលាយជាមួយទឹក ក្នុងម្នាក់១ទៅ២វែក ហើយខ្មែរក្រហមមិនឲ្យហូបអ្វីផ្សេងទេ។ ប្រធានក្រុមជាជនជាតិចាម ដែលជាអ្នកគ្រប់គ្រង។ អ្នកដែលរកត្រីសាច់បានត្រូវយកទៅសហករណ៍ បើយកទុកហូបតែម្នាក់ឯង ប្រធានក្រុមដឹងគេយកទៅកសាង ។ ខ្ញុំឃើញគេចាប់មនុស្ស៣ទៅ៤នាក់ឡើងលើរទេះ អ្នកទាំងនោះសុទ្ធតែប្រជាជនចាស់ ហើយអ្នកភូមិនិយាយថា គេយកទៅសម្លាប់ចោល។ នៅភូមិសោយបានមួយឆ្នាំខ្មែរក្រហមចាប់ផ្តើមជម្លៀសដល់ ភូមិតាពុំតាប៉ាំង ឃុំឈូក ស្រុកក្រូចឆ្មា នៅទីនោះគេឲ្យខ្ញុំធ្វើ បង្គីរ កន្ត្រក កញ្ជើរ ល្អីដដែល ។ ប្រធានដែលគ្រប់គ្រងក៏ពិការដែរ ។ ពេលគេរំដោះបានខ្ញុំនៅ ភូមិតាប៉ាំង ឃុំឈូក ស្រុកក្រូចឆ្មារ។ ខ្ញុំរស់នៅទីនោះរហូតមានអាយុ៤ឆ្នាំ ទើបនាំប្រពន្ធកូនត្រឡប់ទៅស្រុកកំណើតវិញ ។ មកដល់ភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខ្ញុំចាប់ផ្តើមធ្វើផ្ទះកាប់ឆ្ការព្រៃដើម្បីបានដីដាំដំណាំ ។ ពូជស្រូវបានមកពីវៀតណាម ដែលដូរមាសខ្លះ ដូរកម្លាំងខ្លះ។ ឥឡូវខ្ញុំពិការជើងម្ខាង ខាងឆ្វេង កាលសម័យអាមេរិក ហើយខ្ញុំងងឹតភ្នែកទាំងសងខាងរយះពេលបីឆ្នាំ។

## ៧ - សឹម ធន

សឹម ទន ភេទប្រុស អាយុ៧៥ឆ្នាំ មានស្រុកកំណើតនៅស្រុកកូនទ្រាំង ខេត្តតាយនិញ ប្រទេសវៀតណាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ សឹម ចំណែកម្តាយឈ្មោះ ប្រុស។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ស្រីចំនួន២នាក់ និងប្រុសចំនួន៣នាក់។ បងស្រីខ្ញុំម្នាក់ស្លាប់នៅឆ្លូង ក្នុងជំនាន់ខ្មែរក្រហម ចំណែកបងប្រុសស្លាប់ធ្វើទាហានឲ្យអាមេរិកកាំង ស្លាប់នៅប្រទេសវៀតណាម។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សូ សារឿន




សឹម ទន ភេទប្រុស អាយុ៧៥ឆ្នាំ មានស្រុកកំណើតនៅស្រុកកូនទ្រាំង ខេត្តតាយនីញ ប្រទេសវៀតណាម។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំគ្មានកូនទេ។ ខ្ញុំបានរត់មកស្រុកខ្មែរនៅឆ្នាំ១៩៦២ ដល់១៩៦៣ ព្រោះតែនៅប្រទេសវៀតណាមកំពុងតែមានសង្គ្រាមខ្លាំង ហើយរបបអាហារចែកឲ្យម្នាក់កន្ទះកំប៉ុងក្នុងមួយពេល។ ខ្ញុំគិតថាបើនៅប្រទេសវៀតណាម ខ្ញុំច្បាស់ជាស្លាប់មិនខាន ខ្ញុំក៏ប្រថុយរត់មកស្រុកខ្មែរជាមួយមិត្តភក្តិខ្ញុំម្នាក់ (មិនចាំឈ្មោះ)។ ពេលមកដល់ភូមិសាទុំ ត្រូវទៅដល់សង្កាត់ជាំក្រវៀន ដើម្បីរាយការណ៍ថាពួកខ្ញុំចូលមកប្រទេសខ្មែរ។ សង្កាត់ជាំក្រវៀនបានរាយការណ៍ទៅថ្នាក់លើទៀត ប៉ូលីសបានមកហៅពួកខ្ញុំឲ្យឡើងទៅភ្នំពេញ ហើយខ្ញុំនិងមិត្តជាប់គុកនៅជិតវត្តស្រះចក៦ខែ។ នៅក្នុងគុកភាគច្រើនសុទ្ធតែអ្នករត់ឆ្លងដែន។ ខ្ញុំនៅក្នុងគុកបានមួយខែ មេគុកបានតែងតាំងខ្ញុំឲ្យធ្វើជាអ្នកមើលការខុសត្រូវនៅក្នុងគុក។ គ្រប់ចំនួន៦ខែ ក៏ដោះលែងឲ្យខ្ញុំទៅកាន់សង្កាត់ជាំក្រវៀនវិញ។ ខ្ញុំមានបងប្អូនច្រើនដែលរស់នៅភូមិម្ទោះ តែខ្ញុំទៅរស់នៅភូមិសាទុំ។ ខ្ញុំរៀបការប្រពន្ធទី១ នៅឆ្នាំ១៩៦៨ ដោយគ្មានកូនទេ ហើយក៏បែកគ្នាវិញ។ ខ្ញុំមកដាំស្រូវ និងធ្វើចំការ។ ពេលដែលកងទ័ពវៀតកុងមកធ្វើការនៅមន្ទីរពេទ្យក្នុងព្រៃ ខ្ញុំមិនដែលទៅលេងមន្ទីរពេទ្យទេ ព្រោះខ្លាចគេជួបខ្ញុំ។

នៅពេលដែលទាហានអាមេរិកទម្លាក់គ្រាប់បែកខ្លាំងនៅក្នុងភូមិសាទុំ ព្រោះតែស៊ើបការណ៍បានថាវៀតកុងលាក់ខ្លួននៅក្នុងព្រៃ ជិតភូមិសាទុំ។ យន្តហោះអាមេរិកមកទម្លាក់បេ-៥២ ជុំត្រង់ព្រៃកញ្ឆន់ តែកងទ័ពវៀតកុងក៏ដឹងខ្លួនមុនដែរ ទើបដកអស់នៅសល់តែអ្នកពិការ ដែលពិបាកនឹងយកចេញពីមន្ទីរពេទ្យក្នុងព្រៃកញ្ឆន់។ ប្រជាជនដែលរស់នៅក្នុងភូមិទាំងអស់ បានជម្លៀសចេញពីភូមិ អ្នកខ្លះនៅត្រឹមភូមិប្រិយ៍ ចំណែកខ្ញុំទៅដល់ស្រុកព្រែកប្រសប់ ខេត្តក្រចេះ។ ពេលដែលទាហានអាមេរិកដកអស់ពីប្រទេសខ្មែរ ទើបខ្ញុំត្រឡប់មកភូមិវិញ។ ឆ្នាំ១៩៧៤ ទើបខ្ញុំយកប្រពន្ធមួយទៀត នៅតែគ្មានកូនរហូតដល់សព្វថ្ងៃ។ ពេលត្រឡប់មកភូមិវិញ ចាប់ផ្តើមធ្វើស្រែប្រវាស់ដៃ ប្រមូលផលបានចែកទិន្នផលតាមគ្រួសាររៀងៗខ្លួន។ នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រង ខ្ញុំស្ថិតនៅក្នុងកងចល័ត ភ្ជួរស្រែ លើកប្រឡាយ និងធ្វើស្រែរួម។ ការហូបរួមមិនគ្រប់គ្រាន់ទេ។ ខ្ញុំទៅលើកភ្លឺស្រែដល់ស្នួល ឃុំឈើទាលជ្រុំ ខែប្រាំងវិញវាស់ឡូដែលមានទទឹង១០ម៉ែត្របណ្តោយ១០ម៉ែត្រ ហើយនៅខាងស្នួលសំបូរត្រី បបរលាយជាមួយសម្លត្រី។ ក្រោយមកខ្មែរក្រហមចោទខាងបូព៌ា ថាក្បាលយួន ខ្លួនខ្មែរ បានជម្លៀសឲ្យទៅខាងឆ្លូង។ ខ្ញុំទៅលើកប្រឡាយ និងលើកភ្លឺស្រែ។ ខ្ញុំធ្លាប់ឃើញគ្រួសារណាដែលយកប្រពន្ធ ឬប្តីជាជនជាតិវៀតណាម គឺខ្មែរក្រហមដឹកយកទៅទាំងរទេះៗ យកតែអ្នកដែលជាជនជាតិវៀតណាមទេ ប្តី ឬប្រពន្ធខ្មែរ និងកូនមិនយកទៅទេ។ ពីទៅបីថ្ងៃដឹក៤ទៅ៥រទេះ។ នៅពេលដែលកងទ័ពវៀតណាមទៅដល់ឆ្លូង ខ្ញុំក៏ដើរវិលត្រឡប់មកភូមិសាទុំវិញ តែមួយថ្ងៃទេ ចំណែកប្រពន្ធខ្ញុំគាត់ជម្លៀសទៅផ្សេងៗ។ គាត់ទៅដល់ខាងចំការលើ គាត់ចំណាយពេលយូរជាងខ្ញុំទម្រាំមកដល់ស្រុកកំណើតវិញ។

## ៨ - ទិត្យ យិន

ទិត្យ យិន ភេទស្រី អាយុ៨៩ ឆ្នាំ។ សព្វថ្ងៃរស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ទិត្យ (ស្លាប់) និងមានម្តាយឈ្មោះ ខូ (ស្លាប់) ខ្ញុំមានបងប្អូន ៧ នាក់ (ស្រី៦ ប្រុស១) ខ្ញុំមានប្តីឈ្មោះ ថ្នម (ស្លាប់) នៅសម័យខ្មែរក្រហម ខ្ញុំមានកូន៦ នាក់ (ស្រី២ ប្រុស៤)។ កាលពីខ្ញុំនៅក្មេងខ្ញុំមិនបានរៀនសូត្រទេ ព្រោះអត់សាលារៀន មានតែរៀននៅវត្ត។ ខ្ញុំនៅផ្ទះ ជួយធ្វើការងារឪពុកម្តាយខ្ញុំ ធ្វើស្រែចម្ការ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំបានកូន៣នាក់ ស្រាប់តែមានអាមេរិកចូលមកដល់ក្នុងភូមិ។ ឆ្នាំ១៩៧០ ខ្ញុំបានរត់ទៅ



ទិត្យ យិន ភេទស្រី អាយុ៨៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (វី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រវៀន ក្រោយមកទៅមេមត់។ អាមេរិកបានទម្លាក់គ្រាប់បែក ដើម្បីតាមរកវៀតកុង។ វៀតកុងបានពួនតាមព្រៃ នៅជិតភូមិរបស់ខ្ញុំ វៀតកុងមិនហ៊ានចូលភូមិទេ ព្រោះខ្លាចអាមេរិកឃើញ។ កាលនោះមានគ្រាប់ផ្លោង ធ្លាក់ចូលក្នុងភូមិ ប៉ុន្តែមិនត្រូវប្រជាជនទេ។ អ្នកភូមិនាំគ្នារត់ចូលរណ្ដៅ អាមេរិកទម្លាក់ច្រើនខ្លាំងណាស់នៅមេមត់។ បន្ទាប់ពី សង្គ្រាមអាមេរិកបញ្ចប់ទៅ ខ្ញុំបានត្រឡប់មកផ្ទះវិញ ត្រឡប់មកបាន១ឆ្នាំ មានខ្មែរក្រហមចូលក្នុងភូមិម្ដងទៀត។ ខ្មែរក្រហមបានឲ្យអ្នកភូមិធ្វើស្រែប្រវាស់ដៃ បន្ទាប់មកហូបរួម តែហូបមិនឆ្អែតទេ។ ខ្មែរក្រហមឲ្យខ្ញុំលើកប្រព័ន្ធភ្លឺស្រែ ខ្ញុំមិនបានរស់នៅជុំគ្រួសារទេ។ ខ្មែរក្រហមបានបែងចែកការងារ ស្រីផ្សេង ប្រុសផ្សេង ប្ដីខ្ញុំធ្វើការផ្សេង។ ក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំទៅ ស្ពឹកលូន ធ្វើស្រែ នៅទីនោះមិនបានប៉ុន្មាន ខ្មែរក្រហមជម្លៀសខ្ញុំទៅក្រចេះ។ នៅក្រចេះបាន២ថ្ងៃ ជម្លៀសខ្ញុំដោយឆ្លងកាណូតទៅស្ទឹងត្រង់ នៅបាន១យប់ ខ្ញុំបានត្រឡប់ទៅមេមត់ ខ្ញុំរស់នៅមេមត់បាន១០ខែ ត្រឡប់មកភូមិសាទុំវិញ។ នៅពេលដល់ផ្ទះខ្ញុំបានរកគ្រាប់ស្រូវយកមកដាំ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

## ៩- ឡិប ភាច

ឡិប ភាច អាយុ៨៣ឆ្នាំ ភេទស្រី មានស្រុកកំណើតនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តពោធិ៍សាត់។ ឪពុករបស់ខ្ញុំឈ្មោះ អែម ឡិប និងម្ដាយឈ្មោះ អុំ។ ខ្ញុំមានបងប្អូន៣នាក់ ស្រី២នាក់ និងប្រុសម្នាក់។ គ្រួសាររបស់ខ្ញុំឈ្មោះ ម៉ិញ ហឹស និងមានកូន១២នាក់ ស្រី២នាក់ និងប្រុស១០នាក់ សព្វថ្ងៃនៅសល់៦នាក់ ស្រី២ និងប្រុស៤នាក់។ កាលពីតូចៗ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះតែពាក្យសំដីរបស់ម្ដាយខ្ញុំថា "កូនអើយ! កុំខ្លួនយើងជាស្រី វាមិនហោះទេ"។ ខ្ញុំក៏នៅជួយធ្វើស្រែចំការ ម្ដាយឪពុក និងជួយមើលប្អូនៗ រហូតដល់ខ្ញុំរៀបការ។ ខ្ញុំរៀបការនៅអាយុ១៨ឆ្នាំ ជំនាន់សង្គមរាស្ត្រនិយម។ តាំងពីខ្ញុំដឹងក្ដីមកភូមិរបស់ខ្ញុំដាំដូងមិនបានផ្លែហូបទេ គឺមានសង្គ្រាមរត់បោលផ្ទះសម្បែង ទៅរស់នៅភូមិផ្សេង ហើយពេលដែលត្រឡប់មកវិញ ត្រូវដាំសារជាថ្មី។ ពេលដែលអាមេរិកផ្លោង និងទម្លាក់បេ-៥២ ដើម្បីតាមរកយៀកកុង ខ្ញុំនិងប្រជាជនដទៃទៀតក្នុងភូមិទាំងអស់បានរត់ទៅភូមិប្រិយ៍ ដើម្បីរួចផុតពីគ្រាប់ផ្លោង។ ខ្ញុំរស់នៅ និងធ្វើស្រែចំការនៅភូមិប្រិយ៍បានរយៈពេលមួយឆ្នាំ ទើបត្រឡប់មកភូមិសាទុំវិញ បន្ទាប់ពីស្ងប់ស្ងាត់ការទម្លាក់គ្រាប់បែក។ ពេលដែលរស់នៅភូមិប្រិយ៍ ខ្ញុំបានកូនចំនួន៣នាក់។ កាលពីដើមភូមិសាទុំនិយមធ្វើចម្ការដាំស្រូវជាលក្ខណៈវិលជុំ។ ក្រោយពីស្ងប់ស្ងាត់លែងមានព្យុះសម្លេងយន្តហោះរបស់អាមេរិកក៏មានការធ្វើស្រែប្រវាស់ដៃ ពេលបានផលគឺចែកទិន្នផលតាមសមាជិកគ្រួសារ។ ពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រង ខ្មែរក្រហមបានបែងចែកកម្លាំងដូចជាចាស់ៗឲ្យធ្វើស្រែ ស្ទូងស្រូវ ដកជម្រះស្មៅ ហើយទៅហូបបាយនៅរោងបាយ។ មេភូមិដែលគ្រប់គ្រង

ពួកខ្ញុំឈ្មោះ ម៉ៅ អោក និងគណៈឃុំឈ្មោះ លាង។

ឆ្នាំ១៩៧៧ ខ្មែរក្រហមជម្លៀសប្រជាជនដែលនៅភូមិភាគបូព៌ាឲ្យទៅខាងភូមិចិន។ ខ្មែរក្រហមបានប្រាប់អ្នកភូមិថា ខ្មាំងយួនចូលមក និងខ្មាំងអាមេរិកទម្លាក់គ្រាប់បែកទៀត ទើបជម្លៀសប្រជាជនចេញពីភូមិ។ ពេលទៅដល់ភូមិចិន ខ្មែរក្រហមចាត់ឲ្យខ្ញុំជិះដរី ដើម្បីទៅរកស្បៀង ប៉ុន្តែខ្ញុំខ្លាចដរី មិនហ៊ានជិះ សុខចិត្តដើរទៅប្រូតស្រូវ។ ពេលដែលខ្ញុំទៅធ្វើការគឺខ្ញុំទុកកូនតូចនៅជាមួយយាយៗ។ ថ្ងៃមួយពេលល្ងាចដែលខ្ញុំទៅយកកូនពីយាយៗ គាត់បានប្រាប់ថាកូនខ្ញុំមិនព្រមហូបបបរទេ ខ្ញុំបានយកមកកូនមកស្ទាប ស្រាប់តែខ្លួនរបស់គេក្តៅណាស់ ហើយខ្ញុំបានប្រាប់ទៅប្រធានកងថាកូនឈឺ សុំយកកូនទៅពេទ្យ ឬក៏សុំថ្នាំ។ តែប្រធានកងបានឲ្យខ្ញុំយកកូនទៅពេទ្យនៅស្រែរនាម ប៉ុន្តែខ្ញុំមិនស្គាល់ផ្លូវទេ ចុងក្រោយកូនប្រុសរបស់ខ្ញុំបានស្លាប់។ ខ្ញុំនៅភូមិចិនបានមួយឆ្នាំ ទើបខ្មែរក្រហមបានជម្លៀសពួកខ្ញុំទៅថ្មគ្រែ និងជិះកាណូតទៅស៊ីងត្រង់ចំការលើ។ ខ្ញុំទៅដល់ភូមិបុស្សខ្នុរ ប្រជាជនចាស់បានឲ្យពួកខ្ញុំទៅដកសណ្តែកដី បានចំនួនតែ២ថ្ងៃ កងទ័ពវៀតណាមក៏បានទៅដល់ភូមិបុស្សខ្នុរ ហើយប្រកាសថាបងប្អូនមានផ្ទះសំបែងនៅឯណា អញ្ជើញត្រឡប់ទៅវិញ។ ខ្ញុំនិងគ្រួសារបានត្រឡប់មកស្រុកវិញ ហើយសម្រាកនៅកំពង់ចាមមួយយប់ រង់ចាំឆ្លងសា ឡាងធំមកខាងទន្លេបិទ។ ខ្ញុំធ្វើដំណើរមកដល់មេមត់ចំណាយពេលអស់កន្លះខែ ព្រោះតែយប់ត្រង់ណា សម្រាកកន្លែងហ្នឹង ហើយដើរមិនយូរទេ ព្រោះមានកូនតូច ដូច្នេះដើរតែពេលមេឃត្រជាក់ទេ។ ខ្ញុំបានទៅរកស្រូវដល់កាត់ដៃ ហើយបានយកមកបុកដើម្បីទុកហូប។ ពេលដែលមកដល់ភូមិ សុទ្ធតែព្រៃ ហើយកាប់ឆ្ការដើម្បីបានដីធ្វើផ្ទះនៅ និងរស់នៅរហូតដល់សព្វថ្ងៃ។



ឡិប ភាច អាយុ៨៣ឆ្នាំ រស់នៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)




សាលាឃុំទន្លូង។
(រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្លូវលំក្នុងភូមិសាទុំ ឃុំជាំក្រវៀន
ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម

***ស៊ាង ចិន្តា, ទូច វណ្ណេត, អេង វណ្ណីកា, ផល សំភស់ និងមេន នឿន***

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសាររយៈពេល ៤ថ្ងៃ ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២២ ជាមួយអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ដើម្បីស្តាប់រឿងរ៉ាវជីវិតរបស់គាត់ដែលបានឆ្លងរបបខ្មែរក្រហម។ ខាងក្រោមគឺជារឿងរ៉ាវសង្ខេបរបស់គាត់៖



ប៊ុន ឡៅហាន ភេទស្រី អាយុ៧១ឆ្នាំ រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ***១. ប៊ុន ឡៅហាន***

ប៊ុន ឡៅហាន ភេទស្រី អាយុ៧១ឆ្នាំ ជាអតីតកងចល័តនារី និងជាអ្នករស់រានមានជីវិត រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម បានចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមដូចតទៅ៖ ខ្ញុំកើតនៅនៅឆ្នាំ១៩៥១ ក្នុងគ្រួសារកសិករមួយ នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានម្តាយឈ្មោះ អេង ណយស្រ៊ីម និងឪពុកឈ្មោះ ប៊ុន ណាល់។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៧។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំរៀននៅសាលាបឋមសិក្សាគគរ ដល់ថ្នាក់ទី៩ចាស់។ ខ្ញុំចេះអាន និងសរសេរបានបន្តិចបន្តួចៗ ក្រោយមកទៀត ខ្ញុំឈប់រៀន ដោយសារជីវភាពក្រីក្រ។ ខ្ញុំជួយឪពុកម្តាយត្បាញក្រមាលក់ និងធ្វើកិច្ចការងារផ្ទះ។ នៅពេលដែលខ្ញុំត្បាញក្រមាបានប្រហែល២០ ឈ្មួញកណ្តាលតែងតែចុះមកទិញយកទៅលក់បន្ត។ ខ្ញុំទទួលដំណឹងអំពីព្រឹត្តិការណ៍រដ្ឋប្រហារនៅខែមីនា ឆ្នាំ ១៩៧០ តាមរយៈវិទ្យុ។ បន្ទាប់ពីរដ្ឋប្រហារកើតឡើងបាន១ខែ ខ្ញុំឃើញអ្នកភូមិជាច្រើនធ្វើបាតុកម្មដង្ហែរតាមផ្លូវចេញពីភូមិទៅទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានចូលរួមធ្វើបាតុកម្មនោះទេ។ ខ្ញុំបន្តត្បាញក្រមាដូចធម្មតា។ ប៉ុន្មានថ្ងៃក្រោយមក បាតុករទាំងអស់បានដង្ហែរឆ្លងកាត់ភូមិម្តងទៀតក្នុងទិសដៅមកកាន់ទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហម បានចូលមកដល់ និងបានសុំអ្នកភូមិស្នាក់នៅ។ វត្តមានរបស់កងទ័ពរំដោះខ្មែរក្រហមនៅក្នុងភូមិ គឺជាសញ្ញានៃការផ្ទុះឡើងការប្រយុទ្ធគ្នានាពេលខាងមុខ។ នៅចុងឆ្នាំ១៩៧១ ទាហានលន់ នល់ ជាច្រើនត្រូវបានបញ្ជូនទៅឈរជើងនៅបន្ទាយកោះរកា និងរកាគយ។ បន្ទាប់មកទាហានលន់ នល់ បើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហម។ ទាហានលន់ នល់ បញ្ជូនកងទ័ពអាកាសទៅទម្លាក់គ្រាប់បែក និងបាញ់ប្រហារមកលើកងទ័ព

រំដោះខ្មែរក្រហម។ ខ្ញុំ និងក្រុមគ្រួសាររត់ភៀសខ្លួនចេញពីផ្ទះទៅស្នាក់នៅបណ្ដោះអាសន្នជាមួយពូនៅជីហែ ដែលជាតំបន់រំដោះខ្មែរក្រហម ស្ថិតនៅត្រើយម្ខាងនៃទន្លេមេគង្គ ដើម្បីសុវត្ថិភាព។ នៅឆ្នាំ១៩៧២ ខ្ញុំរៀបការជាមួយប្ដីឈ្មោះ ឈិន ហុក ដែលធ្វើការនៅកងយុវជន។ នៅឆ្នាំ១៩៧៣ ខ្ញុំបង្កើតបានកូនប្រុសម្នាក់។ នៅក្នុងឆ្នាំ១៩៧៣ដដែល ប្ដីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំចិញ្ចឹមកូនតែម្នាក់ឯង។ គ្រួសារ និងខ្ញុំ បន្តស្នាក់នៅជីហែ រហូតដល់កងទ័ពរំដោះខ្មែរក្រហមបានវាយកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ខ្ញុំបានដឹងដំណឹងនេះពីអ្នកភូមិថា កងទ័ពរំដោះខ្មែរក្រហមបានវាយយក ទីក្រុងភ្នំពេញ។ ខ្ញុំ និងគ្រួសារ ត្រឡប់មកភូមិវិញ។ ប៉ុន្មានខែក្រោយមក ប្រធានសហករណ៍បង្កើតក្រុមសាមគ្គី ដែលក្រោយមកបានប្ដូរទៅជា "សហករណ៍"។ វេលានេះខ្ញុំចាប់ផ្ដើមធ្វើការងារនៅក្នុងសហករណ៍។ កូនរបស់ខ្ញុំគឺនៅជាមួយម្ដាយរបស់ខ្ញុំមើលថែ។ នៅក្នុងភូមិ កងចល័តត្រូវបានបែងចែករួមមាន៖ ទី១) កងកុមារ គឺចាប់ពីអាយុ៦ឆ្នាំដល់១១ឆ្នាំ។ ទី២) កងចល័តយុវជនគឺចាប់ផ្ដើមអាយុ១២ឆ្នាំដល់លើស២០ឆ្នាំ។ ទី៣) កង៣ គឺជាសម្រាប់អ្នកដែលបានរៀបការរួចហើយ (ក្រុមមនុស្សវ័យកណ្ដាល)។ ទី៤) កងវ័យជរា គឺសម្រាប់អ្នកដែលមានវ័យចំណាស់ និងមិនអាចធ្វើការបាន។ ខ្ញុំត្រូវបានចាត់តាំងធ្វើការនៅកងចល័តគឺ «កង៣» ដែលមានគ្នាប្រហែល៣០០នាក់។ សមមិត្ត រ៉ាត គឺជាប្រធានកង៣។ ខ្ញុំត្រូវបានចាត់ឲ្យជីកគាស់គល់ឈើ និងជីកដីនៅទីតាំងរួមមាន៖ ទំនប់ល្អាក វាលទួលស្រែ និង ទំនប់ត្រួយចេក។ ខ្ញុំធ្វើការពីព្រលឹមទល់ព្រលប់ជារៀងរាល់ថ្ងៃ និង ទទួលបានរបបអាហារតិចតួច និងគ្មានពេលមើលថែកូន និងឪពុកម្ដាយ។ ចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ការសម្លាប់រង្គាលបានចាប់ផ្ដើមនៅក្នុងភូមិ៖

**ដំណាក់កាលទី ១៖** នៅខែកក្កដា ឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានមកដល់ភូមិ និងចាប់ផ្ដើមគ្រប់គ្រង។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ចាប់ផ្ដើមស្វែងរក និងចាប់ខ្លួនកម្មាភិបាលមូលដ្ឋានយកមកសម្លាប់។

**ដំណាក់កាលទី ២៖** នៅខែកញ្ញា ឆ្នាំ១៩៧៧ បន្ទាប់ពីសម្លាប់កម្មាភិបាលមូលដ្ឋាន និងអ្នកពាក់ព័ន្ធ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបន្តដាក់គោលដៅកំណត់ និងចាប់ផ្ដើមចាប់ខ្លួនអ្នកភូមិ។ នៅក្នុងរយៈពេលនេះ ប្រជាជនខ្មែរឥស្លាមប្រហែល ៥០ គ្រួសារ ដែលកំពុងរស់នៅភូមិចម្ការសាមសិប ត្រូវបានខ្មែរក្រហមចាប់ និងដឹកយកទៅសម្លាប់ទាំងគ្រួសារ។ ទីតាំងសម្លាប់គឺនៅក្នុង ឡថ្មដក់ និងនៅក្រោយភូមិ។

នៅចុងឆ្នាំ១៩៧៨ នៅពេលដែលខ្ញុំកំពុងធ្វើការនៅទំនប់ត្រួយចេក ខ្ញុំបានឮសំឡេងផ្ទុះគ្រាប់ និការបាញ់កាំភ្លើងនៅសមរភូមិ ខ្ញុំរត់ត្រឡប់មកផ្ទះវិញ។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានប្រមូលអ្នកភូមិដើរទៅទំនប់ត្រួយចេក។ គោលបំណងនៃប្រមូលអ្នកភូមិយកទៅទីតាំងខាងលើនេះ គឺដើម្បីសម្លាប់ចោល។ ខ្ញុំ និងគ្រួសារ មិនទៅទេ និងបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហម នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ភូមិនៅខែមករា ឆ្នាំ១៩៧៩។ នៅឆ្នាំ១៩៨២ ខ្ញុំ និងគ្រួសារ ចាប់ផ្ដើមប្រកបរបរកសិកម្ម ដោយបានដាំបន្លែ និងតម្បាញក្រមាលក់ដើម្បីរកចំណូលចិញ្ចឹមជីវិតរហូតមកដល់បច្ចុប្បន្ន។

## ២. ប៊ុន ចាន់ថុល

ប៊ុន ចាន់ថុល ភេទស្រី អាយុ៦២ឆ្នាំ អតីតកងចល័តនារី និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានពិពណ៌នាអំពីរយៈពេលមួយថ្ងៃធ្វើការនៅការដ្ឋានទំនប់។ ចាន់ថុល នៅតែចងចាំអំពីថ្ងៃដែលខ្លួនធ្វើការគ្មានពេលសម្រាក និងហូបមិនគ្រប់គ្រាន់។ ខ្ញុំកើតនៅឆ្នាំ១៩៦០ នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្ត




ប៊ុន ចាន់ថុល ភេទស្រី អាយុ៦៧ឆ្នាំ រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កំពង់ចាម។ ខ្ញុំគឺជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំរៀននៅសាលាបឋមសិក្សាគគរ។ ខ្ញុំរៀនត្រឹមថ្នាក់ទី១០។ មួយខែក្រោយពីមានរដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០ បាតុកម្មបានកើតមានឡើង។ ក្នុងស្ថានភាពច្របូកច្របល់បែបនេះ ខ្ញុំសម្រេចចិត្តឈប់រៀន និងនៅផ្ទះជួយឪពុកម្តាយ។ ក្រោយមកទៀត កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ។ បន្ទាប់មក ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះឡើងជាញឹកញាប់។ គ្រួសាររបស់ខ្ញុំ រត់ភៀសខ្លួនចេញពីភូមិដើម្បីស្វែងរកទីកន្លែងសុវត្ថិភាព គឺនៅជីហែដែលជាតំបន់រំដោះខ្មែរក្រហម។

នៅពេលនោះ ខ្ញុំមានអាយុប្រហែល១២ឆ្នាំ។ ខ្ញុំបន្តរៀនសូត្រនៅតំបន់រំដោះខ្មែរក្រហម។ សមមិត្ត ប៉ូ បង្រៀនសិស្សប្រហែល២០នាក់នៅក្រោមផ្ទះរបស់អ្នកភូមិ។ សិស្សទាំងអស់ រៀនអក្សរនិងលេខនៅពេលព្រឹក ខណៈពេលដែលមិនមានការបង្រៀនអ្វីពេលរសៀលនោះឡើយ។ នៅចុងឆ្នាំ១៩៧៣ គ្រួសារវិលត្រឡប់មករស់នៅភូមិចម្ការសាមសិបវិញ។ ភូមិចម្ការសាមសិប ត្រូវបានទាហាន លន់ នល់ ទម្លាក់គ្រាប់បែកជាច្រើន។ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមវាយផ្តាច់យកបានទីរួមខេត្តកំពង់ចាមនៅនៅចុងឆ្នាំ១៩៧៣ អ្នកភូមិជាច្រើនបានវិលត្រឡប់មកវិញ។ នៅឆ្នាំ១៩៧៤ ខ្ញុំរស់នៅក្នុងផ្ទះ និងធ្វើស្រែចម្ការ។ បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមវាយចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញប្រជាជនថ្មីជាច្រើនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ដើរតាមផ្លូវនៅមុខផ្ទះ។ ប្រជាជនជម្លៀសខ្លះបានសុំអ្នកភូមិស្នាក់នៅមួយយប់ ខណៈដែលប្រជាជនជាច្រើនផ្សេងទៀតបន្តដំណើរទៅមុខទៀត។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៣ឆ្នាំ។ ខ្ញុំត្រូវបានចាត់ឲ្យធ្វើការនៅកងចល័តស្រុក ដែលមានមនុស្សប្រហែល ៣០០នាក់។ សមមិត្ត នីន គឺជាប្រធានកងចល័តស្រុក ខណៈពេលដែលសមមិត្ត ដា គឺជាប្រធានកងតូច។ ចាប់ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ ខ្ញុំបានត្រូវផ្ទេរទៅធ្វើការនៅការដ្ឋាននិងទំនប់ រួមមាន: ល្អាក ត្រួយបេក និងព្រៃទទឹង។ ខ្ញុំអាចចងចាំការងារពេញមួយថ្ងៃដែលខ្ញុំបានធ្វើនៅពេលនោះដូចតទៅ៖

- ប្រហែលម៉ោង៣ព្រឹក សមមិត្ត ដា ផ្លុំកញ្ចែដាស់ និងក្រោកឈរតម្រង់ជួរ។ នៅក្នុងកងតូច មានសមមិត្តប្រហែល៣០នាក់។
- ប្រហែលម៉ោង៣:៣០នាទីព្រឹក សមមិត្ត ដា ណែនាំឲ្យខ្ញុំ និងអ្នកគ្រប់គ្នាសម្រេចផែនការការងារ ជីកដី៣ម៉ែត្រការ៉េ និងទៅយកសម្ភារធ្វើការ។
- ប្រហែលម៉ោង ៣:៤០នាទីព្រឹក យើងទាំងអស់គ្នាដើរទៅការដ្ឋានធ្វើការ។ នៅយប់ខ្លះ ខ្ញុំមើលមុខគ្នាមិនស្គាល់នោះឡើយ។
- ប្រហែលម៉ោង ៤ព្រឹក ខ្ញុំចាប់ផ្តើមកាប់ និងរែកដី។
- ប្រហែលម៉ោង ៦ព្រឹក ខ្ញុំកាប់ដីបានប្រហែលកន្លះម៉ែត្រការ៉េ។
- ប្រហែលម៉ោង ៦:៤៥នាទីព្រឹក សមមិត្ត ដា ផ្លុំកញ្ចែដើម្បីឲ្យអ្នកគ្រប់គ្នាសម្រាកបន្តិច។ បន្ទាប់ពីសម្រាករួចហើយ សមមិត្ត ដាផ្លុំកញ្ចែម្តងទៀត ដើម្បីឲ្យសញ្ញាដល់អ្នកគ្រប់គ្នាបន្តការងាររហូតដល់ពេលសម្រាកបាយថ្ងៃត្រង់។

- នៅម៉ោង១១ព្រឹក ខ្ញុំហូបបបររាវមួយចាន និងសម្រាក។
- ម៉ោង១២ថ្ងៃត្រង់ អ្នកគ្រប់គ្នាត្រូវត្រឡប់មកទីតាំងធ្វើការ និងធ្វើការរហូតគ្រប់ផែនការកំណត់ត្រឹមម៉ោង៥ល្ងាច។
- បើមិនទាន់គ្រប់ផែនការកំណត់ទេ ខ្ញុំត្រូវបន្តធ្វើការរហូតដល់ម៉ោង៦ឬ៧ល្ងាច។ អ្នកដែលបានកាប់ និងលើកដីគ្រប់តាមផែនការកំណត់អាចទទួលបានរបបអាហារ។
- ចាប់ពីម៉ោង៩ដល់ម៉ោង១០យប់ ខ្ញុំត្រូវយាមនៅកន្លែងសម្រាក។ បន្ទាប់ពីយាមរួចរាល់ ខ្ញុំអាចចូលដេក។

សកម្មភាពការងារពេញមួយថ្ងៃ គឺនៅតែស្ថិតក្នុងការចងចាំរបស់ខ្ញុំ។ គ្រាមួយ ដែលខ្ញុំយល់ថាបាត់បង់អ្វីៗគ្រប់យ៉ាងនោះគឺនៅពេលដែលឪពុករបស់ខ្ញុំត្រូវបានចាប់យកទៅសម្លាប់។ សមមិត្ត ស៊ុន បានប្រាប់ខ្ញុំ ថាឪពុកខ្ញុំត្រូវបានបណ្តើរទៅកន្លែងសម្លាប់នៅ វាលទួលស្រែ។ ខ្ញុំបានរត់ទៅជួបគាត់ជាលើកចុងក្រោយ។ ខ្ញុំឃើញគាត់ត្រូវបានបណ្តើរដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីទៅ វាលទួលស្រែ។ ពេលនោះគឺជាលើកចុងក្រោយដែលខ្ញុំបានឃើញគាត់។ នៅពេលដែលកងទ័ពវៀតណាមចូលជិតមកដល់ ខ្ញុំបានរត់គេចខ្លួនត្រឡប់មកភូមិវិញ។ ខ្ញុំបានបន្តធ្វើស្រែចម្ការ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមានកម្លាំងធ្វើស្រែចម្ការបានទៀតទេ។ ខ្ញុំនៅផ្ទះ និងតែងតែចងចាំថ្ងៃដែលខ្ញុំធ្វើការនៅតំបន់ទំនប់ និងវេលាពេលចុងក្រោយដែលខ្ញុំបានឃើញឪពុករបស់ខ្ញុំ។

## ៣. អេង ស្រី

អេង ស្រី ភេទស្រី អាយុ៦៧ឆ្នាំ អតីតកងចល័ត និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅភូមិកោះរកាក្នុង ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានរំឭកអំពីដំណើរជីវិតក្នុងរបបខ្មែរក្រហម។ ខ្ញុំកើតនៅឆ្នាំ១៩៥៥ នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម។ ខ្ញុំជាកូនទីប្រាំក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន ៧ នាក់។ កាលពីនៅវ័យក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាដំបងដែក។ ខ្ញុំរៀនត្រឹមថ្នាក់ទី១១ចាស់ ប៉ុន្តែក្រោយមកទៀត ខ្ញុំឈប់រៀន។ នៅពេលនោះខ្ញុំមានអាយុប្រហែល១០ឆ្នាំ។ ខ្ញុំជួយឪពុកម្តាយនៅផ្ទះ។ បន្ទាប់ពីមានរដ្ឋប្រហារនៅដើមឆ្នាំ១៩៧០ និងការផ្ទុះឡើងសង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម គ្រួសាររបស់ខ្ញុំភៀសខ្លួនចេញពីភូមិ។ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ គ្រួសាររបស់ខ្ញុំរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ រួមមាន ភូមិទួលស្រែ ភូមិរមាស ភូមិរកាគយ ភូមិដីឥដ្ឋ ភូមិទន្លូង និងភូមិមហាខ្ញូង។ អ្នកភូមិម្នាក់ប្រាប់គ្រួសារខ្ញុំថា ផ្ទះរបស់យើងត្រូវបានឆេះអស់ដោយសារតែការទម្លាក់គ្រាប់បែក។ នៅចុងឆ្នាំ១៩៧៣ ខ្ញុំដឹងថាទីរួមខេត្តកំពង់ចាមត្រូវបានវាយបែក។ ក្រោយមកទៀត គឺនៅឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញក៏ត្រូវបានកាន់កាប់ដោយកងទ័ពរំដោះខ្មែរក្រហម។ បន្ទាប់មក ខ្ញុំ និងក្រុមគ្រួសារបានត្រឡប់មកភូមិវិញ និងសង់កូនខ្ទមមួយសម្រាប់រស់នៅ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងសហករណ៍។ ខ្ញុំធ្វើការនៅក្នុងកងចល័តស្រុក ដោយបានទៅលើកទំនប់ និងជីក


អេង ស្រី ភេទស្រី អាយុ៦៧ រស់នៅភូមិកោះរកាក្នុងឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រឡាយនៅទីតាំងផ្សេងៗ រួមមានទំនប់ល្អាក់ខាងជើងព្រៃ ទំនប់ស្ទឹងជីនិត និងខាងស្ទឹងត្រង់ៗ ខ្ញុំធ្វើការពីម៉ោង៧ព្រឹកដល់ម៉ោង៥ល្ងាចៗ ចំណែកឯរបបអាហារវិញគឺខ្ញុំទទួលបានតែបបររាវមួយចានៗ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានផ្លាស់ទៅលើកទំនប់ល្អាក់ៗ ចុងឆ្នាំ១៩៧៨ ខ្ញុំរៀបការប្តី ដោយមានការរៀបចំរបស់អង្គការៗ នៅពេលនោះ មានគ្នាប្រហែល៣០គូ ដែលរៀបចំដោយអង្គការៗ ពិធីរៀបការនៅពេលនោះ គឺមានតែរយៈពេលប្រហែលមួយម៉ោងតែប៉ុណ្ណោះៗ នៅពេលនោះ ខ្ញុំប្រាប់អង្គការថា ខ្ញុំស្ម័គ្រចិត្តរៀបការ តាមការរៀបចំរបស់អង្គការៗ នៅថ្ងៃបន្ទាប់ គ្រួសារខ្ញុំ និងប្តីប្រពន្ធ៤គូទៀត ត្រូវបានបញ្ជូនត្រឡប់ទៅរស់នៅភូមិក្រឡាវិញៗ អ្វីៗទាំងអស់គឺស្ថិតនៅក្រោមការរៀបចំរបស់អង្គការតែប៉ុណ្ណោះៗ នៅពេលដែលកងទ័ពវៀតណាមចូលជិតមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្តីវិលត្រឡប់មកភូមិវិញ និងប្រកបរបរជាកសិកររហូតមកដល់បច្ចុប្បន្ននេះៗ

## ៤. សាន់ ហឿង

សាន់ ហឿង ភេទប្រុស អាយុ៦២ឆ្នាំ អតីត



សាន់ ហឿង រស់នៅក្នុងភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

កងចល័តស្រុក និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចែករំលែកបទពិសោធន៍ និងរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបខ្មែរកហមៗ នៅឆ្នាំ១៩៧៩ ខ្ញុំឃើញរថក្រោះ និងកងទ័ពវៀតណាមស្ថិតនៅត្រើយ ទន្លេបិទបានបាញ់ផ្លោងមកលើកងទ័ពខ្មែរក្រហមៗ នៅពេលនោះ ខ្ញុំត្រូវបានជម្លៀសទៅភ្នំហាន់ជ័យ និងល្អាកៗ ដោយដឹងអំពីស្ថានភាពមិនស្រួល ខ្ញុំលួចរត់មកផ្ទះវិញ បន្ទាប់ពីបានដេក១យប់ៗ

ខ្ញុំឈ្មោះ សាន់ ហឿង គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅក្នុងភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ សព្វថ្ងៃនេះ ខ្ញុំប្រកបរបរធ្វើស្រែចម្ការៗ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៧ នាក់ ( ប្រុស៣នាក់ ស្រី៤នាក់ )ៗ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារកសិករនេះៗ ឪពុករបស់ខ្ញុំមានឈ្មោះ សាន់ ធុយ និងម្តាយមានឈ្មោះ ថន លុចៗ ខ្ញុំរៀបការជាមួយ ប៊ួន ចាន់ថុល និងមានកូនប្រុសស្រីចំនួន៣នាក់ៗ នៅវ័យកុមារ ខ្ញុំរៀនថ្នាក់ទី១០នៅសាលាបឋមសិក្សា គគរៗ ខ្ញុំអាចសរសេរ និងអានអក្សរបានបន្តិចបន្តួចៗ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចឪនៅដើមឆ្នាំ១៩៧០ ខ្ញុំឈប់រៀន និងមកជួយធ្វើការងារផ្ទះឪពុកម្តាយៗ នៅឆ្នាំ១៩៧២ ខ្ញុំស្ម័គ្រចិត្តធ្វើជាកងឈ្លបឃុំ ដែលមានគ្នាទាំងអស់ចំនួន១០នាក់ក្នុងមួយក្រុមៗ ភូមិចម្ការសាមសិប គឺជាសមរភូមិក្តៅរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមៗ នៅពេលដែលសមរភូមិនៅកោះរកាផ្ទុះឡើង ខ្ញុំត្រូវបានបញ្ជូនទៅលីសែងអ្នករបួសយកមកព្យាបាលនៅមន្ទីរពេទ្យដែលស្ថិតនៅក្នុងតំបន់រំដោះខ្មែរក្រហមៗ នៅឆ្នាំ១៩៧៣ កងទ័ពខ្មែរក្រហមត្រូវបានបញ្ជូនមកភូមិដើម្បីទៅប្រយុទ្ធនៅខ្សែត្រៀមជួរមុខ ដើម្បីវាយផ្តាច់យកទីរួមខេត្តកំពង់ចាមៗ នៅចុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ កងទ័ពរំដោះខ្មែរក្រហមវាយបែកបន្ទាយទាហាន លន់ នល់ និងបន្តទៅទីរួមខេត្តកំពង់ចាមៗ នៅក្នុងសមរភូមិវាយផ្តាច់នេះ ខ្ញុំក៏ត្រូវបានបញ្ជូនទៅសែងអ្នករងរបួសដើម្បីព្យាបាលនៅមន្ទីរពេទ្យស្រុករការគយ និងខ្មោចកងទ័ពដែលបានស្លាប់នៅក្នុងសមរភូមិៗ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់

មកកងចល័តស្រុកវិញ។ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ខ្ញុំទៅធ្វើការនៅកងចល័តជាច្រើនកន្លែងរួមមាន៖

- **ឆ្នាំ១៩៧៦៖** ខ្ញុំផ្លាស់ទៅធ្វើការដកស្ទូង និងកាប់ព្រៃនៅស្រុកព្រៃឈរ និងស្រុកជើងព្រៃ។ ខ្ញុំចាប់ផ្តើមធ្វើការចាប់ពីវេលាម៉ោង៧ ព្រឹកដល់វេលាម៉ោង១១ថ្ងៃត្រង់ និងចូលធ្វើការវិញចាប់ពីវេលាម៉ោង១ដល់វេលាម៉ោង៥ល្ងាច ទើបឈប់។
- **ឆ្នាំ១៩៧៧៖** ខណៈពេលខ្ញុំផ្លាស់មកធ្វើការនៅទំនប់ត្រួយចេក ខ្ញុំកើតមានជំងឺគ្រុនចាញ់ និងត្រូវបានបញ្ជូនមកព្យាបាលនៅក្នុងវិហារចាមស្ថិតនៅភូមិកំពង់ក្របី។ ខ្ញុំទទួលបានថ្នាំលេប១ថ្ងៃ២ដង និងព្យាបាលជិត២ខែ។ បន្ទាប់ពីធូរស្រាលបន្តិច ខ្ញុំត្រូវបានចាត់តាំងឲ្យទៅមើលគោចំនួន២០០ក្បាល។
- **ឆ្នាំ១៩៧៨៖** ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការឡឥដ្ឋស្ថិតក្រោមការគ្រប់គ្រងដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចំនួន២នាក់។ ខ្ញុំមិនចាំឈ្មោះរបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីទាំងនេះទេ។ នៅឆ្នាំ១៩៧៩ ខ្ញុំឃើញរថក្រោះ និងកងទ័ពវៀតណាមស្ថិតនៅត្រើយទន្លេបិទបានបាញ់ផ្លោងមកលើកងទ័ពខ្មែរក្រហម។ នៅពេលនោះ ខ្ញុំត្រូវបានជម្លៀសទៅភ្នំហាន់ជ័យ និងល្អាកដេក។ ដោយដឹងអំពីស្ថានភាពមិនស្រួល ខ្ញុំលួចរត់មកផ្ទះវិញបន្ទាប់ពីបានដេក១យប់។

## ៥. ទូច វ៉ា

ទូច វ៉ា ភេទប្រុស អាយុ៥៦ឆ្នាំ អតីតកុមារមូលដ្ឋាន និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានរំឭកអំពីការចងចាំពីកុមារភាពនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំឈ្មោះ ទូច វ៉ា កើតនៅឆ្នាំ១៩៦៦ នៅភូមិរមួល ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ងិច ទូច និងម្តាយឈ្មោះ ង៉ាន គីន។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំកើតនៅក្នុងគ្រួសារកសិករ និងមិនមានរៀនសូត្រអ្វីនោះឡើយ ពីព្រោះភូមិរបស់ខ្ញុំត្រូវបានប្រែក្លាយទៅជាសមរភូមិរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បន្ទាប់ពីមានរដ្ឋប្រហារនៅឆ្នាំ១៩៧០។ ឪពុកម្តាយបានពាខ្ញុំរត់ចេញពីភូមិ ដើម្បីរកកន្លែងសុវត្ថិភាព។ នៅឆ្នាំ១៩៧៤ ខ្ញុំ និងគ្រួសារបានវិលត្រឡប់ចូលភូមិវិញ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានដាក់នៅក្នុងកងកុមារ ដើម្បីរើសលាមកសត្វ កាត់ទន្ទ្រានខែត្រធ្វើជី ដាក់ស្រែ។ ខ្ញុំរែកសំណាបយកទៅឲ្យអ្នកស្ទូងនៅវាលស្រែគោកតាងួន។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅរោងចញ្ចឹមមាន់។ នៅពេលនោះ មានកុមារទាំងអស់សរុបចំនួន១០នាក់ ដើម្បីមើលថែ និងសម្អាតរោងមាន់។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានផ្លាស់ប្តូរទៅ រោងបាយ ដោយបានដើរបេះត្រួយអំពិលសម្រាប់ចុងភៅដាំស្ល។ នៅពេលនោះ ខ្ញុំហូបតែបបរមួយកូនចានប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនទៅហ្វឹកហ្វឺនសឹក ដើម្បីត្រៀមវាយទប់កងទ័ពវៀតណាម។ នៅក្នុងមួយក្រុម មានកងទ័ពហ្វឹកហ្វឺនចំនួន២០នាក់។ នៅដើមឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមទទួលរងបរាជ័យដោយកងទ័ពវៀតណាមនៅមាត់ទន្លេមេគង្គ។ ខ្ញុំលួចរត់មកផ្ទះដើម្បីជួបជាមួយឪពុកម្តាយ និងបងប្អូនវិញ។



ទូច វ៉ា ភេទប្រុស អាយុ៥៦ឆ្នាំ រស់នៅភូមិចម្ការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៦. ភួង ស្រ៊ន់

ភួង ស្រ៊ន់ ភេទស្រី អាយុ៥៣ឆ្នាំ អតីតកុមារមូលដ្ឋាន និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាននិយាយប្រាប់អំពីការចងចាំពីកុមារភាពរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម។ ខ្ញុំកើតនៅឆ្នាំ១៩៦៩ នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបជាមួយប្តីឈ្មោះ ទូច វ៉ាន់ និងមានកូនប្រុសស្រីទាំងអស់ចំនួន ៨នាក់។ ខ្ញុំមានឪពុកឈ្មោះ ភួង ផន និងម្តាយឈ្មោះ ផុក លី។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ កាលពីវ័យកុមារ ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី៩ចាស់នៅសាលាបឋមសិក្សាដំបងដែក។ ក្រោយមកទៀត ខ្ញុំឈប់រៀន ពីព្រោះឪពុកម្តាយមានជីវភាពខ្វះខាត។ បន្ទាប់ពីបានឈប់រៀន ខ្ញុំមកជួយការងារឪពុកម្តាយនៅផ្ទះវិញ។ នៅពេលនោះ ខ្ញុំប្រកបរបរជាអ្នកលក់ទឹកអំពៅ ដើម្បីយកប្រាក់ផ្គត់ផ្គង់ភាពខ្វះខាតនៅក្នុងគ្រួសារ។ នៅពេលនោះ ខ្ញុំមានអាយុជិត១០ឆ្នាំ។ ខាងក្រោមនេះគឺជាការចងចាំរបស់ខ្ញុំអំពីការផ្ទុះឡើងនូវសង្គ្រាម និងរបបខ្មែរក្រហម៖

- **ឆ្នាំ១៩៧០៖** ខ្ញុំដឹងខ្លះអំពីព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចឪ
- **ឆ្នាំ១៩៧១៖** កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ក្នុងភូមិ។
- **ឆ្នាំ១៩៧៣៖** សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើង។ ការបាញ់ផ្លោងគ្រាប់ ការទម្លាក់គ្រាប់បែកបណ្តាលឲ្យផ្ទះរបស់អ្នកភូមិឆេះ។ គ្រួសារខ្ញុំបានរត់ចេញពីភូមិ តាមរទេះគោ ទៅដល់ភូមិថ្មីក្រោមដែលជាតំបន់រំដោះរបស់ខ្មែរក្រហម។
- **ឆ្នាំ១៩៧៥៖** គ្រួសារខ្ញុំវិលត្រឡប់មកភូមិវិញ។ នៅចុងឆ្នាំ១៩៧៥ ដដែរ ឪពុកម្តាយរបស់ខ្ញុំត្រូវបានចាត់តាំងធ្វើការកងចល័តសហករណ៍។ បងប្អូនរបស់ខ្ញុំត្រូវទៅធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ ចំណែកឯ ខ្ញុំត្រូវចូលធ្វើការនៅកងកុមារ ដើម្បីដើរកាត់ស្លឹកឈើ និងរើសអាចម៍គោធ្វើជីដាក់ស្រែ។ មិនយូរប៉ុន្មាន ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារតែការហូបអាហារមិនគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល។
- **ឆ្នាំ១៩៧៦៖** ភូមិដំបងដែកត្រូវបានទឹកជំនន់ជន់លិច។ គ្រួសាររបស់ខ្ញុំត្រូវបានបញ្ជូនទៅភូមិទួលស្រែ។
- **ឆ្នាំ១៩៧៧៖** ម្តាយ និងបងប្អូនរបស់ខ្ញុំ ត្រូវទៅធ្វើការងារ រួមមាន៖ កាប់ឆ្ការព្រៃដើម្បីពង្រីកផ្ទៃដីដាំដុះស្រូវ និងភ្ជួររាស់ដីដាំស្រូវ។ បន្ទាប់ពីប្រមូលផលស្រូវរួចរាល់ គ្រួសារខ្ញុំត្រូវបានបញ្ជូនមកភូមិវិញ។
- **ឆ្នាំ១៩៧៨៖** គ្រួសារខ្ញុំត្រូវបានផ្លាស់ទៅរស់នៅនិងលើកទំនប់ព្រែកជីក អស់រយៈពេល៣ខែ។
- **ឆ្នាំ១៩៧៩៖** ខណៈពេលដែលគ្រួសារខ្ញុំធ្វើការនៅការដ្ឋានទំនប់ព្រែកជីក កងទ័ពវៀតណាមចូលមកដល់។ នៅពេលនោះគ្រួសាររបស់ខ្ញុំរួចផុតពីសេចក្តីស្លាប់ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។




ភួង ស្រ៊ន់ ភេទស្រី អាយុ៥៣ឆ្នាំ រស់នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាប្រវត្តិសាស្ត្រគ្រួសារ
## និងគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកត្រាំកក់ ខេត្តតាកែវ

*ង៉ាន់ វិន និង សៀង កញ្ញា*





សាលាស្រុកត្រាំកក់។ (ង៉ាន់វិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវកំពុងពិភាក្សាជាមួយលោកគ្រូអ្នកគ្រូនៅ «បណ្ណាល័យសម្តេចឪសម្តេចម៉ែ»។ (ង៉ានវិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃ៨រោចខែបុស្ស ឆ្នាំឆ្លូវ ត្រីស័កពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី ២៥ ខែមករា ឆ្នា២០២២ លោកនាយកនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងក្រុមការងារអ្នកស្ម័គ្រចិត្តបានទៅមើលចេតិយដែលទើបនឹងសាងសង់រួច នៅក្នុងភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ បន្ទាប់មកក្រុមការងារក៏បានជួបលោកមេភូមិពិភាក្សាគ្នាអំពីការបញ្ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព។ ក្រុមការងារក៏បានធ្វើដំណើរទៅសាលាស្រុកត្រាំកក់ ដើម្បីស្នើសុំឲ្យអាជ្ញាធរស្រុកជួយសហការ និងធ្វើការផ្សព្វផ្សាយទៅដល់ប្រជាជនទាំងអស់តាមរយៈអាជ្ញាធរភូមិ ឃុំ ដើម្បីឲ្យប្រជាជនជ្រាបជាដំណឹងទាក់ទងនឹងគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម"។

ក្រុមការងារបានសម្ភាសន៍លោកយាយម្នាក់ឈ្មោះ សឹម ឡៃស្រ៊ុយ អាយុ ៦៣ឆ្នាំ រស់នៅក្នុងភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ លោកយាយរស់នៅម្នាក់ឯង ដោយប្រកបមុខរបរជាអ្នកលក់នំចេក។ ប្ដីរបស់លោកយាយបានស្លាប់បាត់ហើយបន្សល់ទុកនូវកូនស្រីម្នាក់។ បច្ចុប្បន្នកូន

ស្រីលោកយាយមានប្តី និងទៅរស់នៅស្រុកឆ្ងាយពីគាត់។ សព្វថ្ងៃ លោកយាយរស់នៅក្នុងផ្ទះតូចមួយម្នាក់ឯង ដែលសង់លើដីរបស់អ្នកដទៃ។ ជីវភាពលោកយាយមើលទៅខ្វះខាត តែលោកយាយមិនមានប័ណ្ណក្រីក្រទេ។ ក្រឡេកទៅមើលពីរបបខ្មែរក្រហមវិញ លោកយាយបានបាត់បង់សាច់ញាតិបងប្អូនសរុបទាំងអស់ប្រហែល៤០នាក់ ដោយសាររបបនេះ។ លោកយាយបានលើកឡើងថា គាត់មិនចង់រំឭកពីរបប ប៉ុល ពត ហ្នឹងទេព្រោះវាឈឺចាប់ពេក ឪពុកលោកយាយស្លាប់ដោយសារជំងឺក្នុងរបបខ្មែរក្រហម ហើយក្រុមគ្រួសារយាយត្រូវបានខ្មែរក្រហមជម្លៀសចេញពីភ្នំពេញឲ្យមករស់នៅតាមជនបទ។ ការរស់នៅក្នុងរបបខ្មែរក្រហមធ្វើឲ្យលោកយាយជួបនូវទុក្ខលំបាកស្ទើរតែទ្រាំមិនបាន។ ចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់តុលាការខ្មែរក្រហមលោកយាយមិនពេញចិត្តទេ ព្រោះមិនយុត្តិធម៌សម្រាប់គាត់និងអ្នកដែលបានស្លាប់ទាំងឡាយ។ សព្វថ្ងៃ លោកយាយមានជំងឺលើសឈាម ប៉ុន្តែលោកយាយមិនធ្លាប់បានទៅពិនិត្យសុខភាពទេ ដោយសារជីវភាពខ្វះខាតជាប់រវល់ធ្វើនំលក់និងធ្វើការងាររកស៊ីចិញ្ចឹមជីវិត។

នៅថ្ងៃបន្ទាប់ ក្រុមការងារបានបន្តធ្វើដំណើរទៅកាន់ «បណ្ណាល័យសម្តេចឪ សម្តេចម៉ែ» ដែលមានទីតាំងស្ថិតនៅក្នុងស្រុកគិរីវង្ស ដើម្បីជួបសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូនៅទីនោះ។ ក្រុមការងារបានពិភាក្សាជាមួយលោកគ្រូ អ្នកគ្រូ អំពីគម្រោងតាំងពិព័រណ៍និងផ្តល់ព័ត៌មានទៅកាន់សិស្សដែលមានបំណងចង់ធ្វើការងារស្ម័គ្រចិត្ត។



សឹម ឡៃស្រ៊ួយ អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។
(ង៉ាន់ វិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)




ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវប្រគល់ប្រអប់អនុស្សាវរីយ៍សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជូនអ្នកគ្រូនៅ «បណ្ណាល័យសម្តេចឪ សម្តេចម៉ែ»។
(ង៉ាន់ វិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មក ក្រុមការងារក៏ទៅសាលាស្រុកអង្គរជ័យ ហើយក៏បានជួបពិភាក្សាជាមួយអាជ្ញាធរស្រុក ដើម្បីចូលរួមសហការ និងធ្វើការផ្សព្វផ្សាយដល់អាជ្ញាធរភូមិឃុំ និងប្រជាជនទាំងអស់ឲ្យបានដឹងពីគម្រោង "ការលើកកម្ពស់សិទ្ធ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម"។

ក្រោយមកទៀត ក្រុមការងារក៏បានទៅកាន់ផ្ទះអ្នកស្ម័គ្រចិត្តម្នាក់នៅក្នុងភូមិត្រពាំងផ្អែក ឃុំម្រោម ស្រុកអង្គរជ័យដដែល ហើយក៏បានជួបលោកយាយពិការជើងដោយសារគ្រាប់មីនម្នាក់ឈ្មោះសឿ ណាន។ លោកយាយបានស្នើសុំមជ្ឈមណ្ឌលកម្ពុជាជួយផ្ដល់រទេះសម្រាប់ជនពិការដល់រូបគាត់ផងដែរ ដើម្បីសម្រួលដល់ការធ្វើដំណើរ។

នៅក្នុងស្រុកដដែល ក្រុមការងារបានទៅសម្ភាសន៍អ្នកគ្រូម្នាក់ទៀត ឈ្មោះ ឈន ខិន្នែត អាយុ៥៥ឆ្នាំ រស់នៅក្នុងភូមិត្រពាំងខ្វា ឃុំភ្នំកុង ហើយក៏បានសួរនាំគាត់អំពីរឿងរ៉ាវកាលពីសម័យខ្មែរក្រហម។ អ្នកគ្រូរៀបរាប់យ៉ាងលម្អិត ហើយជូនកាលអ្នកគ្រូស្រក់ទឹកភ្នែកមកម្ដងៗ ដោយសារនឹកឃើញឡើងវិញនូវទិដ្ឋភាពជូរចត់កាលពីសម័យនោះ។ អ្នកគ្រូនិយាយថា ខ្មែរក្រហមយកឪពុកខ្លួនទៅសម្លាប់ចោលដោយគ្មានប្រាប់មូលហេតុ ធ្វើឲ្យអ្នកគ្រូមានការឈឺចាប់ជាខ្លាំងដែលមិនអាចជួយអ្វីដល់ជីវិតឪពុករបស់ខ្លួនបាន។ មានថ្ងៃមួយនោះ គាត់បានឃើញខ្មែរក្រហមសម្លាប់ស្ត្រីពោះធំម្នាក់ដោយកាប់ជាបីកង់ ព្រោះតែស្ត្រីនោះលួចឪឡឹកគេហូបអស់មួយផ្លែ។ សព្វថ្ងៃ អ្នកគ្រូមានជំងឺខ្សោយបេះដូង ដោយសារតែជួបរឿងភ័យតក់ស្លុត និងឈឺចាប់ដែលបន្សល់ទុកតាំងពីសម័យខ្មែរក្រហម។



ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះទៅជួបអាជ្ញាធរនៅស្រុកអង្គរជ័យ ខេត្តកំពត។ (ង៉ាន់ វិន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកយាយ សឿ ណាន រស់នៅក្នុងភូមិត្រពាំងខ្វា ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត និងក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វិន / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ម រិន៖ ខ្មែរក្រហមធ្វើឱ្យស្ថានភាពគ្រួសាររបស់ខ្ញុំផ្លាស់ប្តូរទាំងស្រុង

*ភា រស្មី*



*ម៉ម រិន អាយុ៧៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ម៉ម រិន ភេទស្រី អាយុ៧៩ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅសម័យសង្គមរាស្ត្រនិយមជីវភាពក្នុងគ្រួសាររបស់ខ្ញុំមានការលំបាកខ្លាំង ដែលជាហេតុធ្វើឲ្យខ្ញុំមិនបានចូលសិក្សារៀនសូត្រដូចគេ។ នៅឆ្នាំ១៩៦៩ ខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ ញៀន គុប ពាក់ស័ក្តិមួយ មានតួនាទីបើកប្រាក់ខែឲ្យកូនទាហាន។ កាលនោះខ្ញុំទៅរស់នៅក្នុងទីរួមខេត្តស្វាយរៀង។ បន្ទាប់ពីលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានរយៈពេលពីរខែ ស្ថានភាពនៅក្នុងទីរួមខេត្តស្វាយរៀងមានភាពចលាចល។ ប្តីរបស់ខ្ញុំឲ្យខ្ញុំមករស់នៅជាមួយឪពុកម្តាយនៅក្នុងស្រុកកំពង់ត្របែកមួយរយៈ ព្រោះនៅបន្ទាយកំពង់ចក ស្ថិតនៅខាងជើងទីរួមខេត្តស្វាយរៀង កងទ័ពវៀតណាមខាងជើងធ្វើការវាយប្រហារយ៉ាងខ្លាំង។ នៅឆ្នាំ១៩៧២ កងទ័ពវៀតណាមខាង

ជើង វាយយកបានបន្ទាយកំពង់ចកទាំងមូលហើយទាហានលន់នល់ទាំងអស់រួមជាមួយប្តីរបស់ខ្ញុំបានផ្លាស់ប្តូរបន្ទាយមកនៅវត្តព្រៃឆ្លាក់ ក្នុងក្រុងស្វាយរៀងវិញ។ ចំណែកខ្ញុំដែលរស់នៅស្រុកកំពង់ត្របែកគ្រប់គ្រងដោយខ្មែរក្រហម បានតាមមករកប្តីនៅបន្ទាយកំពង់ចក ក្រែងលោឃើញសាកសពប្តីរបស់ខ្ញុំ ព្រោះនៅទីនោះមានទាហានលន់នល់ស្លាប់ច្រើនណាស់ ប៉ុន្តែខ្ញុំរកមិនឃើញ។ ក្រោយមក ខ្ញុំបានស្នើសុំសំបុត្រធ្វើដំណើរពីខ្មែរក្រហមដើម្បីចូលមកខាងលន់នល់ ដោយយកលេសថា មកយកប្តីឲ្យទៅចុះចូល។ ខ្ញុំធ្វើដំណើរមកដល់វត្តព្រៃឆ្លាក់ ក៏ហែកសំបុត្រចោល បន្ទាប់មកបានចូលទៅក្នុងបន្ទាយដើម្បីតាមរកប្តីរបស់ខ្ញុំ។ ពេលនោះមានកូនទាហានម្នាក់បានរត់ទៅប្រាប់ប្តីរបស់ខ្ញុំថា លោកស្រីទើបតែធ្វើដំណើរមកដល់។ នៅក្នុងបន្ទាយ ខ្ញុំឃើញមានឡាន ១២គ្រឿងត្រៀមចេញដំណើរទៅវាយបន្ទាយខ្មែរក្រហមដើម្បីរំដោះខ្ញុំ និងប្រពន្ធទាហានផ្សេងទៀត ប៉ុន្តែពេលខ្ញុំទៅដល់ក៏អាក់ខានវិញ។

នៅឆ្នាំ១៩៧៣ ប្តីរបស់ខ្ញុំត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅមើលការខុសត្រូវនៅខេត្តកំពង់ចាម ហើយខ្ញុំទៅជាមួយដែរ។ ពេលទៅដល់កំពង់ចាមមិនបានប៉ុន្មាន ប្តីរបស់ខ្ញុំបានឲ្យខ្ញុំជិះយន្តហោះមករស់នៅទីក្រុងភ្នំពេញ ព្រោះប្តីរបស់ខ្ញុំជាប់វាយជាមួយទាហានវៀតណាមខាងជើង។ ក្រោយមក ខ្ញុំស្នើអ៊ំរបស់ខ្ញុំឈ្មោះ កង សោម ដែលធ្វើការនៅបន្ទាយទាហាននៅពោធិ៍ចិនតុងសុំខ្ទម្ពាគចក្រស្ពាបកាត់ឲ្យជូនខ្ញុំទៅជួបប្តីនៅកំពង់ចាម។ ខ្ញុំធ្វើដំណើរតាមខ្ទម្ពាគចក្រមកចុះនៅភ្នំប្រុស-ភ្នំស្រី។ ពេលមកដល់មានកូនទាហានម្នាក់យករ៉ឺម៉កមកដឹកខ្ញុំទៅបន្ទាយស៊ិបនៅជើងព្រៃ គឺជាកន្លែងដែលប្តីរបស់ខ្ញុំប្រចាំការ។ ពេលទៅដល់ភ្លាម ប្តីរបស់ខ្ញុំបានសួរខ្ញុំអំពីមធ្យោបាយធ្វើដំណើរ ហើយគាត់បានស្តីបន្ទោសខ្ញុំ ព្រោះខ្ទម្ពាគចក្រនោះទាហានទុកធ្វើសង្គ្រាម។ ខ្ញុំរស់ជាមួយគ្រួសារប្អូនថ្លៃស្រីរបស់ខ្ញុំដែលកំពុងមានផ្ទៃពោះ ហើយក្រោយមកកើតបានកូនភ្លោះពីរនាក់។

នៅឆ្នាំ១៩៧៤ ដោយសារតែការប្រយុទ្ធគ្នានៅកំពង់ចាមកាន់តែខ្លាំង គ្រួសារប្អូនថ្លៃរបស់ខ្ញុំត្រូវបានផ្ទេរឲ្យទៅប្រចាំការនៅខេត្តកំពត ចំណែកខ្ញុំត្រូវបានបញ្ជូនឲ្យមករស់នៅក្នុងទីក្រុងភ្នំពេញវិញ។ មុនដំបូងខ្ញុំដំណើមឡើងជិះខ្ទម្ពាគចក្រ ប៉ុន្តែត្រូវកូនទាហានចាប់ទាញជើងធ្លាក់មកដី ដូច្នេះខ្ញុំបានប្តូរមកជិះកប៉ាល់វិញ។ នៅតាមផ្លូវខ្មែរក្រហមបានបាញ់ជាច្រើនគ្រាប់សំដៅមកកប៉ាល់។ ដោយសារតែមានទាហានតិចតួច ដូច្នេះខ្ញុំបានចូលទៅជួយហុចគ្រាប់ផ្លោងឲ្យទាហានលន់នល់ ដើម្បីបាញ់តតាំងពីកប៉ាល់សំដៅទៅខ្មែរក្រហមវិញ។ ពេលមកដល់ភ្នំពេញខ្ញុំយកមាសទៅលក់យកលុយដើម្បីទិញផ្ទះនៅផ្សារកណ្តាលស្នាក់នៅ។ ចំណែកប្តីរបស់ខ្ញុំបានជិះកប៉ាល់មកតាមក្រោយ។



រិន និងប្តី ថតនៅឆ្នាំ១៩៧០ នៅខេត្តស្វាយរៀង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យើងរស់នៅក្នុងទីក្រុងភ្នំពេញរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

យោធាខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីទីក្រុងភ្នំពេញ ដោយលើកហេតុផលថា សម្អាតទីក្រុង។ ប្តីរបស់ខ្ញុំបានយករទេះដឹកទឹកកកដើម្បីដឹកអីវ៉ាន់ និងក្មួយក្មេងៗពីរនាក់ចេញពីទីក្រុង ប៉ុន្តែពេលចេញពីផ្ទះបានបន្តិចយើងស្នើសុំខ្មែរក្រហមត្រឡប់មកផ្ទះវិញព្រោះភ្លេចមនុស្សម្នាក់។ គ្រាន់តែគ្រួសាររបស់ខ្ញុំហៀបនឹងបកក្រោយ ស្រាប់តែយោធាខ្មែរក្រហមម្នាក់ទាញកាំភ្លើងបម្រុងបាញ់ប្តីរបស់ខ្ញុំ។ ឃើញដូច្នេះ ខ្ញុំទាញប្តីរបស់ចេញ ហើយរត់ទៅចាប់កាណុងកាំភ្លើងរបស់យោធាខ្មែរក្រហមឡើងទៅលើ។ យោធាខ្មែរក្រហមបានបាញ់រះឡើងលើអស់គ្រាប់មួយបង់។ បន្ទាប់មក យោធាខ្មែរក្រហមម្នាក់ទៀតបានរុញខ្ញុំឲ្យដួល រួចស្តីឲ្យខ្ញុំថា «ឯងក៏ឆ្លាស់ម្ល៉េះ»។ ខ្ញុំឆ្លើយតបវិញថា «បើមិនឆ្លាស់ម៉េច បើអ្នកឯងទាញកាំភ្លើងមកបាញ់មនុស្សបែប មិនស្លាប់អស់ហើយ» ហើយគ្រួសាររបស់ខ្ញុំក៏ធ្វើដំណើរបន្តទៅមុខទៀត។ នៅតាមផ្លូវទៅខេត្តកំពង់ចាម ខ្ញុំឃើញយោធាខ្មែរក្រហមបាញ់ប្រជាជនស្លាប់ជាច្រើននាក់ ដោយសារតែប្រជាជនប្រឆាំងមិនចង់ចេញពីផ្ទះ។ សាកសពខ្លះបានជះក្លិនស្អុយ និងខ្លះទៀតទើបតែស្លាប់ថ្មីៗ។ ពេលនោះក្មួយក្មេងៗរបស់ខ្ញុំយំយ៉ាងខ្លាំង ខ្ញុំបានយកក្មួយទៅឲ្យមើលមនុស្សប្រុសដែលអង្គុយក្នុងឡាន ហើយនិយាយបន្លាចក្មួយថា «បើយំប្រយ័ត្នតានៅក្នុងឡានវ៉ាយ» ប៉ុន្តែមនុស្សនៅក្នុងឡានមិនឆ្លើយតបទេ។ ពេលខ្ញុំមើលមនុស្សនៅក្នុងកាន់តែជិតទើបដឹងថាគាត់បានស្លាប់ហើយ ដោយកូនចៅរបស់គាត់បានទុក



រិន (ខាងស្តាំ) និងប្អូនស្រីរបស់នាងថតដោយពាក់ឯកសណ្ឋានយោធាក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ ឯកសណ្ឋាននោះមិនមែនជារបស់ រិន ទេ ហើយ រិន ក៏មិនធ្វើការក្នុងជួរកងទ័ពដែរ។ ដោយសារតែស្រឡាញ់ និងនឹកប្តីខ្លាំងពេកទើប រិន ខ្ចីឯកសណ្ឋានយោធាមកពាក់ថតរូប។ (ដេង ពង្សរ៉ាស៊ី /មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡានបោល រួចធ្វើដំណើរទៅបាត់អស់។ គ្រួសាររបស់ខ្ញុំធ្វើដំណើរទៅដល់កំពង់ចាមរួចត្រឡប់មកព្រៃវែងវិញ។ គ្រួសារខ្ញុំធ្វើដំណើរកាត់តាមឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ឆ្លងមកស្រុកកំពង់ត្របែក។ នៅតាមផ្លូវ ខ្ញុំបានបបួលប្តីរបស់ខ្ញុំទៅរស់នៅខេត្តស្វាយរៀង ព្រោះនៅជិតប្រទេសវៀតណាម។ ខ្ញុំគិតថាបើមានហេតុការណ៍កើតឡើង យើងអាចរត់ចូលទឹកដីវៀតណាមបានដោយងាយ ប៉ុន្តែប្តីរបស់ខ្ញុំបដិសេធព្រោះគាត់ចង់មករស់នៅជាមួយម្តាយរបស់ខ្ញុំ។ ប្តីរបស់ខ្ញុំជឿថា បដិវត្តន៍មិនមានសម្លាប់មនុស្សឡើយ។ គ្រួសាររបស់ខ្ញុំធ្វើដំណើររយៈពេល ១ខែ ទើបមកដល់ស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំរស់នៅផ្ទះបានប្រហែលមួយសប្តាហ៍ អង្គការបានស្នើយកប្តីរបស់ខ្ញុំទៅរៀនសូត្រ។ បងប្អូននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ និងឲ្យខ្ញុំខិតខំធ្វើការក្រែងលោបានរស់ជីវិត។ ខ្មែរក្រហមដឹងថា ប្តីរបស់ខ្ញុំគឺជាទាហាន លន់ នល់។ នៅក្នុងភូមិ ខ្មែរក្រហមបានប្រើខ្ញុំឲ្យហាលដីលេខមួយ (លាមកមនុស្ស) និងរែកដីៗរហូតដល់ខែវស្សា ទើបខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅស្ទូងស្រូវ និងប្រូតស្រូវពេលរដូវស្រូវទុំ។

នៅដើមឆ្នាំ១៩៧៦ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងយោធាខ្មែរក្រហមនៅតាមបណ្តោយព្រំដែន ហើយបានបណ្តាលឲ្យយោធាខ្មែរក្រហមស្លាប់អស់ជាច្រើន។ នៅពេលនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំជាមួយកងចល័តនារីទៅសែងសាកសពទាហាន និងអ្នករបួសមកព្យាបាលនៅមន្ទីរពេទ្យក្បាលថ្នល់។ អំឡុងឆ្នាំ១៩៧៦ ដដែល ខ្មែរក្រហមចាត់តាំងខ្ញុំទៅធ្វើដីសណ្តូរនៅព្រៃកណ្តូចជាមួយកងចល័តនារីផ្សេងទៀត ព្រោះខ្ញុំមិនទាន់មានកូន។ នៅព្រៃកណ្តូចប្រជាជនមូលដ្ឋានរើសអើងខ្ញុំខ្លាំងណាស់ ហើយប្រសិនបើមានការប្រជុំផ្សេងៗ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនថ្មីចូលរួមប្រជុំទេ។ ខ្ញុំធ្លាប់បានលួចស្តាប់ខ្មែរក្រហមប្រជុំម្តង ដើម្បីចង់ដឹងថាខ្មែរក្រហមមានផែនការអ្វីខ្លះ។ ខ្ញុំស្តាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយប្រាប់ប្រជាជនមូលដ្ឋានកុំឲ្យមកស្និទ្ធស្នាលជាមួយប្រជាជនថ្មី។ នៅក្នុងស្រុកកំពង់ត្របែក ប្រជាជនមូលដ្ឋានមានការរើសអើងប្រជាជនថ្មីយ៉ាងខ្លាំង ព្រមទាំងចាត់តាំងប្រជាជនថ្មីឲ្យធ្វើការងារធ្ងន់ធ្ងរដែលជាធ្វើឲ្យប្រជាជនថ្មីមួយចំនួនលេបគ្រាប់ស្លែងសម្លាប់ខ្លួន។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រឡប់មកធ្វើការនៅក្នុងភូមិវិញ។ ខ្មែរក្រហមបានដាក់វេនឲ្យកងរបស់ខ្ញុំដាំបាយ និងបុកស្រូវ ប៉ុន្តែខ្ញុំមិនសូវបានធ្វើការក្នុងកងទេ ព្រោះអង្គការចាត់តាំងខ្ញុំនិងកងចល័តនារីមួយចំនួនទៅសែងអ្នករបួស និងអ្នកស្លាប់ ពីព្រំដែនវៀតណាមយកមកព្យាបាលនៅមន្ទីរពេទ្យ ស្ថិតនៅភូមិព្រៃម្លូង ឃុំព្រៃពោន ស្រុកកំពង់ត្របែក។ នៅក្នុងឆ្នាំ១៩៧៧ មានទាហានខ្មែរក្រហមជាច្រើននាក់បានស្លាប់ ព្រោះខ្មែរក្រហមបញ្ជូនឲ្យយោធាដិះដើមចេកឆ្លងទឹកទៅវាយវៀតណាម ប៉ុន្តែដោយសារវៀតណាមស៊ើបដឹងមុនក៏ចាំបាញ់ស្នាក់។ នៅពេលយប់ ប្រធានសហករណ៍ឈ្មោះ ជឹម យន បានបញ្ជូនឲ្យកងនារីទាំងអស់នៅប្រូតស្រូវនៅភូមិក្រាំងលាវ ចំណែកពេលថ្ងៃយើងត្រូវប្រូតស្រូវនៅជិតៗភូមិ។ យើងទៅប្រូតស្រូវនៅភូមិក្រាំងលាវពេលយប់ដោយសារពេលថ្ងៃ កងទ័ពវៀតណាមចាំបាញ់ស្នាក់នៅពេលឃើញមានមនុស្សទៅក្បែរព្រំដែន។ ដូច្នេះយើងត្រូវលួចចូលប្រូតស្ងាត់ៗ មិនឲ្យវៀតណាមឃើញឡើយ។ នៅយប់មួយ ពេលដែលខ្ញុំកំពុងតែប្រូតស្រូវ កងទ័ពវៀតណាមបានបាញ់គ្រាប់ផ្លោងចូលមកធ្វើឲ្យកងចល័តនាំគ្នារត់ និងខ្លះទៀតបានស្លាប់ដោយសារត្រូវគ្រាប់។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនថ្មីទាំងអស់ឲ្យទៅរស់នៅខេត្តពោធិ៍សាត់។ ដំបូងប្រធានសហករណ៍ ឈ្មោះ យន មិនបញ្ជូនគ្រួសារខ្ញុំទៅខេត្តពោធិ៍សាត់ទេ ប៉ុន្តែដោយសារអ្នកភូមិទិតៀនច្រើនពេក ទើបប្រធានសហករណ៍បញ្ជូនគ្រួសាររបស់ខ្ញុំទៅជាមួយប្រជាជនផ្សេងទៀត។ ខ្ញុំនិងប្អូនថ្លៃរបស់ខ្ញុំ រួមជាមួយក្មួយភ្លោះពីរនាក់ទៀត បានដើរពីកំពង់ត្របែករហូតទៅដល់អ្នកលឿង ដើម្បី

ឡើងជិះកប៉ាល់ទៅក្រុងភ្នំពេញ។ នៅពេលដែលប្រជាជនឡើងលើកប៉ាល់ពេញ អ្នកបើកបរចាប់ផ្ដើមចេញដំណើរ។ ប៉ុន្តែពេលទៅដល់កណ្ដាលទន្លេស្រាប់តែយោធាខ្មែរក្រហមម្នាក់ពាក់អាវពោងរួចជាស្រេចបានទៅដកឆ្នុកកប៉ាល់ដើម្បីឲ្យទឹកហូរចូល។ ឃើញដូច្នេះ អ៊ំប្រុសម្នាក់ដែលនៅជិតខ្ញុំ បានស្រែកគំរាមថា បើមិនចុកឆ្នុកវិញ គាត់នឹងយកដកវែកវ៉ាយ។ ពុ ដូច្នេះយោធានោះព្រមធ្វើតាម ហើយយើងធ្វើដំណើរដោយសុវត្ថិភាពរហូតដល់ទីក្រុងភ្នំពេញ។ ពេលទៅដល់ទីក្រុងភ្នំពេញ ប្រជាជនទាំងអស់ទទួលរបបអាហារ ខោអាវថ្មី និងក្រមាថ្មី និងរង់ចាំជិះរថភ្លើងបន្តទៀត។ ប្រជាជនទាំងអស់ចាប់ផ្ដើមឡើងជិះលើរថភ្លើងដើម្បីធ្វើដំណើរទៅដល់ខេត្តពោធិ៍សាត់ បន្ទាប់មកក៏មានឡានមកដឹកទៅដាក់នៅតាមការដ្ឋានរៀងៗខ្លួន។ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅនៅជិតវត្តកណ្ដាល ហើយនៅទីនោះខ្ញុំឃើញមានរណ្ដៅសាកសពជាច្រើន។ នៅកន្លែងស្នាក់នៅ មានអ៊ំម្នាក់និយាយប្រាប់ខ្ញុំថា ក្រុមរបស់ខ្ញុំសំណាងជាងគេ ព្រោះអង្គការមិនយកទៅសម្លាប់ដូចក្រុមមុនៗ។ ពេលឮដូច្នេះ ខ្ញុំកាន់តែខំប្រឹងធ្វើការបន្ថែមទៀត ព្រោះអ្នកដែលមិនធ្វើការ ឬធ្វើឲ្យខូចរបស់ប្រើប្រាស់ ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលភ្លាមៗ។ ពេលល្ងាច ខ្មែរក្រហមហៅខ្ញុំទៅសួរអំពីប្រវត្តិការងារពីមុនមក ព្រោះឃើញខ្ញុំចេះគ្រប់ការងារទាំងអស់ដែលខ្មែរក្រហមដាក់ឲ្យធ្វើ។ ខ្ញុំបានហូបបាយឆ្អែត ហូបស្ករ ហើយខ្ញុំអាចបេះផ្លែឈើព្រៃហូបបន្ថែមទៀត ព្រោះអង្គការឃើញខ្ញុំធ្វើការងារបានល្អជាងគេ។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំទៅដេរខោអាវចាស់ៗ ដែលសល់ពីអ្នកស្លាប់ យកមកចែកឲ្យប្រជាជននៅក្នុងតំបន់ដែលខ្ញុំរស់នៅ។ នៅពេលដែលខ្ញុំចែកខោអាវរួច ស្រាប់តែឃើញកងទ័ពវៀតណាមចូលមកដល់ ដូច្នេះខ្មែរក្រហមចាប់ផ្ដើមកៀរប្រជាជនចូលទៅក្នុងព្រៃ។ ចំណែកគ្រួសាររបស់ខ្ញុំបបួលគ្នាត្រឡប់មកស្រុកវិញ។ ពេលនោះ យោធាខ្មែរក្រហមបានជិះសេះតាមពីក្រោយ ប៉ុន្តែពេលឃើញខ្ញុំមានកាំបិតប្រុងតដៃក៏ត្រឡប់ទៅវិញបាត់។ នៅតាមផ្លូវយោធាខ្មែរក្រហម បានលួចស្ទាក់បាញ់គ្រួសារខ្ញុំនិងប្រជាជនផ្សេងទៀត។ ខ្ញុំប្រុងចូលទីក្រុងភ្នំពេញ ប៉ុន្តែកងទ័ពវៀតណាម និងកងទ័ពរណសិរ្ស បានហាមឃាត់មិនឲ្យចូល ដូច្នេះខ្ញុំបន្តដំណើរមកព្រៃវែងតែម្ដង។ ខ្ញុំធ្វើដំណើរជាង១០ថ្ងៃបានមកដល់ស្រុកកំពង់ត្របែក។ ខ្ញុំបានជួបម្ដាយឪពុក បងប្អូន និងរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំបាត់បង់ប្ដីជាទីស្រឡាញ់ និងប្អូនប្រុសរបស់ខ្ញុំម្នាក់ ដែលផ្លាស់ទៅប្រចាំការនៅខេត្តកំពតនៅក្នុងសម័យ លន់ នល់។



*វាលស្រែក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លទិន្នន័យរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!















# តើលោកអាចកំណត់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយវិធីណា?

ឆាំង យុ





អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំបានបំផ្លាញមនុស្សធម៌របស់ប្រជាជន។ មជ្ឈមណ្ឌលឯកសារកម្ពុកមានគោលដៅស្តារឡើងវិញនូវអំពើមនុស្សធម៌នៃប្រជាជនទាំងអស់ មិនមែនត្រឹមតែជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែគឺរួមបញ្ចូលទាំងជនដែលបានប្រព្រឹត្តអំពើឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ការគាំទ្រ និងសេវាកម្មដល់ប្រជាជនកម្ពុជាឲ្យច្រើនតាមអ្វីដែលអាចធ្វើបាន ដោយផ្អែកលើការជឿជាក់ថាប្រជាជនកម្ពុជាទាំងអស់ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមទទួលការរងទុក្ខវេទនា។ បើនិយាយអំពីតួលេខ គឺមានអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ចំនួន ៥,១៨៣,៣៨៦ នាក់ (អាយុ៥០ឆ្នាំ និងលើសពី៥០ឆ្នាំ) ស្មើនឹង ៣៣.១៦ ភាគរយនៃប្រជាជនសរុប ក្នុង១៩៦ស្រុកក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៧។ មូលហេតុគឺ បច្ចុប្បន្ននេះ ប្រជាជនដែលមានអាយុចាប់ពី ៥០ឆ្នាំ ឬច្រើនជាង៥០ឆ្នាំ យ៉ាងហោចណាស់ជាក្មេងដែលមានអាយុ ៨ទៅ១០ឆ្នាំ នៅពេលដែលខ្មែរក្រហមដួលរលំក្នុង១៩៧៩។ គាត់គឺជាក្រុមមនុស្សដែលនៅ

ចងចាំរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងជាក្រុមមនុស្សដែលមានរឿងរ៉ាវសម្រាប់ចែករំលែកជាមួយយុវវ័យបច្ចុប្បន្ននេះ។

ទោះជាការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តោតសំខាន់លើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី ៥០ឆ្នាំ និងលើសពី ៥០ឆ្នាំ យ៉ាងណាក៏ដោយ យើងបានដឹងថានៅមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនទៀតដែលមានអាយុចាប់ពី៤០ឆ្នាំ និងលើសពី៤០ឆ្នាំ។ ដោយសារតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ដែលមានអាយុចាប់ពី ៤០ឆ្នាំ គឺជាទារកនៅឡើយនៅពេលដែលរបបខ្មែរក្រហមត្រូវបានដួលរលំក្នុងឆ្នាំ១៩៧៩ យើងមិនរំពឹងថា គាត់នៅមានការចងចាំផ្ទាល់ណាមួយដែលចាំមិនភ្លេច និងអាចចែករំលែករឿងរ៉ាវរបស់គាត់ជាមួយយុវវ័យបច្ចុប្បន្ននេះបានទេ។ ទោះជានៅក្នុងកាលៈទេសៈដូចនេះយ៉ាងណាក្តី មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុ ៤០ឆ្នាំ និងលើសពី ៤០ឆ្នាំ ទាំងនោះក្នុងការពិនិត្យសុខភាពដូចអ្នកដ៏ទៃទៀតដែរ ប្រសិនបើគាត់មានបញ្ហាសុខភាពទ្រុឌទ្រោម។





អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ៤. ព្យុះជីវិតក្រោយមេឃបាក់ដួងចន្ទ្រ (ត)

## អ្នកទោសកុមារបដិវត្តន៍ (ត)

### នារីមេកងកុមារបដិវត្តន៍ (ត)

...កុមារមូលដ្ឋានហូបរួច គេក៏យកម្ហូបដែលសល់មកឲ្យខ្ញុំ មើលទៅឃើញសម្លម្ជូរមានតែទឹកនិងព្រលិតមួយៗ ពណ៌ខ្មៅប៉ិរវកក្អកគ្មានសាច់ ហូបស៊ើររាល់ថ្ងៃ បបូរមាត់អណ្តាតធ្មេញពណ៌ខ្មៅស្វាយគ្រប់គ្នា។ ខ្ញុំយកចានបាយដែកកំពិតកំពៀតទៅដួសបបរជាមួយនឹងស្លាបព្រាដ៉េរកញ្ចាស់បាក់ដងមួយកំណាត់មកហូបយ៉ាងកម្សត់ទឹកអាណិតខ្លួន ក្រោមទម្ងន់មាក់ងាយមើលថោក រើសអើងពីសំណាក់មេកងកុមារ និងកម្មាភិបាលគ្រប់គ្រងរោងបាយ សហករណ៍នេះ។

ហូបបាយរួច ខ្ញុំក៏ធ្វើដំណើរមកផ្ទះ ឃើញតាយាយបងស្រីអង្គុយចាំមើលផ្លូវៗ បងស្រីសួរខ្ញុំ "ប្អូនហូបបាយហើយឬនៅ" ខ្ញុំឆ្លើយថារួចហើយ។ គាត់ដឹកដៃខ្ញុំនិងប្អូនវ៉ាទៅផ្ងូតទឹកនៅអណ្តូងក្បែរនោះ រួចរាល់បងប្អូនបីនាក់ដើរមកផ្ទះហើយ ចូលគេងតម្រៀបគ្នាលើរនាបឫស្សី។

ខ្ញុំពីរនាក់ប្អូនដេកឱបក្បាលជង្គង់ធំជាងក្បាល សម្លឹងមើលមុខគ្នាទៅវិញទៅមកទាំងរងា។ យើងដេកលើកន្ទេលធ្លុះធ្លាយមានក្រមាកញ្ចាស់មួយគ្របពីលើពីរនាក់ ដែលមានតែស្បែកដណ្តប់ឆ្អឹងយ៉ាងវេទនាជាទីបំផុត។

ខ្ញុំហាក់ដូចជាមានអារម្មណ៍ប្លែកនឹកឃើញរឿងពីថ្ងៃ ហេតុអ្វីបានជាសមមិត្តនារីមេកងកុមារនោះចងកំហឹងជាមួយខ្ញុំម្ល៉េះ? ខ្ញុំដឹងថាមានកំហុសពីរដង តែគិតថាវាមិនអីទេ រឿងតូចតាច ហើយម្យ៉ាងទៀត ខ្ញុំជាកុមារទៀតផង។

មួយសន្ទុះក្រោយមកយើងទាំងអស់គ្នាក៏លង់លក់ក្នុងស្បៃរាត្រី ដែលពោរពេញទៅដោយទុក្ខកង្វល់ដោកពេញប្រាណ។



ទិដ្ឋភាព៖ មេកងនារីកុមារឈរសម្លក់ខ្ញុំនៅក្នុងរោងបាយដែលមានតែបបរសម្លព្រលិតខ្មៅប៉ិ ជាមួយស្លាបព្រាដ៉េរកញ្ចាស់ បាក់ដងៗ (ឡុង វង្សសមិទ្ធ/សៀវភៅទូលពិយាដ៍)

# ទឹកចិត្តតាយាយ
# មេកងកុមារកំណាច

## ទឹកដោះម្ដាយថ្លៃ

តើជាសុបិនឬជាការពិត? ដឹងខ្លួនល្មើយៗឮសំឡេងដាស់អង្រួនខ្ញុំៗ យាយនិយាយតិចៗ "នៃចៅវង្សៗ ក្រោកឡើងៗ សមមិត្តនារីមេកងកុមារមករកចៅឯង!ៗ"

ខ្ញុំភ្ញាក់ឡើងក្រញាង បះសក់ព្រូង បែកញើសពេញខ្លួន ក្នុងរដូវរងាៗ ខ្លួនញ័រទទ្រើត ខ្ញុំសួរទៅយាយតា "តើមានរឿងអ្វីកើតឡើងទៅ?" គាត់តបមកខ្ញុំទាំងមាត់ញ័រតតាត់ "នៃចៅវង្ស តើចៅធ្វើអ្វីខុសបានជានារីមេកងកុមារមកយកចៅ ទាំងយប់ទៅអប់រំ" ។

ខ្ញុំយកដៃញីភ្នែកសម្លឹងទៅឃើញស្រមោលខ្មៅស្ទុងៗឈរចាំនៅមាត់ទ្វារៗ យាយតានិយាយទៅកាន់គេថា "មិត្តនារី ខ្ញុំសុំទៅជាមួយចៅបានទេឬចាំស្អែកព្រឹកសិនទៅ?"ៗ សមមិត្តនារីតបមកវិញដោយសំឡេងគ្រគោះបោះបោក "មិនបានទេយាយ អង្គការត្រូវការតែកុមារថ្មី ហើយទៅពេលនេះជាកំហិតៗ"

យាយតាផាកមកឱបខ្ញុំក្នុងក្ដីមេត្តាអាណិត ស្រណោះ និងហូរទឹកភ្នែកយំក្ដុកក្ដួលពោលតិចៗ ហេតុអ្វីបានជាចៅអភ័ព្វម្ល៉េះ គេសម្លាប់ឪពុកម្ដាយចោល ហើយឥឡូវតាមមករកកូនទៀតៗ កម្មពៀរអ្វីមិនចេះចប់ៗ ខ្ញុំក៏យំតាមគាត់អណ្ដឹតអណ្ដកៗ

មិនយូរប៉ុន្មាននារីនោះក៏ស្រែកមកថា "ប្រញាប់ឡើងៗ កម្មាភិបាលរបស់អង្គការយើងកំពុងរង់ចាំនៅឯខាងត្បូងភូមិ"ៗ គាត់យំរឹតតែខ្លាំងៗ ពាក្យអង្គការយកទៅអប់រំនេះហើយមានន័យស្មើនឹងសម្លាប់ ដែលគេធ្លាប់ប្រើមកលើកូនប្រុសរបស់គាត់គឺគូប៉ោ ដែលត្រូវជាបងបង្កើតម្ដាយខ្ញុំ បានបាត់ខ្លួនមកដល់សព្វថ្ងៃនេះៗ នារីនោះចេះតែរន្ទាន់ឆាប់ឡើងៗមិត្តកុមារ ខ្ញុំក៏សម្រេចចិត្តចាកចេញពីតាយាយក្រោមសិទ្ធិអំណាចផ្ដាច់ការមេកងនារីកុមារមិនអាចប្រកែកបានៗ

មេកងកុមារនោះក៏ស្ទុះមកកន្ត្រាក់ដៃខ្ញុំតស់ចេញទៅ យាយតាខ្ញុំក៏លើកដៃសំពះនារីនោះ "ឈប់សិនៗ មិត្តនារី



រូបថត៖ តាអាន និង យាយហ៊ាង ជាតាយាយរបស់ខ្ញុំៗ (ឡុង វង្សសមិទ្ធ/សៀវភៅទូលពិឃាដ)

ខ្ញុំសុំនិយាយជាមួយចៅខ្ញុំបន្តិចៗ" ដៃខ្ញុំម្ខាងត្រូវមិត្តនារីនោះទាញជាប់ ឯម្ខាងទៀតឱបជាមួយតាយាយៗ គាត់និយាយខ្សឹបដាក់ត្រចៀកខ្ញុំ ទាំងទឹកភ្នែកហូរចេញមកដោកនឹងក្រមា "ចៅវង្ស បើគេប្រុងសម្លាប់ចៅត្រូវទន្ទេញពាក្យថា ពុទ្ធោៗ ហើយរម្លឹកដល់គុណឪពុកម្ដាយ គ្រូបាធ្យាយ វត្ថុសក្ដិសិទ្ធិក្នុងលោកសូមជួយដល់ខ្ញុំផងណា៎ៗ" តាយាយនិយាយមិនទាន់ចប់ស្រួលបួលផងមិត្តនារីនោះទាញដៃខ្ញុំកន្ត្រាក់បណ្ដើរទៅ ដោយថ្ងើមខ្មៅគ្មានមេត្តាករុណាធម៌ក្នុងចិត្តសោះៗ

ខ្ញុំងាកមើលក្រោយឃើញតាយាយលើកដៃបួងសួង "ឱ! ព្រះជាម្ចាស់អើយ សូមជួយថែរក្សាចៅវង្សខ្ញុំផងៗ" គេបណ្ដើរខ្ញុំទាំងគ្មានអាវ ដើរឱបដៃខ្លួនរងាក្រោមទឹកសន្សើមត្រជាក់ស្រឹបកណ្ដាលអធ្រាត្រ មិនឲ្យងាកក្រោយទេៗ

ពេលនោះខ្ញុំនឹកឃើញដូចកងឈ្លបបណ្ដើរអ្នកទោស ដែលគេប្រាប់ថាពួកឈ្លើយសឹកដែលលួចរត់ចេញពីការសម្លាប់នៅទួលស្វាំងដៃចងស្លាបសេកនឹងខ្សែធាងត្នោតៗ

កងឈ្លបអាវខ្មៅស្ពាយកាំភ្លើងអូសដី ដេញចាប់អ្នកទោសដែលលួចរត់ចេញពីទួលស្វាំងដៃជាប់ចំណងស្លាបសេក ស្លៀកខោវែងរហែកមួយចំហៀងត្រឹមជង្គង់ អត់អាវ ស្គមឃើញតែស្បែក ដណ្ដប់ឆ្អឹងប្រហែលពួកគេបម្រុងសម្លាប់ៗ

ខ្ញុំឃើញកងឈ្លបបីនាក់ដេញចាប់ ហើយស្រែកថា "កុំរត់ៗ ឈប់ភ្លាមអញបាញ់ចោលឥឡូវៗ" មនុស្សនោះរត់ផងស្រែកផងថា "អូយ!!ៗ" ខ្ញុំពួននៅគុម្ពោតព្រៃលួចមើល ក្នុងចិត្តគិតថាតិចឪពុកខ្ញុំទៅ? ក្រែងលោពួកគេមិន



ទិដ្ឋភាព៖ មេកងនារីទាញដៃខ្ញុំពីតាយាយដើម្បីយកទៅអប់រំកសាង។
(ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)



ទិដ្ឋភាពស្រមៃ៖ ពេលមេកងបណ្តើរខ្ញុំយកទៅកសាង ខ្ញុំស្រមៃឃើញកងឈ្លបចាប់អ្នកទោសដែលរត់ចេញពីទួលស្លាំង
រូបភាពបច្ចុប្បន្នឆ្នាំ២០១៩៖
ផ្លូវរទេះដែលប្រធានកងនារីកុមារបណ្តើរខ្ញុំយកទៅកសាងទាំងយប់អធ្រាត្រ
(ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

ទាន់សម្លាប់ ព្រោះឪពុកខ្ញុំជាគ្រូបង្រៀន ទុកឲ្យបង្រៀនកងឈ្លបទាំងនោះសិនតែអ៊ីបានត្រឹមតែគិតប៉ុណ្ណោះ ព្រោះក្រមាប៉ាក់ជាយបានទម្លាយអាថ៌កំបាំងរួចហើយ។

មិនយូរប៉ុន្មានអ្នកទោសបដិវត្តន៍នោះក៏ដួលក្នុងស្រែ កងឈ្លបម្នាក់ដែលស្ពាយកាំភ្លើងអូសដី បានបញ្ជាឲ្យកងឈ្លបពីរនាក់ទៀតថា "នែសមមិត្ត បណ្តើរវាទៅទួលស្លាំងវិញ"។ កងឈ្លបពីរនាក់នោះបណ្តើរផង វាយផងនឹងដំបងគល់ឫស្សី និងភ្ជង់ជាមួយកាំភ្លើងអាកា។ អ្នកទោសនោះស្រែកអង្វរថា "កុំវាយខ្ញុំអី កុំសម្លាប់ខ្ញុំអី ខ្ញុំឈប់រត់គេចទៀតហើយ" ទោះជាអង្វរយ៉ាងណាក៏កងឈ្លបទាំងនោះនៅតែវាយ ទាត់ធាក់តាមអំពើចិត្តរហូតចូលទៅក្នុងទួលស្លាំងបាត់ស្រមោលគួរឲ្យអាណោចអាធ័មជាទីបំផុត។

បន្តិចក្រោយមកពុកាំភ្លើងអាកាផ្ទុះឡើងពីរគ្រាប់ជាប់គ្នាជាំងៗដែលបានបិទបាំងដោយសំឡេងចម្រៀងបដិវត្តន៍ចាក់តាមមីក្រូស្ទើរគ្រប់ពេលលាន់រំពង។ សន្មតថាអ្នកទោសបដិវត្តន៍នោះ ប្រហែលគេបាញ់សម្លាប់ចោលហើយ។

នៅពេលនោះដែរ យើងបានឮនិងឃើញស្ទើរតែរាល់ថ្ងៃដែលមនុស្សរត់ចេញពីទួលស្លាំងមកលួចមាន់អង្ករឬប្រហុក ហើយពួកកងឈ្លបដេញចាប់ ដែលគេហៅថា ពួកឈ្លើយសឹកនោះ។

នឹកឃើញរឿងនេះភ្លាម ខ្ញុំគិតថានឹងមានវាសនា មិនខុសពីអ្នកទោសបដិវត្តន៍នោះឡើយ។ ទឹកភ្នែកខ្ញុំហូរធ្លាក់មកដូចភ្លៀងរហែកមេឃ។ ខែខ្មៅងងឹតកន្លងផុតទៅដូងខែរនោចមកជំនួស។ មេឃងងឹតចាក់ភ្នែកមើលអ្វីពុំយល់។ មនុស្សសត្វទាំងឡាយនិទ្រាលង់លក់ក្នុងស្បែរាត្រីស្ងាត់ជ្រងំ មានតែភ្លើងសត្វអំពិលអំពែកហើរចុះហើរឡើងក្នុងភពងងឹត គួរឲ្យស្រណោះក្នុងរលកខ្សែជីវិតទឹកភ្នែកផុយស្រួយលើវិថីដ៏គ្រោះថ្នាក់នេះ។

# អង្គការគល់ឫស្សីលាក់មុខ

មេកងនារី បានបញ្ជាឲ្យខ្ញុំដើរលើផ្លូវទេះឆ្ពោះទៅទិសខាងលិចរហូតដល់ផ្លូវបែកជាបួនទើបឲ្យដើរទៅខាងត្បូង។ ដើរបានប្រហែលរំលងបីបួនផ្ទះគេឲ្យបត់ឆ្វេងទៅរករោងបាយ។ មកដល់កន្លែងធុងសាំងម៉ូតូចាស់ៗ ដែលកុមារ មូលដ្ឋានវាយលេងពីល្ងាច គេប្រាប់ឲ្យខ្ញុំអង្គុយចាំនៅទីនោះរួចមេកងនារីកុមារនោះដើរចេញបាត់ទៅ។

ខ្ញុំព្រឺក្បាលខ្លាកៗ មើលជុំវិញខ្លួនគ្មានឃើញអ្វីទេក្រៅតែកូនក្អាត់យំទ្រហឹងអឹងកង ខ្ញុំអង្គុយឱបដៃលើអង្កត់ឈើផ្ដេកក្បែរនោះរួចសម្លឹងមើលជុំវិញខ្លួនខ្លាចក្រែងលោគេវាយសម្លាប់នៅទីនេះ។

រង់ចាំជាយូរ មិនឃើញមានអ្វីសោះ។ មួយស្របក់ក្រោយមកឮសម្រឹបជើងមនុស្សដើរមកជិតទៅៗ ភ្លាមនោះដែរស្រមោលមនុស្សនោះ មកឈរចំពោះមុខខ្ញុំ។ ខ្ញុំមើលទៅគេជាសមមិត្តនារី។ ខ្ញុំមិនដែលស្គាល់គេពីមុនមក។ គេកាត់សក់ខ្លីបង់កក្រមា ស្លៀកពាក់ខោអាវខ្មៅ និងស្បែកជើងកង់ឡានដងៗ។ នារីនោះនិយាយ បញ្ជាឲ្យខ្ញុំដើរចូលក្នុងចម្ការមួយមានដើមឫស្សីស៊ុបទ្រុប។ ខ្ញុំលួចងាកមើល ក្រោយ។ នារីនោះប្រាប់ថា "ទៅទៀត សមមិត្តកុមារវង្វេងនៅដំបូកខាងមុខនោះ។"

ដើរឆ្ពោះទៅមុខបានបួនដប់ជំហានខ្ញុំក៏ឃើញស្រមោលមនុស្សខ្មៅមាឌធំស្គុះៗ បង់កក្រមា ពាក់មួកកាតិបពាក់ស្បែកជើងកង់ឡាន អង្គុយលើគោអីដាក់ដៃលើគុ កាន់ដំបងគល់ឫស្សីប៉ុនកំភួនដៃមនុស្សចាស់ និងកង់កញ្ចាស់មួយគ្មានគម្របភក់គ្មានជន្ទល់ ផ្ដេកនឹងគល់ឈើនៅពីក្រោយ ភ្នែកធំក្រលោតសម្លឹងមកខ្ញុំទាំងគូមិនព្រិច។

ខ្លួនខ្ញុំរងាភ័យញ័រ ឈរឱបដៃគ្មានអាវ ជើងទទេ មានតែខោខ្លីកញ្ចាស់មួយស្លៀកព្រឹកល្ងាចៗ ពេលនោះព្រលឹងខ្ញុំហោះហើរចេញបាត់ពីក្នុងខ្លួនអស់ហើយ ព្រោះដឹងច្បាស់ថាគ្មានបានវិលត្រឡប់ទៅផ្ទះវិញឡើយ។ ខ្ញុំដើរចូលទៅរកគេទាំងអារម្មណ៍ស្លាប់បាត់អស់ហើយ។

គេបញ្ជាឲ្យខ្ញុំអង្គុយទល់មុខ ឲ្យដាក់ដៃទៅក្រោយទាំងពីររួចកម្មាភិបាលនោះបានបោះខ្សែចំណងគោឲ្យសមមិត្តនារី។ ពួកគេហាក់ដូចជាដឹងមុន នារីនោះចាប់ផ្ដើមចងស្លាបសេកខ្ញុំ។

គេចងស្លាបសេកខ្ញុំជាអន្ទាក់ ទាក់កន្ត្រៃហើយរុំពីរបីជុំយ៉ាងណែន ដែលខ្ញុំមិនអាចរើរួច និងពិបាកទ្រាំជាទីបំផុតរួចហើយកម្មាភិបាលនោះបានប្រាប់នារីមេកងកុមារដើរទៅកន្លែងគុម្ពឫស្សីនិយាយខ្សឹបគ្នា។ ភ្នែកពួកគេសម្លឹងមើលមកខ្ញុំ ហើយមើលទៅរណ្ដៅអាចម៍គោនៅក្បែរនោះ។ ខ្ញុំស្ដាប់មិនច្បាស់ទេ។ ខ្ញុំគិតថា គេសម្លាប់ទម្លាក់ក្នុងរណ្ដៅអាចម៍គោនោះ។

បន្ទាប់មក ពួកគេបានដើរមករកខ្ញុំវិញ មេកងឈ្លបនោះក៏យកដៃទៅកាន់ដំបងឫស្សីវាយឮសូរផាំងៗ ខ្ញុំភ្ញាក់ព្រើតខំបិទភ្នែក នឹកក្នុងចិត្តគេប្រាកដជាធ្វើទារុណកម្ម ឬក៏សម្លាប់នៅទីនេះហើយ។ ខ្ញុំគ្មានអ្វីក្រៅពីទន្ទេញពាក្យដែលជីដូនជីតាបានប្រាប់ទាំងទឹកភ្នែកជាមួយដង្ហើមដង្ហក់ត្រដរខ្យល់។

ទន្ទេញបានពីរចប់កម្មាភិបាលនោះបានបន្លឺសំឡេងដាក់ខ្ញុំខ្លាំងៗថា "នែមិត្តកុមារថ្មីតើមិត្តកុមារឯងមានដឹងកំហុសខ្លួនឯងទេ?" ពេលនោះខ្ញុំលួចបើកភ្នែកឃើតៗសម្លឹងទៅរកគេ ហើយតបទៅវិញ" បាទ ខ្ញុំមិនដឹងទេ បងកម្មាភិបាលអើយ តែបើខ្ញុំមានកំហុសសូមសមមិត្តជួយធ្វើស៊័យទិតៀន និងកសាងដល់រូបខ្ញុំផង។"

គេតបមកខ្ញុំវិញដោយសម្ដីគ្រោកគ្រាតធ្ងន់ មួយៗ "មិត្តកុមារឯងត្រូវដឹងថា សម័យនេះ ជាសម័យបដិវត្តន៍ អង្គការបដិវត្តន៍យើងមិនត្រូវការមនុស្សច្រៀងវាយចង្វាក់ភ្លេងលេងសប្បាយដូចកុមារឯងនេះទេ ដូច្នេះត្រូវបេះកសាងខ្លួនឲ្យក្លាយទៅជាកុមារបដិវត្តន៍ពិតដូចកុមារមូលដ្ឋានឬកុមារចាស់ៗ នេះជាកំហុសលើកទីមួយ ដូច្នេះអង្គការមិនយកទោសពៃរ៍អ្វីទេ តែបើមានលើកទីពីរ អង្គការនឹងបញ្ជូនទៅកសាងអប់រំនៅថ្នាក់លើហើយ ដឹងទេមិត្តកុមារ?" សម្ដីគេគំហកខ្លាំងៗដាក់ខ្ញុំ។

ពាក្យនេះខ្ញុំដូចជាធូរអារម្មណ៍បន្តិច ខ្ញុំបានងក់ក្បាល ទាំងដៃជាប់ចំណងឆ្លើយថា "បាទសមមិត្តបង ខ្ញុំសុំធ្វើស៊័យទិតៀនដល់ខ្លួនឯង ដោយដឹង

ពីកំហុសកន្លងមក ចាប់ពីថ្ងៃនេះតទៅ ខ្ញុំនឹងខិតខំកសាងខ្លួនឲ្យក្លាយទៅជាកុមារបដិវត្តន៍ពិតៗ"

កម្មាភិបាលនោះបានប្រាប់ទៅសមមិត្តនារី "នែសមមិត្តនារី បណ្ដើរមិត្តកុមារនេះទៅកន្លែងស្នាក់នៅវិញចុះ ហើយថ្ងៃស្អែកកុំភ្លេចដាក់វិន័យលើកុមារនេះ ទៅតាមកំហុសដែលអង្គការដាក់ឲ្យ។"

ខ្ញុំដើរចេញពីកន្លែងនោះដោយដៃជាប់ចំណងស្វាបសេក។ ដើរបានបីបួនជំហាន កម្មាភិបាលនោះបាននិយាយមកកាន់មិត្តនារីនោះថា "នែ សមមិត្តនារី ខំធ្វើការបម្រើអង្គការដើម្បីឲ្យក្លាយខ្លួនជានារីកម្មាភិបាលបដិវត្តន៍គំរូ ហើយស្រាយចំណងចេញទុកប្រើថ្ងៃក្រោយទៀត"។

និយាយចប់គេក៏បណ្ដើរខ្ញុំមកវិញ ទោះជាធូរស្រាលអារម្មណ៍បន្តិចមែន តែខ្ញុំនៅតែគិតដល់ថ្ងៃស្អែក តើគេដាក់វិន័យខ្ញុំយ៉ាងណា? ខ្ញុំធ្លាប់ឃើញគេដាក់ វិន័យដល់ប្រជាជនថ្មី ដែលមិនគោរពតាមអង្គការចាត់តាំងដោយឲ្យជីកដីលើកដាក់ផ្លូវកំណត់ជាម៉ែត្រ បើធ្វើមិនបានទេអង្គការនឹងឲ្យទៅរៀនសូត្រ យកទៅរៀនសូត្រមានន័យថា យកទៅសម្លាប់ចោល។

ដើរមកដល់មុខផ្ទះដែលមិនមានរបង មិត្តនារីនោះប្រាប់ខ្ញុំថា ថ្ងៃស្អែកត្រូវងើបពីព្រលឹមដូចសព្វដងកើបអាចម៍គោឲ្យបានប្រាំក្រោល ហើយដឹកគោទៅចាំនៅក្បែរដើមចារត្រពាំងតាទិតខាងលិចភូមិ បណ្ដើរវាឲ្យដើរស៊ីស្មៅនៅក្នុងស្រែនោះ មិនឲ្យដើរទៅណាឆ្ងាយឡើយ បុឡើងដើមចាររច្រៀងទៀតទេ ហើយរង់ចាំបញ្ជពី



ទិដ្ឋភាព៖ គេយកខ្ញុំទាំងយប់ទៅកសាងអប់រំដោយចងស្វាបសេកនៅចម្ការខាងត្បូងភូមិ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

មេកងនារីកុមារ។ ខ្ញុំតបវិញថា "អរគុណសមមិត្តនារី ខ្ញុំនឹងធ្វើតាមពិន័យនេះ។ បន្ទាប់មកខ្ញុំដើរចូលទៅក្នុងផ្ទះ។

ពេលនោះយាយតាមិនចូលសម្រាន្តទេអង្គុយចាំមើលផ្លូវចៅរហង់រត់មកឱបខ្ញុំទាំងទ្រូងនិងយំផង គាត់ស្ទាបខ្លួនប្រាណខ្ញុំរួចសួរ "ចៅវង្សៗ តើគេមានធ្វើបាបចៅម្ដេចខ្លះ? ខ្ញុំបានតបថាអត់អីទេ គេអប់រំបន្តិចបន្តួច" ហើយគាត់ក៏លើកដៃសំពះទៅលើពោលថា អរគុណព្រះជាម្ចាស់។

ខ្ញុំគ្មានអ្វីថ្លាថ្លែងនូវពាក្យមេត្តាករុណា ទាំងទឹកភ្នែក រួចខ្ញុំលូនចូលក្រាបដេកលើកន្ទេលកក់កញ្ជាស់ ទឹកភ្នែកនៅតែហូរនិងខំសំងំដេក។ យាយយកក្រមាពីគាត់ដណ្ដប់មកគ្របលើខ្ញុំ ហើយនិយាយថា "ចៅដេកចុះ"។ ខ្ញុំខំប្រឹងសម្ងំដេកតែមិនលក់ស្កប់ទេ ព្រោះខ្លាចងើបមិនទាន់កើបអាចម៍គោ យើងត្រូវមានកំហុសថែមទៀត។

គេយកពាក្យសម្ដីធ្វើជាអាវុធ មុតស្រួចចាក់ទម្លុះអារម្មណ៍ផ្លូវចិត្តរបស់ខ្ញុំដាងប្រហារជីវិតទៅទៀត។ ហេតុការណ៍នេះបងស្រីចិន្តា និងប្អូនប្រុសរ៉ា ខ្ញុំមិនបានដឹងទេ។

មិនទាន់បានដេកមួយស្របក់ឡើងផង ស្រាប់តែដល់ពេលមាន់រងាវបីដង។ ខ្ញុំក៏រូតរះងើបឡើងទាញរទេះកង់មួយមានបង្គីពីលើ។ យាយងើបមកសួរចៅទៅណាទាំងព្រលឹមអុរអ៊ីចឹង? ខ្ញុំតបទៅគាត់វិញថា "បាទយាយ ខ្ញុំត្រូវមិត្តនារីមេកងកុមារដាក់ពិន័យឲ្យដើរប្រមូលអាចម៍គោឲ្យបានប្រាំក្រោល" គាត់ងក់ក្បាល "អូ! អ៊ីចឹងទៅចុះ"។

ខ្ញុំចាប់ផ្ដើមប្រមូលសម្អាតពីមួយក្រោលទៅមួយក្រោលយកទៅចាក់នៅរណ្ដៅមួយ។ ខ្ញុំធ្វើការពិន័យនេះ រួចហើយ ថ្ងៃចាប់ផ្ដើមរះភ្លឺច្បាស់ ខ្ញុំក៏រុញរទេះមកទុកហើយដឹកមេគោទៅចាំនៅខាងលិចភូមិក្បែរដើមចារត្រពាំងតាទិត ដែលគេបានប្រាប់ពីយប់។

**(តនៅលេខក្រោយ)**

# ស្វែងរកសមាជិកគ្រួសារ៦នាក់ ដែលបាត់ខ្លួនតាំងពីឆ្នាំ ១៩៧៣













Mr. Chhouk Sam An né 1943.
Mme Chhouk Sam An ... Lok Leng
née en 1951.
Chhouk Thavarith né en 1968.
Chhouk Kunnoroth née en 1969.
Chhouk Thavasoth né en 1970.
Chhouk Sechamoli né en 1974.
Bac Piguet à Phnom Penh.

ខ្ញុំសរសេរសេចក្តីប្រកាសនេះ ដើម្បីស្វែងរកក្រុមគ្រួសារ ខាងម្តាយក្មេករបស់ខ្ញុំ។ ម្តាយក្មេករបស់ខ្ញុំកើតនៅ ទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៥៦។ គាត់ត្រូវជាកូនស្រីរបស់ ប៉ែង ខូវ ហៅ ខូយ (កើតឆ្នាំ១៩២១ និងស្លាប់ឆ្នាំ២០១៦) និង លី ហ្គេតជួន (កើតឆ្នាំ១៩២០ និងស្លាប់នៅឆ្នាំ២០១០)។ ម្តាយក្មេករបស់ខ្ញុំមានបងប្អូនបង្កើត១០នាក់ ហើយបងប្អូនរបស់គាត់ភាគច្រើនបានភៀសខ្លួនចេញពីប្រទេសកម្ពុជាតាមយន្តហោះក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ គឺនៅសល់តែបងស្រីធំម្នាក់ ដែលរៀបការរួច រស់នៅជាមួយប្តី និងកូន ៤ នាក់នៅក្នុងប្រទេសកម្ពុជា។ តាំងពីពេលនោះមក បងប្អូនប្រុសស្រីរបស់គាត់ទាំងអស់ដែលបានភៀសខ្លួនចេញពីប្រទេសកម្ពុជា ពុំដែលបានជួបបងស្រីធំទេ។ ឪពុកម្តាយរបស់គាត់ធ្លាប់បានស្វែងរកគាត់ដែរ ប៉ុន្តែឪពុកម្តាយរបស់គាត់ពុំដែលវិលត្រឡប់មកប្រទេសកម្ពុជាទេ ហើយបច្ចុប្បន្នពួកគាត់បានស្លាប់ទៅហើយ។

ម្តាយក្មេករបស់ខ្ញុំ និងបងប្អូនបង្កើតរបស់គាត់គ្រប់គ្នាសង្ឃឹមថា នឹងទទួលបានដំណឹងពីបងស្រីធំរបស់គាត់រួមជាមួយកូនៗនៅរស់រានមានជីវិត។

ខាងក្រោមនេះគឺជាឈ្មោះសមាជិកក្រុមគ្រួសាររបស់បងស្រីធំរបស់គាត់៖

- **ខូវ ខូយគិច** ឈ្មោះហៅក្រៅ **ឡ លីង** កើតឆ្នាំ១៩៥១ ត្រូវជាបងស្រីធំ
- **ឈូក សំអាន** កើតឆ្នាំ១៩៤៣ ត្រូវជាប្តីរបស់បងស្រីធំ

ខាងក្រោមនេះគឺ ឈ្មោះកូនទាំង៤នាក់របស់បងស្រី ធំ៖

១) **ឈូក ថាវរិទ្ធ** កើតឆ្នាំ១៩៦៨
២) **ឈូក ខុនណ្ណារ័ត្ន** កើតឆ្នាំ១៩៦៩
៣) **ឈូក ថាវសុទ្ធ** កើតឆ្នាំ១៩៧០
៤) **ឈូក សេកហាម៉ូលី** កើតឆ្នាំ១៩៧៤

ប្រសិនបើបងប្អូនមានដំណឹងឬសំណួរអ្វី សូមផ្ញើអ៊ីម៉ែលមកកាន់ខ្ញុំ joaocsdocarmogil@gmail.com
សូមអរគុណ! ចៅ ស៊ូសា

រូបក្របមុខ៖

សិស្សានុសិស្សនៅស្រុកក្រូចបានចូលរៀនវិញ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្តួលរំលំ
នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ
នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅខាងមុខព្រះបរមរាជវាំង ក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 265, January 2022 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.